ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍បូកសរុប
# ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០២៤
# និងទិសដៅឆ្នាំ២០២៥

រាជធានីភ្នំពេញថ្ងៃទី២០ ខែមករា ឆ្នាំ២០២៥

# មាតិកា

**១. សេចក្តីផ្តើម** ............................................................ ១
**២. លទ្ធផលនៃការអនុវត្តថវិកាកម្មវិធី** ............................................................ ២
**៣. អនុសាសន៍សម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** .......... ៣
**៤. លទ្ធផលជារួម** ............................................................ ៥
៤.១ ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ ............................................................ ៥
៤.២ កំណើនវិស័យកសិកម្ម ............................................................ ៦
៤.៣ ការចូលរួមចំណែករបស់អនុវិស័យនានាក្នុងវិស័យកសិកម្ម ............................................................ ៦
**៥. លទ្ធផលតាមអនុវិស័យ និងផ្នែកផ្សេងៗ** ............................................................ ៧
៥.១ ការងារបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិធុរកិច្ច ............................................................ ៧
៥.២ ការបង្កើនផលិតភាពដំណាំកៅស៊ូ ............................................................ ១៦
៥.៣ ការងារផលិតកម្មសត្វ និងសុខភាពសត្វ ............................................................ ១៩
៥.៤ ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម ............................................................ ២៩
៥.៥ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានព្រៃឈើ និងសត្វព្រៃ ............................................................ ៣២
៥.៦ ការងារសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស ............................................................ ៣៥
**៦. បញ្ហាប្រឈម** ............................................................ ៣៩
**៧. ទិសដៅអនុវត្ត** ............................................................ ៤០
៧.១ ផែនការជំរុញផលិតកម្មដំណាំស្រូវ ដំណាំស្បៀងរួមផ្សំ និងដំណាំទ្រទ្រង់សេដ្ឋកិច្ច ............................................................ ៤០
៧.២ ផែនការបង្កើនផលិតកម្មដំណាំកៅស៊ូ ............................................................ ៤១
៧.៣ ផែនការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ ............................................................ ៤១
៧.៤ ផែនការពង្រឹងការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម ............................................................ ៤២
៧.៥ ផែនការពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃ ............................................................ ៤២
៧.៦ ផែនការពង្រឹងការគ្រប់គ្រងស្ថាប័ន និងអភិវឌ្ឍន៍ធនធានមនុស្ស ............................................................ ៤៤
**៨. សេចក្តីសន្និដ្ឋាន** ............................................................ ៤៥
**តារាងឧបសម្ព័ន្ធ**

# របាយការណ៍បូកសរុប
# ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០២៤
# និងទិសដៅឆ្នាំ២០២៥

## ១. សេចក្តីផ្តើម

រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយថាមវន្តរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងកម្មវិធីគោលនយោបាយអាទិភាព សំដៅធានាសុខសន្តិភាព ស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច ដែលជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍលើគ្រប់វិស័យ។

នៅគ្រប់ដំណាក់កាលទាំងអស់ រាជរដ្ឋាភិបាលនៅតែបន្តចាត់ទុកវិស័យកសិកម្មជាវិស័យអាទិភាព ដែលចូលរួមចំណែកយ៉ាងសកម្មក្នុងការធានាសន្តិសុខស្បៀង ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ កាត់បន្ថយភាពក្រីក្រ និងទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ។ ជាមួយគ្នានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានតួនាទីជាសេនាធិការលើការអភិវឌ្ឍវិស័យកសិកម្ម ស្របតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា។ ក្នុងន័យនេះ ក្រសួងមានកាតព្វកិច្ចចូលរួមអនុវត្តឱ្យសម្រេចជោគជ័យនូវការងារអាទិភាពដូចមានចែងក្នុង **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** នៅក្នុង **ស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ** មាន(មុំទី១)-ការពង្រឹងនិងការកែទម្រង់ស្ថាប័ន (មុំទី២)-ការលើកកម្ពស់សមត្ថភាពធនធានមនុស្ស និងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ និង(មុំទី៤)-ការបន្តកសាងភាពជាដៃគូប្រកបដោយបរិយាបន្ន និងស័ក្តិសិទ្ធិភាព នៃកិច្ចសហប្រតិបត្តិ ការអភិវឌ្ឍន៍។ **បញ្ចកោណទី២ ការធ្វើពិពិធកម្មសេដ្ឋកិច្ចនិងការបង្កើនភាពប្រកួតប្រជែង** មាន(មុំទី១)-ការអភិវឌ្ឍវិស័យគន្លឹះ និងប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច (មុំទី៣)-ការកែលម្អបរិកាសធុរកិច្ចនិងការវិនិយោគ និង(មុំទី៤)-ការពង្រឹងប្រសិទ្ធភាព និងភាពទាក់ទាញ នៃតំបន់សេដ្ឋកិច្ចពិសេស រួមបញ្ចូលនូវសួន-ឧស្សាហកម្ម សួនកសិ-ឧស្សាហកម្ម និងតំបន់ពាណិជ្ជកម្មសេរីក្នុងស្រុក។ **បញ្ចកោណទី៣ ការអភិវឌ្ឍវិស័យឯកជននិងការងារ** មាន(មុំទី២)-ការលើកស្ទួយសហគ្រាសធុនមីក្រូ តូច មធ្យម ធុរកិច្ចថ្មី សហគ្រិនភាព និងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ (មុំទី៣)-ការពង្រឹងភាពជាដៃគូ វិស័យសាធារណៈ និងវិស័យឯកជន (មុំទី៤)-ការពង្រឹងការប្រកួតប្រជែង និង**បញ្ចកោណទី៤ ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន** មាន(មុំទី២)-ការគ្រប់គ្រងធនធានធម្មជាតិ បេតិកភណ្ឌវប្បធម៌ និងទេសចរណ៍ ប្រកបដោយចីរភាព និង(មុំទី៣)-ការលើកស្ទួយកសិកម្ម និងការអភិវឌ្ឍជនបទ។

រយៈពេលពេញមួយឆ្នាំនៃឆ្នាំ២០២៤ កន្លងទៅនេះ ក្រសួងបានខិតខំជំរុញអនុវត្តវិធានការចាំបាច់នានា រួមមាន ការកសាងនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធគាំទ្រផលិតកម្មកសិកម្ម ការបង្កើនគុណភាពស្រាវជ្រាវនិងផលិតពូជ ការជំរុញការស្រាវជ្រាវបច្ចេកទេសកសិកម្មសំដៅបង្កើនទិន្នផលដំណាំធន់នឹងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងនិងបង្កើនប្រសិទ្ធភាពការប្រើប្រាស់ដីកសិកម្ម ព្រមទាំងការកសាង និងការពង្រឹងសមត្ថភាពធនធានមនុស្សនិងស្ថាប័ន ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្មឱ្យមានប្រសិទ្ធភាពខ្ពស់។ ទន្ទឹមនេះ ក្រសួងបានយកចិត្តទុកដាក់លើកកម្ពស់ការចិញ្ចឹមសត្វ ផលិតកម្មចំណីសត្វ និងវារីវប្បកម្ម ផលិតពូជត្រីនិងវារីសត្វផ្សេងទៀត អភិរក្សពូជ ព្រមទាំងបង្កើនការប្រើប្រាស់

បច្ចេកទេសសមស្រប និងជំរុញការពង្រឹងការអនុវត្តច្បាប់ ដើម្បីគ្រប់គ្រង និងប្រើប្រាស់ធនធានព្រៃឈើ និងជលផល ប្រកបដោយចីរភាព។ ជាមួយគ្នានេះ ក្រសួងខិតខំប្រឹងប្រែងផ្សព្វផ្សាយជូនកសិករប្រើប្រាស់ បច្ចេកទេសក្នុងការកាត់បន្ថយថ្លៃដើមផលិត ជួយសម្របសម្រួលទីផ្សារ និងឈានបង្កើនប្រាក់ចំណូល ព្រមទាំងបង្កើនតម្លៃបន្ថែមផលិតផលកសិកម្ម ជំរុញកសិ-ធុរកិច្ច និងបង្កើនចំណូលជាតិ។ គួរកត់សម្គាល់ថា លទ្ធផលល្អប្រសើរនេះអាចសម្រេចទៅបាន អាស្រ័យដោយមានការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា កិច្ចសហការល្អពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ វិស័យឯកជន អង្គការជាតិនិងអន្តរជាតិនានា រដ្ឋបាលថ្នាក់ក្រោមជាតិ និងការចូលរួមយ៉ាងសកម្មពីប្រជាកសិករ។

## ២. លទ្ធផលនៃការអនុវត្តថវិកាកម្មវិធី

### ២.១ កម្មវិធីទី១៖ ការបង្កើនផលិតភាពពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច

ក្នុងឆ្នាំ២០២៤ ការអនុវត្តថវិកាកម្មវិធីទី១ បានចំណាយប្រមាណ ២៩ ៣០២លានរៀល ស្មើនឹង ៩៩,០៨% នៃកញ្ចប់ថវិកាក្រោយវិចារណកម្ម ដោយទទួលបានផលិតកម្មដំណាំកសិកម្មសរុបចំនួន ៣៩,៤០លានតោន កើនឡើងប្រមាណ ៦,៦០% ធៀបឆ្នាំ២០២៣ ក្នុងនោះផលិតកម្មដំណាំស្រូវបានចំនួន ១៣,៨៩លានតោន ផលិតកម្មដំណាំដំណាំស្បៀងរួមផ្សំចំនួន ៥លានតោន និងផលិតកម្មដំណាំទ្រទ្រង់សេដ្ឋកិច្ចចំនួន ២០,១០លានតោន និងផលិតកម្មដំណាំកៅស៊ូចំនួន០,៤០លានតោន។ កម្ពុជាបាននាំចេញជាផ្លូវការនូវផលិតផលកសិកម្មសរុបប្រមាណ ១២លានតោន ដែលមានទំហំជាទឹកប្រាក់ប្រមាណជាង ៥ ២៩៦លានដុល្លារអាមេរិក និងកើនលើសឆ្នាំ២០២៣ ចំនួន ៤៩៨លានដុល្លារអាមេរិក ស្មើនឹង ៩%។ កម្ពុជាមានអតិរេកបរិមាណផលស្រូវនៅសល់ក្រោយពីតម្រូវការស្បៀងប្រើប្រាស់ក្នុងស្រុកចំនួនជិត ៨,១៦លានតោន គិតជាងអង្ករមានចំនួន ៥,២២លានតោន កើន ១៦,៥៤% ធៀបឆ្នាំ២០២៣។

### ២.២ កម្មវិធីទី២៖ ការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ

ក្នុងឆ្នាំ២០២៤ ការអនុវត្តថវិកាកម្មវិធីទី២ បានចំណាយប្រមាណ ១១ ៣៤៦លានរៀល ស្មើនឹង ៩៧,៤៥% នៃកញ្ចប់ថវិកាក្រោយវិចារណកម្ម ដោយទទួលបានផលិតកម្មសត្វសរុបចំនួន ៦៩,៣០លានក្បាល មានអត្រាកំណើនចំនួន ៤,១%ធៀបឆ្នាំ២០២៣ ដែលក្នុងនោះគោ/ក្របី សរុបមានចំនួន ៣,៥១លានក្បាល កើនឡើងចំនួន ០,៦២% ធៀបឆ្នាំ២០២៣ ជ្រូកសរុបមានចំនួន ៤,០៦លានក្បាល កើនឡើងចំនួន ១៣,៤១% ធៀបឆ្នាំ២០២៣ និងបក្សីសរុបមានចំនួន ៦១,៥៥លានក្បាល កើនឡើងចំនួន ៣,៧១% ធៀបឆ្នាំ២០២៣។ ក្រសួងបានយកចិត្តទុកដាក់លើការងារផលិតកម្មសត្វទាំងលក្ខណៈគ្រួសារ និងពាណិជ្ជកម្ម សំដៅធានាការផ្គត់ផ្គង់សាច់ និងផលិតផលសត្វមានគុណភាព អនាម័យ និងសុវត្ថិភាព សម្រាប់បំពេញតម្រូវការហូបចុករបស់ប្រជាពលរដ្ឋ។

### ២.៣ កម្មវិធីទី៣៖ ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម

ក្នុងឆ្នាំ២០២៤ ការអនុវត្តថវិកាកម្មវិធីទី៣ បានចំណាយប្រមាណ ១១ ៤៨៥លានរៀល ស្មើនឹង ៩៧,៨៨% នៃកញ្ចប់ថវិកាក្រោយវិចារណកម្ម ដោយទទួលបានផលនេសាទ និងវារីវប្បកម្មសម្រេចបានចំនួនជាង ៩២៧ពាន់តោន កើនឡើង ៦១ពាន់តោន ស្មើនឹង៧% ធៀបនឹងឆ្នាំ២០២៣ ដែលក្នុងនោះ ផលនេសាទទឹកសាបទទួលបាន ៤៦៧ពាន់តោន ផលនេសាទសមុទ្រទទួលបាន ១៣៩ពាន់តោន និងផលវារីវប្បកម្ម ៣២០ពាន់តោន។ ទន្ទឹមនេះ ការអភិរក្សសត្វផ្សោតដែលជារតនសម្បត្តិជាតិ ក្រសួងទទួលបានតួលេខវិជ្ជមាន ដែលមានសត្វផ្សោតបានកើតកូនចំនួន ៩ក្បាល និងស្លាប់៤ក្បាល តាមការប៉ាន់ស្មានមានសត្វផ្សោតសរុបចំនួន ១០៤ក្បាលក្នុងឆ្នាំ២០២៤។ ជាមួយគ្នានេះ ក៏មានវត្តមានជ្រូកទឹកជាច្រើនឡើងវិញបន្ទាប់ពីបាត់ខ្លួនជាង១០ឆ្នាំកន្លងមក ជាមួយគ្នានេះ ផ្សោតឃ្លៀច (ផ្សោតពណ៌ផ្កាឈូក) និងផ្សោតក្បាលត្រឡោកក៏កើនឡើងច្រើនផងដែរ ប្រមាណជាង១០០ក្បាល ដែលតែងតែមានវត្តមានជា

ញឹកញាប់នៅតំបន់ឆ្នេរ ពិសេសខេត្តកំពតនិងកែប។ ក្រសួងបានពង្រឹងកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអាជ្ញាធរមានសមត្ថកិច្ចក្នុងការទប់ស្កាត់បទល្មើសនេសាទកាន់តែមានប្រសិទ្ធភាព ដើម្បីធានាបាននូវការផ្គត់ផ្គង់ កាត់បន្ថយការនាំចូល រក្សាបានតុល្យភាពតម្លៃទីផ្សារ ព្រមទាំងធានាបាននូវគុណភាព និងសុវត្ថិភាពសម្រាប់អ្នកបរិភោគ។

### ២.៤ កម្មវិធីទី៤៖ ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃ

ការអនុវត្តថវិកាកម្មវិធីទី៤ សម្រេចបានប្រមាណ ៨ ៨៣៣លានរៀល ស្មើនឹង ៩៦,៦១% នៃកញ្ចប់ថវិកាក្រោយវិចារណកម្ម ដោយបានគាំទ្រដល់សហគមន៍ព្រៃឈើសរុបមានចំនួន ៦៥៥ សហគមន៍ គ្របដណ្តប់លើផ្ទៃដី ៥៣០ ៤៩៨ ហិកតា មានប្រជាសហគមន៍ចូលរួមសរុប ១៧២ ៣៩៨ គ្រួសារ បានចូលរួមចំណែកគ្រប់គ្រង និងអភិវឌ្ឍធនធានព្រៃឈើ និងសត្វព្រៃ ព្រមទាំងបានដាំឈើជាចម្ការថ្មី និងទីសាធារណៈលើផ្ទៃដីទំហំ ២២ ៩០០ហ.ត ក្នុងនោះដាំដោយរដ្ឋ ១៥៣ហិកតា និងដាំដោយក្រុមហ៊ុនដៃគូសហការ និងទីសាធារណៈ ២២ ៧៤៧ ហិកតា។ ក្រសួងបានបន្តផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការគ្រប់គ្រង ការអភិរក្ស បានចូលរួមដាំឈើជាចម្ការថ្មី និងទីសាធារណៈ និងការអភិវឌ្ឍធនធានព្រៃឈើឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ដោយចូលរួមសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសនានា។

ជារួមក្នុងឆ្នាំ២០២៤ ក្រសួងបានទទួលកញ្ចប់ថវិកាចំនួន ៣១៦,៣៥៣លានរៀល ថវិកាសម្រាប់អនុវត្ត ២៨៦,២២០លានរៀល ស្មើនឹង ៩៤,៨% នៃថវិកាក្រោយវិចារណកម្ម។ សមិទ្ធផលទាំងនេះបានឆ្លុះបញ្ចាំងឱ្យឃើញថាវិស័យកសិកម្មមានការរីកចម្រើនគួរឱ្យកត់សម្គាល់ និងបានចូលរួមចំណែកយ៉ាងសកម្មក្នុងការធានាសន្តិសុខស្បៀង លើកកម្ពស់កម្រិតជីវភាពប្រជាជន បង្កើនប្រាក់ចំណូលក្នុងគ្រួសារ ជាមួយនឹងការបង្កើនការនាំចេញ និងទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ។

## ៣. អនុសាសន៍សម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ក្រសួងបានសហការជាមួយស្ថានប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបន្តអនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងពិធីបិទសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០២៣ និងទិសដៅឆ្នាំ២០២៤ ទទួលបានលទ្ធផលដូចខាងក្រោម៖

- អនុវត្តកម្មវិធីលើកកម្ពស់ខ្សែសង្វាក់ផលិតកម្មកសិកម្ម ប្រកបដោយនិរន្តរភាពតាមរយៈការលើកកម្ពស់ សហគមន៍កសិកម្មទំនើប ការផ្តល់សេវាបច្ចេកទេសកសិកម្មដល់កសិករ ស្ថិរភាពតម្លៃផលិតផល និងការគ្រប់គ្រងធនធានកសិកម្ម។ ទន្ទឹមនឹងនេះ ក្រសួងបានបង្កើតប្រព័ន្ធគ្រាប់ពូជសុទ្ធ លើកកម្ពស់ផលិតកម្មស្រូវ និងចុះបញ្ជីពូជដំណាំចំនួនប្រាំពីរ បញ្ជីកសិដ្ឋានបន្លែ និងផ្លែឈើចំនួន ៤១១ លើស្តង់ដារការអនុវត្តកសិកម្មល្អកម្ពុជា (CamGAP) ដោយធានាបាននូវគុណភាព និងសុវត្ថិភាពសម្រាប់ការប្រើប្រាស់ក្នុងស្រុក និងការនាំចេញ។ ក្រសួងបានសហការជាមួយរោងម៉ាស៊ីនកិនស្រូវធំៗ និងអាជ្ញាធរមូលដ្ឋាន ដើម្បីរក្សាស្ថិរភាពតម្លៃស្រូវក្នុងរដូវប្រមូលផល។ ក្រសួងក៏បានធ្វើអន្តរាគមន៍ក្នុងកិច្ចខិតខំប្រឹងប្រែងជួយសង្គ្រោះគ្រោះមហន្តរាយ ដោយបានចែកគ្រាប់ពូជស្រូវដល់គ្រួសារកសិករចំនួន ២០.៣៣៨ គ្រួសារ និងកម្ចាត់សត្វល្អិត រុយ ព្រូន និងស្លឹកគ្រៃ ដោយជួយសន្សំបានជាង ៩៦% នៃផ្ទៃដីដែលរងផលប៉ះពាល់។

- បង្កើនការអភិរក្សធនធានជលផល ជាពិសេសការបង្កាត់ពូជត្រី ផ្សោតទន្លេមេគង្គ និងប្រភេទសត្វដែលងាយរងគ្រោះ។ នេះរួមបញ្ចូលទាំងការការពារ និងដាំព្រៃលិចទឹក សាងសង់ទីស្នាក់ការ និងពង្រឹងការល្បាត។ ជាមួយគ្នានេះ ក្រសួងក៏បានអនុវត្តប្រព័ន្ធតាមដាននាវានៅលើកប៉ាល់នេសាទសមុទ្រ ការដាក់ពង្រាយជម្រកត្រីសិប្បនិម្មិត និងសហការជាមួយភ្នាក់ងារអនុវត្តច្បាប់ ផលនេសាទបានកើនឡើងចំនួន ១០%។ ក្រសួង បានលែងប្រភេទវារីសត្វកម្រ ត្រីមេពូជ និងលើកទឹកចិត្តដល់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចខិតខំប្រឹងប្រែងអភិរក្ស ព្រមទាំងបានបង្ក្រាបបទល្មើសនេសាទចំនួន ៣១៧៦ ករណី បំពាក់ប្រព័ន្ធតាមដានកប៉ាល់នៅលើនាវានេសាទសមុទ្រចំនួន ៨០០ និងបានធ្វើការស្រាវជ្រាវលើជីវសាស្ត្រនៃជលផល និងការធ្វើចំណាកស្រុកនៅទន្លេមេគង្គលើ។
- បានអនុវត្តយន្តការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ ដីព្រៃឈើ បទល្មើសរត់ពន្ធឈើ និងសត្វព្រៃ ក្នុងនោះរួមមាន គណៈកម្មការជាតិ បញ្ជាការឯកភាព និងអនុគណៈកម្មាធិការខេត្ត រដ្ឋបាលព្រៃឈើ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករ។ ក្រសួងក៏បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីព្រៃឈើថ្មី។ កំណែទម្រង់សម្រាប់ការគ្រប់គ្រង និងការដាំដុះចម្ការព្រៃឈើ មានគោលបំណងលើកទឹកចិត្តដល់ការចូលរួមរបស់វិស័យឯកជនក្នុងដាំចម្ការព្រៃឈើ ដើម្បីឆ្លើយតបនឹងតម្រូវការប្រើប្រាស់ក្នុងស្រុក ការនាំចេញ។ កំណែទម្រង់នេះ ក៏បានពង្រឹងការស្រាវជ្រាវលើប្រភេទដើមឈើដែលលូតលាស់លឿនសម្រាប់ប្រសិទ្ធភាពសេដ្ឋកិច្ច ដោយសម្រេចបានលើផ្ទៃដីទំហំ ៩០ ០៤៦ហិកតា មានការចូលរួមពីក្រុមហ៊ុនចំនួន ២០ ដៃគូអភិវឌ្ឍន៍ និងគ្រួសារ។
- បានរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅគណៈបសុពេទ្យ និងបានបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី និងបានរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតបណ្ឌិត្យសភាវិទ្យាសាស្ត្រកសិកម្មកម្ពុជា ដោយបានប្រមូលផ្តុំអង្គភាពស្រាវជ្រាវកសិកម្មចំណុះអង្គភាពទាំងអស់ ក្នុងគោលបំណងពង្រឹង ពង្រីក និងធានាប្រសិទ្ធភាពការងារស្រាវជ្រាវបម្រើដល់ការអភិវឌ្ឍវិស័យកសិកម្មឱ្យកាន់តែរីកចម្រើន ស្របតាមបរិបទនៃការវិវត្តន៍របស់សង្គម និងសេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន។ លើសពីនេះ កម្មវិធីបណ្តុះបណ្តាល ការស្រាវជ្រាវវិទ្យាសាស្ត្រ និងការផ្ទេរបច្ចេកទេសកសិកម្មត្រូវបានកែលម្អ។
- តាមរយៈការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈក្នុងអាណត្តិទី៧ នៃរដ្ឋសភា ក្រសួងបានកំណត់មុខងារស្នូលចំនួន ១៣ និងអនុមុខងារចំនួន ៧៣ ដោយបានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងស្នើសុំឱ្យរដ្ឋាភិបាលពិនិត្យឡើងវិញ។ ទន្ទឹមនេះ ក្រសួងក៏បានចូលរួមជ្រើសរើសមន្ត្រីកសិកម្មឃុំ-សង្កាត់ចំនួន ១ ២៥០នាក់ ដោយក្នុងនោះ ២៥០នាក់ បានទទួលការបណ្តុះបណ្តាលបឋម និងបណ្តុះបណ្តាលជំនាញបច្ចេកទេស និងបម្រើការងារនៅតាមឃុំគោលដៅក្នុងស្រុកចំនួន ៨៩ នៃខេត្តចំនួន ១៧ និងបន្តជ្រើសរើសក្នុងឆ្នាំ២០២៥ ចំនួន ៣៥០នាក់។
- បានសម្របសម្រួលហិរញ្ញប្បទានពិសេសចំនួន ៤០លានដុល្លារអាមេរិក ដល់រោងម៉ាស៊ីនកិនស្រូវ និងក្រុមហ៊ុនកែច្នៃចំនួន ២៣ ដើម្បីប្រមូលទិញស្រូវឱ្យចំគោលដៅដែលជួបបញ្ហាប្រឈមទីផ្សារ នាំឱ្យតម្លៃស្រូវមានស្ថិរភាពទៅតាមទីតាំង និងតាមប្រភេទពូជស្រូវ។
- បានរៀបចំផែនការសកម្មភាពអាទិភាពសម្រាប់ការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្មឆ្នាំ២០៣០ និងបានចូលរួមរាយការណ៍ស្តីពី ការចូលរួមចំណែករបស់កម្ពុជាដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពី

ការប្រែប្រួលអាកាសធាតុ National Determined Contribution (NDC)។ ទន្ទឹមនេះ ក្រសួងក៏បានអនុវត្តគម្រោងដៃគូអភិវឌ្ឍន៍ ដើម្បីរួមចំណែកលើកកម្ពស់ជីវភាពកសិករ និងកាត់បន្ថយការបំភាយឧស្ម័នមេតានព្រមទាំងបានចូលរួមក្នុងយន្តការឥណទានកាបូន និងសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់។

## ៤. លទ្ធផលជារួម

ក្នុងឆ្នាំកន្លងទៅ ទឹកភ្លៀងបានចាប់ផ្តើមធ្លាក់តាំងពីដើមរដូវវស្សា នៅតាមបណ្តាខេត្តមួយចំនួនក្នុងប្រទេស និងបានបន្តធ្លាក់យ៉ាងច្រើនក្នុងអំឡុងខែកញ្ញា និងតុលា ដែលបង្កឱ្យមានជំនន់ទឹកភ្លៀង និងបណ្តាលឱ្យប៉ះពាល់ និងខូចខាតផលិតកម្មដំណាំ ជាពិសេសដំណាំស្រូវ និងដំណាំឧស្សាហកម្មមួយចំនួន។ ជាមួយគ្នានោះក៏មានតំបន់មួយចំនួនទទួលរងនូវគ្រោះរាំងស្ងួត។ ទោះបីជាជួបគ្រោះធម្មជាតិក្តី វិស័យកសិកម្មនៅតែឈររឹងមាំ និងបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សាបាននូវសន្តិសុខស្បៀង តាមរយៈការផ្គត់ផ្គង់ស្បៀងអាហារ អង្ករ បន្លែ ត្រី និងសាច់ បានគ្រប់គ្រាន់នៅក្នុងប្រទេស និងនៅសល់សម្រាប់នាំចេញទៅកាន់ទីផ្សារអន្តរជាតិទៀតផង។

### ៤.១ ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ

ឆ្នាំ២០២៤ វិស័យកសិកម្មបានចូលរួមចំណែកប្រមាណ ១៦,៧% (គិតជាតម្លៃបច្ចុប្បន្ន) ក្នុងផលិតផលសរុបក្នុងស្រុក ដោយមានការផ្លាស់ប្តូរឆ្នាំគោល២០០០ មកឆ្នាំ២០១៤។ គិតជាតម្លៃថេរ វិស័យកសិកម្មបានចូលរួមចំណែកប្រមាណ ១៤,២% នៃផលិតផលសរុបក្នុងស្រុក ក្នុងឆ្នាំ២០២៤។

**ក្រាហ្វិកទី១៖ ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិឆ្នាំ២០២០-២០២៤**




ប្រភព៖ ក្រសួងផែនការឆ្នាំ២០២៤ (ទិន្នន័យបឋម)

បើទោះជាការចូលរួមចំណែករបស់វិស័យកសិកម្ម មានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំយ៉ាងនេះក្តី តែតម្លៃបន្ថែមសរុបនៃវិស័យកសិកម្ម (Gross Value Added in Agriculture) មានការកើនឡើងជារៀងរាល់ឆ្នាំពី ១៩ ៨០៥ ពាន់លានរៀល នៅឆ្នាំ២០១៥ ដល់ ២៤ ២៨២ពាន់លានរៀល នៅឆ្នាំ២០២០ និងដល់ ៣១ ២៩២ពាន់លានរៀល នៅឆ្នាំ២០២៤ (គិតជាតម្លៃបច្ចុប្បន្ន)។

### ក្រាហ្វិកទី២៖ កំណើនតម្លៃបន្ថែមសរុបនៃវិស័យកសិកម្ម ២០១៤-២០២៤




ប្រភព៖ ក្រសួងផែនការឆ្នាំ២០២៤ (ទិន្នន័យបឋម)

## ៤.២ កំណើនវិស័យកសិកម្ម

កំណើនវិស័យកសិកម្មមានការប្រែប្រួលជាមធ្យម ក្នុងចន្លោះពី ០,២% ទៅ១,១% ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ (គិតជាតម្លៃថេរ) ដែលបញ្ជាក់ពីការចូលរួមចំណែកជាវិជ្ជមានរបស់វិស័យកសិកម្ម ក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ នៅចន្លោះឆ្នាំ២០២០-២០២៤ វិស័យកសិកម្មកម្ពុជានៅតែរក្សាបាននូវកំណើនវិជ្ជមានក្នុងរង្វង់ ០,៦% ទៅ ០,៨%។

### ក្រាហ្វិកទី៣៖ កំណើនវិស័យកសិកម្ម (តម្លៃថេរ) ឆ្នាំ២០១៥-២០២៤




ប្រភព៖ ក្រសួងផែនការឆ្នាំ២០២៤ (ទិន្នន័យបឋម)

## ៤.៣ ការចូលរួមចំណែករបស់អនុវិស័យនានាក្នុងវិស័យកសិកម្ម

ការចូលរួមចំណែករបស់អនុវិស័យនានា ក្នុងវិស័យកសិកម្ម រួមមាន ផ្នែកដំណាំបានចូលរួមចំណែកប្រមាណ ៦១,៣% ផ្នែកផលិតកម្មសត្វ ១៥,៤% ផ្នែកជលផល ២០% និងផ្នែកព្រៃឈើ ៣,៣%។ ជាការកត់សម្គាល់ ផ្នែកដំណាំ និងជលផល គឺជាកម្លាំងចលករនាំមុខ និងចូលរួមចំណែកច្រើនជាងផ្នែកផ្សេងៗ ក្នុងវិស័យកសិកម្ម ខណៈ

ដែលផលិតកម្មសត្វដើរតួនាទីផ្គត់ផ្គង់តម្រូវការសាច់ក្នុងស្រុក និងបម្រើឱ្យការនាំចេញ ដែលត្រូវបន្តជំរុញអភិវឌ្ឍឱ្យបានខ្លាំងក្លាបន្ថែមទៀត។

**ក្រាហ្វិកទី៤៖ ការចូលរួមចំណែករបស់អនុវិស័យក្នុងនានាវិស័យកសិកម្មឆ្នាំ២០២០-២០២៤**
**(គិតជាតម្លៃបច្ចុប្បន្ន)**




| | 2020 | 2021 | 2022 | 2023 | 2024 |
|---|---|---|---|---|---|
| ដំណាំ | 60.6% | 60.4% | 60.1% | 61.1% | 61.3% |
| បសុសត្វ និងបសុបក្សី | 15.5% | 15.6% | 15.6% | 15.5% | 15.4% |
| ជលផល | 19.9% | 19.9% | 20.2% | 19.8% | 20.0% |
| ព្រៃឈើ | 3.9% | 4.1% | 4.1% | 3.6% | 3.3% |

ប្រភព៖ ក្រសួងផែនការឆ្នាំ២០២៤ (ទិន្នន័យបឋម)

## ៥. លទ្ធផលតាមអនុវិស័យ និងផ្នែកផ្សេងៗ

## ៥.១ ការងារបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិឧស្សាហកម្ម

### ក. ផលិតកម្មដំណាំស្រូវ

ក្នុងទិសដៅរួមចំណែកកាត់បន្ថយថ្លៃដើមផលិត និងបង្កើនប្រាក់ចំណូលជូនប្រជាកសិករ ក្រសួងបានរៀបចំឱ្យមានប្រព័ន្ធផលិតកម្មគ្រាប់ពូជស្រូវជាក់លាក់ដើម្បីធានាបរិមាណ និងគុណភាពស្រូវ-អង្ករសម្រាប់ការប្រើប្រាស់ក្នុងស្រុក និងការនាំចេញ បានរៀបចំឱ្យមានពិសោធន៍ ស្រាវជ្រាវ និងអភិវឌ្ឍពូជ ផ្សព្វផ្សាយបង្ហំបច្ចេកទេសផលិតកម្មដំណាំស្រូវ និងជំរុញកសិករប្រើប្រាស់គ្រាប់ពូជស្រូវសុទ្ធ មានគុណភាពនិងតម្រូវការទីផ្សារ ដូចជា ពូជផ្ការំដួល និងសែនក្រអូប ជាដើម។

ជាក់ស្តែងក្នុងឆ្នាំ២០២៤នេះ ផ្ទៃដីដាំស្រូវសរុបទូទាំងប្រទេសសម្រេចបានចំនួន ៣,៨៦លានហិកតា (ស្រូវប្រាំងចំនួន ០,៨៤លានហិកតា និងស្រូវវស្សាចំនួន ៣,០២លានហិកតា) កើនឡើងចំនួន ៣០៦ ៩៧៣ហិកតា ស្មើនឹង ៨,៦៥% ធៀបឆ្នាំ២០២៣។ ផ្ទៃដីប្រមូលផលបានចំនួន ៣,៨១លានហិកតា កើនឡើងចំនួន ៣០១ ៤១៥ហិកតា ស្មើនឹង ៨,៥៨% ធៀបឆ្នាំ២០២៣។ ផ្ទៃដីដាំដុះកើនឡើងដោយសារកសិករបង្កើនរដូវដាំដុះដោយប្រើប្រាស់ពូជស្រូវស្រាលអាយុកាលខ្លីមិនប្រកាន់រដូវ បានផលចំណេញច្រើនបំពេញតាមតម្រូវការទីផ្សារ និងភាពរីកចម្រើនប្រព័ន្ធស្រោចស្រព។ បរិមាណផលស្រូវសរុបទទួលបានចំនួន ១៣,៨៩លានតោន (ស្រូវប្រាំងចំនួន ៣,៨៤លានតោន និងស្រូវវស្សាចំនួន ១០,០៥លានតោន) កើនឡើងចំនួន ១,៤លានតោន ស្មើនឹង ១១,១៤% ធៀបឆ្នាំ២០២៣។

ទិន្នផលស្រូវជាមធ្យមប្រចាំឆ្នាំសម្រេចបាន ៣,៦៤១តោនក្នុងមួយហិកតា កើនឡើង ៨៤គីឡូក្រាម/ហិកតា ធៀបនឹងឆ្នាំ២០២៣។ តាមការវាយតម្លៃតុល្យភាពស្បៀង កម្ពុជាមានអតិរេកស្រូវចំនួនជាង ៨លានតោន និងគិតជាអង្ករ ៥,២២លានតោន ដែលអាចសន្និដ្ឋានបានថា កម្ពុជាធានាបាននូវសន្តិសុខស្បៀង និងសល់សម្រាប់នាំចេញ។

តាមរយៈយន្តការរក្សាលំនឹងថ្លៃកសិផល បានជួយរក្សានូវលំនឹងថ្លៃកសិផល ដូចជា ប្រភេទស្រូវក្រអូបប្រណិត (ស្រូវផ្ការំដួល) មានតម្លៃចាប់ពី ១ ៥០០ ទៅ ១ ៦០០រៀល/គក្រ ប្រភេទស្រូវក្រអូប (ពូជស្រូវសែនក្រអូប) មានតម្លៃចាប់ពី ១ ២០០ ទៅ ១ ៤០០រៀល/គក្រ ប្រភេទស្រូវអង្ករសមានតម្លៃពី ១ ១០០ ទៅ ១ ២០០រៀល/គក្រ និងប្រភេទស្រូវអ៊ីអែរនិងអូរអឹម មានតម្លៃចាប់ពី  ១ ០០០ ទៅ ១ ១០០រៀល/គក្រ (តម្លៃស្រូវនៅក្នុងស្រែ)។

ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ជាមធ្យមប្រចាំឆ្នាំ ផ្ទៃដីដាំស្រូវកើនឡើងចំនួន ៣,០៧% ផ្ទៃដីប្រមូលផលកើនឡើងចំនួន ៣,៣១% បរិមាណផលស្រូវកើនឡើងចំនួន ៥,១៩% និងទិន្នផលស្រូវកើនឡើងចំនួន ១,៧៨%។

**ក្រាហ្វិកទី៥៖ ផលិតកម្មដំណាំស្រូវឆ្នាំ២០២០-២០២៤**




ទន្ទឹមនឹងនេះ កម្ពុជាបានទទួលរងនូវគ្រោះរាំងស្ងួតចំនួន ២លើក គ្រោះទឹកជំនន់ចំនួន ៣លើក និងការបំផ្លាញពីសត្វល្អិតចង្រៃលើដំណាំចំនួន ១លើក ដែលបណ្តាលឱ្យប៉ះពាល់ដាំណាំសរុបចំនួន ២៦៣ ២០២ហិកតា ខូចខាតសរុបចំនួន ៦៩ ៧០៩ហិកតា (២៦% នៃផ្ទៃដីរងការប៉ះពាល់) ក្នុងនោះ ដំណាំស្រូវប៉ះពាល់ចំនួន ១៩៣ ៩១១ហិកតា ស្មើនឹង ៦,៤% នៃផ្ទៃដីដាំដុះទូទាំងប្រទេស ខូចខាតចំនួន ២៧ ៤៣៨ហិកតា ស្មើនឹង ០,៩១%។ ដោយមានកិច្ចអន្តរាគមន៍ផ្តល់ពូជស្រូវតាមរយៈប្រព័ន្ធស្បៀងបម្រុងកម្ពុជា ផ្ទៃដីប្រមាណជាង ២៩ ០០០ហិកតា ត្រូវបានដាំដុះស្តារឡើងវិញ។

## ខ .ផលិតកម្មដំណាំស្បៀងរួមផ្សំ

ផលិតកម្មដំណាំស្បៀងរួមផ្សំសរុបសម្រេចបាននៅលើផ្ទៃដីចំនួន ៣៤៣ ៦៣៥ហិកតា និងផ្តល់បរិមាណផលចំនួន ៥ ១៥២ ៧៨៩តោន ក្នុងនោះមាន៖

- ផ្ទៃដីដាំដំណាំស្បៀងរួមផ្សំរយៈពេលខ្លី (បន្លែ ដំណាំហូបផ្លែរយៈពេលខ្លី និងរុក្ខជាតិលម្អ) មានចំនួន ៨៤ ៤៥០ហិកតា ថយចុះចំនួន ៦៩៧ហិកតា ធៀបឆ្នាំ២០២៣ ដោយមានផ្ទៃដីប្រមូលផលចំនួន ៨៤ ២៥៧ ហិកតា និងផ្តល់បរិមាណផលសរុបចំនួន ១ ៣៦៨ ៥៣៨តោន លើសឆ្នាំមុនចំនួន ១៣៨ ៦២១តោន។
- ផ្ទៃដីដាំដំណាំស្បៀងរួមផ្សំរយៈពេលវែង (ដំណាំហូបផ្លែរយៈពេលវែង) មានចំនួន ២៥៩ ១៨៤ហិកតា ក្នុងនោះ៖ ដំណាំកំពុងផ្តល់ផលមានចំនួន ២០១ ៩៥៥ហិកតា ផ្តល់បរិមាណផលសរុបចំនួន ៣ ៧៨៤ ២៥០តោន។ ដំណាំស្បៀងរួមផ្សំរយៈពេលវែងសំខាន់ៗ រួមមាន៖
  - ផ្ទៃដីដាំដុះដំណាំចេកមានចំនួន ៥៦ ៨៩៣ហិកតា ផ្តល់បរិមាណផលចំនួន ១ ០០៤ ២៦២តោន ក្នុងនោះ ចេកអំបូងលឿងចំនួន ២១ ៣៤០ហិកតា ផ្តល់បរិមាណផលចំនួន ៣៩៦ ៩៨០តោន
  - ផ្ទៃដីដាំដុះដំណាំស្វាយមានចំនួន ១៥៤ ៩០៨ហិកតា ផ្តល់បរិមាណផលចំនួន ២ ២០១ ៥៦៦តោន

- ផ្ទៃដីដាំដុះដំណាំមៀន/មៀនប៉ៃលិនមានចំនួន ១៤ ២៧២ហិកតា ផ្តល់ផលចំនួន ១៧២ ៤៣៤តោន
- ផ្ទៃដីដាំដុះដំណាំទុរេនមានចំនួន ១១ ២៨៧ហិកតា ផ្តល់ផលចំនួន ១១៨ ៧២៧តោន។

ទន្ទឹមនឹងការទទួលបានលទ្ធផលជាផ្លែផ្កានេះ ផ្ទៃដីដំណាំស្បៀងរួមផ្សំសរុបចំនួន ១ ៤៣៩ហិកតា បានរងការប៉ះពាល់ដោយគ្រោះធម្មជាតិ និងសត្វល្អិតចង្រៃ ដែលធ្វើឱ្យខូចខាតចំនួន ៩៩៧ហិកតា។

ជារួម ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ផ្ទៃដីដំណាំស្បៀងរួមផ្សំ កើនជាមធ្យមប្រចាំឆ្នាំចំនួន ២,៥០% ផ្ទៃដីប្រមូលផលកើន ៥,៦៨% និងបរិមាណផលកើន ១២,២៩%។

**ក្រាហ្វិកទី៦៖ ផលិតកម្មដំណាំស្បៀងរួមផ្សំឆ្នាំ២០២០-២០២៤**




## គ. ផលិតកម្មដំណាំទ្រទ្រង់សេដ្ឋកិច្ច

ផលិតកម្មដំណាំទ្រទ្រង់សេដ្ឋកិច្ចសម្រេចបានលើផ្ទៃដីសរុបចំនួន ១ ៧៩៨ ១៧២ហិកតា ដែលមានផ្ទៃដីប្រមូលផលចំនួន ១ ៦៨២ ១៨៧ហិកតា និងទទួលបានបរិមាណផលចំនួន ២០ ០៥២ ០១៩តោន កើនឡើងចំនួន ១ ០៩១ ៦០៨តោន ស្មើនឹង ៥,៧៦% ធៀបឆ្នាំ២០២៣ ក្នុងនោះ៖

- ផ្ទៃដីផលិតកម្មដំណាំទ្រទ្រង់សេដ្ឋកិច្ចរយៈពេលខ្លីសម្រេចបានចំនួន ១ ០៧៤ ៨១៥ហិកតា ដែលមានផ្ទៃដីប្រមូលផលចំនួន ១ ០២០ ១៤៦ហិកតា និងបរិមាណផលចំនួន ១៦ ៨៧៦ ៣១៨តោន ក្នុងនោះ៖
  - ផ្ទៃដីដាំដុះដំឡូងមីមានសចំនួន ៨០៧ ៩៦០ហិកតា កើនឡើង ១០២ ៥០០ហិកតា ផ្តល់បរិមាណផលសរុបចំនួន ១៥ ៦៨៣ ៩៤៩តោន
  - ផ្ទៃដីដាំដុះពោតក្រហមចំនួន ១៩៧ ៣៦១ហិកតា ថយចុះ ៧៩ ៨១៩ហិកតា ផ្តល់បរិមាណផលចំនួន ៩៩៩ ៤៨៣តោន។
- ផ្ទៃដីដាំដុះដំណាំទ្រទ្រង់សេដ្ឋកិច្ចរយៈពេលវែងសម្រេចបានចំនួន ៧២៣ ៣៥៧ហិកតា និងផ្តល់បរិមាណផលចំនួន ៣ ១៧៥ ៧០១តោន ក្នុងនោះ ដំណាំសំខាន់ៗ រួមមាន៖
  - ផ្ទៃដីដាំដុះស្វាយចន្ទីមានចំនួន ៦៣៣ ៣៤២ហិកតា ផ្តល់បរិមាណផលចំនួន ៨៨៥ ៥៦៥តោន
  - ផ្ទៃដីដាំដុះអំពៅមានចំនួន ៤១ ០៣៨ហិកតា ផ្តល់បរិមាណផលចំនួន ១ ៥៥៥ ៧៥៥តោន
  - ផ្ទៃដីដាំដុះម្រេចមានចំនួន ៧ ១២០ហិកតា ផ្តល់បរិមាណផលចំនួន ២១ ៤៥៦តោន
  - ផ្ទៃដីដាំដុះដូងប្រេងមានចំនួន ២០ ០៤៣ហិកតា ផ្តល់បរិមាណផលចំនួន ៣៥៩ ៥៧២តោន។

ក្នុងឆ្នាំ២០២៤ ផ្ទៃដីដំណាំទ្រទ្រង់សេដ្ឋកិច្ចចំនួន ១៧ ១៨០ហិកតា បានរងការប៉ះពាល់ដោយគ្រោះធម្មជាតិ និងសត្វល្អិតចង្រៃ ដែលធ្វើឱ្យខូចខាតចំនួន ២ ៦៨៣ហិកតា។

ជារួម រយៈពេល៥ឆ្នាំចុងក្រោយនេះ ផ្ទៃដីដាំដុះដំណាំទ្រទ្រង់សេដ្ឋកិច្ច កើនជាមធ្យមប្រចាំឆ្នាំចំនួន ៨,៤៨% ផ្ទៃដីផ្តល់ផលបានកើន ១១,១០% និងបរិមាណផលបានកើន ៧,៣៦%។

**ក្រាហ្វិកទី៧៖ ផលិតកម្មដំណាំទ្រទ្រង់សេដ្ឋកិច្ចឆ្នាំ២០២០-២០២៤**




## ឃ. ផលិតកម្ម និងការគ្រប់គ្រងពូជដំណាំ

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- បានបង្កើតប្រព័ន្ធគ្រាប់ពូជសុទ្ធនិងជំរុញផលិតកម្មស្រូវ ដោយផលិតបានគ្រាប់ពូជស្រូវចុះបញ្ជីសរុបចំនួន ៦៧៥តោន និងគ្រាប់ពូជវិញ្ញាបនបត្រសរុបចំនួន ៧៥២តោន ក្នុងការជំរុញលើកទឹកចិត្តការប្រើប្រាស់ពូជផ្ការំដួល និងសែនក្រអូប០១ សម្រាប់ការនាំចេញអង្ករ។
- ក្នុងក្របខណ្ឌប្រព័ន្ធស្បៀងបម្រុងកម្ពុជា បានផលិតពូជស្រូវចំនួន ២ ៨០០តោន សម្រាប់អន្តរាគមន៍ដាំដុះស្តារឡើងវិញក្រោយពេលទឹកជំនន់
- បានផលិតគ្រាប់ពូជបន្លែនិងដំណាំរួមផ្សំចំនួន ១៦មុខ ស្មើនឹងចំនួន ៥០តោន និងសន្និធិគ្រាប់ពូជបន្លែសល់ពីឆ្នាំ២០២៣ មានចំនួន ៣៧,៨៤តោន សម្រាប់ត្រៀមអន្តរាគមន៍
- គ្រាប់ពូជបន្លែចំនួន ៤០,២៣តោន ត្រូវបានចែកជូនដល់កសិករ សាលារៀន និងស្ថាប័នផ្សេងៗ ដែលមានតម្រូវការដាំដុះ និងសន្និធិគ្រាប់ពូជបន្លែនៅសល់ចំនួន ៤៧,៦១តោន
- បានបញ្ចេញប្រភេទពូជដំណាំចំនួន ៧ប្រភេទ រួមមាន ល្ងស្រមោចស សណ្តែកសៀងស្បង់មាស ពូជស្រូវស្រងៃថ្មី ពូជកៅស៊ូ CRPRI-19 និងCRRI-12 ពូជប៉េងប៉ោះ KK-1711 និងKK-1715។ ក្រៅពីនេះ ចុះបញ្ជីពូជដំណាំបានចំនួន ៣០ប្រភេទពូជ
- បានចុះត្រួតពិនិត្យគុណភាពផលិតកម្មគ្រាប់ពូជស្រូវតាមប្រព័ន្ធធានាគុណភាពពូជដំណាំ (QDS) លើផ្ទៃដីផលិតកម្មសរុបចំនួន ៥៥៥ហិកតា ទទួលបានគ្រាប់ពូជប្រមាណ ២ ០២៦តោន ក្នុងនោះមានពូជស្រូវសែនក្រអូប០១ ចំនួន ១៣២ហិកតា បានគ្រាប់ពូជប្រមាណ ៦៦០តោន និងពូជស្រូវផ្ការំដួលចំនួន ៣៧៥ហិកតា បានគ្រាប់ពូជប្រមាណ ១ ០៨១តោន និងពូជស្រូវOM5451ចំនួន ៤៨ហិកតា បានគ្រាប់ពូជប្រមាណ ២៨៥តោន
- បានប្រមូលសំណាកចំនួន ២០៦ សំណាកលើមុខដំណាំចំនួន ២០ប្រភេទ រួមមាន ពពួកជី (ជីនាងវង ជីរណា និងជីម្រះព្រៅ) សណ្តែកកួរ តាសក់ ននោង ត្រឡាច ល្ពៅ ត្រប់ សណ្តែកបាយ ពពាយ ពោត សណ្តែកព្រៃ

ឱឡឹក ល្ហុ ម្រះ ពោតបារាំង និងពោតសំឡី ព្រមទាំងបានដាំវាយតម្លៃនិងកំណត់លក្ខណៈពូជដំណាំ ៤ប្រភេទ ស្មើនឹង ៩៦សំណាក

- គិតត្រឹមឆ្នាំ២០២៤ ក្រសួងបានអភិរក្សនៅក្នុងធនាគារពន្ធុនូវពូជដំណាំចំនួន ៣៩ប្រភេទស្មើនឹង ៩ ៧៧២បញ្ញើក/សំណាក
- បានធ្វើពិសោធន៍ជ្រើសរើសរកស្រឡាយស្រូវ និងដំណាំផ្សេងៗដែលមានទិន្នផលខ្ពស់ គុណភាពល្អ និងធន់នឹងការប្រែប្រួលអាកាសធាតុចំនួន ១០ប្រភេទ ស្មើនឹង ៧០ពិសោធន៍
- បានបញ្ចេញពូជដំណាំថ្មីចំនួន ៣ប្រភេទឱ្យប្រើប្រាស់ជាផ្លូវការ រួមមាន ស្រូវស្រងៃថ្មី សណ្ដែកសៀងស្បង់មាស និងល្ងស្រមោចស
- គ្រាប់ពូជគ្រឹះ គ្រាប់ពូជចុះបញ្ជី និងគ្រាប់វិញ្ញាបនបត្រ ត្រូវបានផ្គត់ផ្គង់ទៅកសិករ និងគ្រប់អ្នកពាក់ព័ន្ធមានដូចជា ផ្ការំដួល ២១ ៨៧១គ.ក្រ សែនពិដោរ ២១៥គ.ក្រ ដំណើបស្បៃមង្គល ៣១០គ.ក្រ រាំងជ័យ ១០៥គ.ក្រ សែនក្រអូប០១ ២១ ០១២គ.ក្រ ចំប៉ីស៧០ ៤ ១៩៦គ.ក្រ និងស្រងៃថ្មី ៩៨០គ.ក្រ
- បានចុះអង្កេតដីដោយធ្វើការសិក្សាវាយតម្លៃ និងប្រមូលទិន្នន័យលម្អិតអំពីលក្ខណសម្បត្តិនៃដីចំនួន ៩ទីតាំងនៅខេត្តបាត់ដំបង និង ២ទីតាំងនៅខេត្តព្រះវិហារ
- បានធ្វើចំណាត់ថ្នាក់ក្រុមដី និងការផលិតផែនទីក្រុមដាំដុះស្រូវនៅស្រុកថ្មគោល ខេត្តបាត់ដំបង
- បានធ្វើពិសោធន៍បង្ហាញលើស្រែកសិកររដូវប្រាំងស្ដីពីការប្រើប្រាស់ជី NPK លើដំណាំនែថាវនៅលើក្រុមដីខ្សាច់នៅស្រុកឈូក ខេត្តកំពត
- បានធ្វើពិសោធន៍ស្ដីពីឥទ្ធិពលនៃការប្រើប្រាស់ថ្នាំពុលកសិកម្មសរីរាង្គ និងជីបំប៉នលើស្លឹកលើការលូតលាស់ និងទិន្នផលស្រូវស្រាលនៃក្រុមដីប្រទះឡាង
- បានធ្វើពិសោធន៍បង្ហាញលើស្រែកសិករ ស្ដីពីប្រសិទ្ធភាពនៃវិធីសាស្ត្រគ្រប់គ្រងស្មៅលើដំណាំស្រូវដើមរដូវវស្សាចំនួន ៤កន្លែង នៅភូមិគក និងភូមិភ្នំគង់ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង
- បានធ្វើការពង្រីកដំណាំដំឡូងមីតាមរយៈជាលិកាវប្បកម្មបានចំនួន ៩២០៦កូន ព្រមទាំងបានយកទៅដាំនៅទីវាលសម្រាប់ប្រើប្រាស់ជាពូជមេ ដើម្បីបម្រើឱ្យការផលិតពូជដំឡូងមីស្អាតនៅសហគមន៍កសិកម្ម
- បានធ្វើការវិភាគសំណាកដីលើប៉ារ៉ាម៉ែត្រសំខាន់ៗមួយចំនួនដូចជាប៉េហាស់(pH) ១៦៧សំណាក និងបានធ្វើវិភាគលើសំណាកទឹកចំនួន២ប៉ារ៉ាម៉ែត្រគឺប៉េហាស់(pH) ២៤សំណាក ភាពចម្លងអគ្គិសនី(EC) ២៤សំណាក
- បានធ្វើទិវាស្រែ/ចម្ការបង្ហាញ និងសាលារៀនស្រែកសិករចំនួន ១៨លើក កសិករចូលរួមចំនួន ១ ១២១នាក់ ស្ត្រី ៣៤៣នាក់ និងបានរៀបចំវគ្គបណ្ដុះបណ្ដាលជំនាញចំនួន ៤លើកមានសិក្ខាកាមចូលរួម ១១៤នាក់ ស្ត្រី ៣០នាក់
- បានផ្ដល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាប្រភេទពូជដំណាំចំនួន ១០៨ច្បាប់ ស្មើនឹង ១០៥ប្រភេទ វិញ្ញាបនបត្របញ្ជាក់គុណភាពប្រភេទពូជដំណាំចំនួន ១៧៤ច្បាប់ ស្មើនឹង ១៧១ប្រភេទ លិខិតអនុញ្ញាតនាំចូលពូជដំណាំចំនួន ១៥ច្បាប់ ជូនក្រុមហ៊ុនចំនួន ១២ និងកសិដ្ឋានចំនួន១ ស្មើនឹង ១៨៨ប្រភេទ និងផ្ដល់លិខិតធ្វើអាជីវកម្មផលិតនិងកែច្នៃពូជដំណាំចំនួន ៧ច្បាប់ ស្មើនឹង ៧ក្រុមហ៊ុន។

## ង. ការបង្កើត និងចុះបញ្ជីសហគមន៍កសិកម្ម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននិងកំពុងយកចិត្តទុកខ្ពស់ក្នុងការអភិវឌ្ឍសហគមន៍កសិកម្ម ដើម្បីផ្ដល់ការគាំទ្របន្ថែមដល់កសិករខ្នាតតូចនិងមធ្យម សំដៅចូលរួមដោះស្រាយបញ្ហាប្រឈមនៅក្នុងប្រព័ន្ធផលិតកម្មកសិកម្ម និងលើកកម្ពស់អំណាចចរចាទីផ្សាររបស់ប្រជាកសិករ។ គិតត្រឹមឆ្នាំ២០២៤នេះ សហគមន៍កសិកម្មសរុបចំនួន ១ ៤៧៥ ត្រូវបានបង្កើតទូទាំងប្រទេស។

### ក្រាហ្វិកទី៨៖ ចំនួនសហគមន៍កសិកម្មតាមបណ្តាខេត្តឆ្នាំ ២០២៤




### ច .ការងារអភិវឌ្ឍន៍សហគមន៍កសិកម្មទំនើប

ការកសាងសហគមន៍កសិកម្មទំនើប គឺដើម្បីប្រែក្លាយវិស័យកសិកម្មពីលក្ខណៈគ្រួសារទៅជាសហគ្រាសសេដ្ឋកិច្ចដ៏រឹងមាំ មានសមារណកម្មខ្ពស់ មានសេដ្ឋកិច្ចមាត្រដ្ឋាន និងមានសមត្ថភាពប្រកួតប្រជែងទាំងបរិមាណនិងគុណភាព។

**១. ការបង្កើតសហគមន៍កសិកម្មទំនើប**

បានបង្កើតសហគមន៍កសិកម្មទំនើបចំនួន៩សហគមន៍ ក្នុងខេត្តចំនួន៦ ផ្តោតលើដំណាំសំខាន់ៗចំនួន៤ប្រភេទ គឺដំណាំស្រូវ ស្វាយចន្ទី បន្លែ និងដំណាំម្រេច ដែលគ្រប់ដណ្តប់លើផ្ទៃដីដាំដុះសរុបប្រមាណ ២ ០០០ហិកតា និងមានកសិករចូលរួមចំនួន ៦៥៧គ្រួសារ។ សហគមន៍កសិកម្មទំនើបចំនួន៥ ដែលមានផែនការពង្រីកអាជីវកម្មច្បាស់លាស់ បានទទួលការគាំទ្រហិរញ្ញប្បទានពីធនាគារវីង និងធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម ក្នុងអត្រាការប្រាក់ទាប។

**២. ការគាំទ្រសហគមន៍កសិកម្មទំនើប**

ដើម្បីជួយគាំទ្រដល់សហគមន៍កសិកម្មទំនើប ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើតក្រុមការងារគាំទ្របច្ចេកទេសគាំទ្រសហគមន៍កសិកម្មទំនើបចំនួន ៤ក្រុម គឺក្រុមការងារគាំទ្របច្ចេកទេសសហគមន៍កសិកម្មទំនើបម្រេច ស្វាយចន្ទី ដំណាំស្រូវ និងដំណាំបន្លែផ្ទះកញ្ចក់ត្រាំកក់ ព្រមទាំងបានចុះគាំទ្រដល់បច្ចេកទេសជាបន្តបន្ទាប់ ដែលរួមមាន ការផ្តល់ប្រឹក្សាបច្ចេកទេសអំពីការប្រើប្រាស់ជីនិងថ្នាំកសិកម្មតាមដំណាក់កាលនៃដំណាំ ការគាំទ្រក្នុងការសិក្សាអំពីប្រភេទដី និងវិភាគសំណាកដី និងការណែនាំបច្ចេកទេសការពារនិងកម្ចាត់សមាសភាពចង្រៃ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើការសម្របសម្រួលជាមួយស្ថាប័នហិរញ្ញវត្ថុដៃគូ ដើម្បីស្វែងរកប្រាក់កម្ចីដើមទុនដែលមានអត្រាការប្រាក់ទាបនិងមិនតម្រូវឱ្យមានទ្រព្យបញ្ចាំ។ ជាលទ្ធផល សហគមន៍កសិកម្មទំនើបចំនួន៥ ទទួលបានប្រាក់កម្ចីពីធនាគារវីង (Wing Bank) និងធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម (ARDB) សរុបជាទឹកប្រាក់ចំនួនប្រមាណ ៨៥៥ ០០០ដុល្លារអាមេរិក ក្នុងអត្រាការប្រាក់ ៧% ក្នុងមួយឆ្នាំ ហើយគ្រោងនឹងស្នើសុំកម្ចីឥណទានបន្ថែមសរុបជិត ៣លានដុល្លារអាមេរិក។

ដើម្បីបង្កើនការគាំទ្រដល់ការអភិវឌ្ឍសហគមន៍កសិកម្មទំនើប ក្រសួងក៏បានពង្រីកកិច្ចសហការជាមួយដៃគូពាក់ព័ន្ធជាច្រើន ក្នុងនោះ បានចុះអនុស្សរណៈយោគយល់គ្នាជាមួយស្ថាប័នមួយចំនួន ដូចខាងក្រោម៖

- ធនាគារវីង៖ ដើម្បីផ្តល់កម្ចីឥណទានការប្រាក់ទាប ក្នុងទំហំទឹកប្រាក់ ៥លានដុល្លារអាមេរិក។

- សហគ្រិនខ្មែរ (Khmer Enterprise)៖ ដើម្បីសហការលើការជួយគាំទ្រខាងផ្នែកសហគ្រិនភាព និងការគ្រប់គ្រងដល់សហគមន៍កសិកម្មទំនើប។
- សាជីវកម្មធានាឥណទានកម្ពុជា (CGCC)៖ ដើម្បីផ្តល់សេវាធានាឥណទានដល់សហគមន៍កសិកម្មទំនើបក្នុងការទទួលបានកម្ចីឥណទានដោយមិនចាំបាច់មានទ្រព្យបញ្ចាំ។
- ក្រុមហ៊ុនបៃតងកម្ពុជា៖ ដើម្បីធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យា ទិញលក់ស្រូវសែនក្រអូបជាមួយសហគមន៍កសិកម្មទំនើប ក្នុងបរិមាណ ៥០ ០០០តោន និងតម្លៃក្នុងរង្វង់ ១៤០០រៀល/គ.ក។

ដើម្បីកាត់បន្ថយថ្លៃដើមផលិតកម្មនិងបង្កើនសមត្ថភាពប្រកួតប្រជែងរបស់សហគមន៍កសិកម្មទំនើប ក្រសួងបានដឹកនាំការសម្របសម្រួលជាមួយសហគមន៍ និងចរចាថ្លៃដោយផ្ទាល់ជាមួយក្រុមហ៊ុនផ្គត់ផ្គង់ធាតុចូលកសិកម្ម។ ជាលទ្ធផល សហគមន៍កសិកម្មទាំងអស់ដែលបានចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួនអាចមានលទ្ធភាពអាចទិញជី និងថ្នាំកសិកម្មសម្រាប់ផលិតកម្ម ក្នុងតម្លៃទាបជាងតម្លៃដែលសមាជិកនីមួយៗទិញរៀងៗខ្លួនពី ១៥% ទៅ ២០%។

លើសពីនេះ ក្រសួងក៏បានកៀរគរធនធានពីប្រភពផ្សេងៗជួយដល់សហគមន៍កសិកម្មទំនើប ក្នុងដំណាក់កាលដំបូង ដោយបានសម្របសម្រួលស្វែងរកដៃគូពាក់ព័ន្ធនិងគម្រោងជាច្រើនដូចជា កិច្ចសហប្រតិបត្តិការ "ត្រីវិស័យ ទឹក កសិកម្ម ជនបទ" កម្មវិធី ASPIRE-AT គម្រោង CAPRED គម្រោង CASDP គម្រោង ACSEP គម្រោង PEARL-PCRL និងគម្រោង DGRV ជាដើម។

## ឆ. ការលើកកម្ពស់គុណភាព សុវត្ថិភាព និងការនាំចេញផលិតផលដំណាំកសិកម្ម

ក្នុងការលើកកម្ពស់គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម ក្រសួងបានចុះបញ្ជីចម្ការដំណាំបន្លែ និងដំណាំហូបផ្លែស្តីពីស្តង់ដានៃការអនុវត្តកសិកម្មល្អកម្ពុជា (CamGAP) ចំនួន ៤១១ចម្ការ ដើម្បីធានាសុវត្ថិភាពនិងគុណភាពសម្រាប់ប្រើប្រាស់ក្នុងស្រុកនិងការនាំចេញ ដោយបង្កើតឱ្យមានប្រព័ន្ធ QR Code ដើម្បីបញ្ជាក់និងតាមដានគុណភាពផលិតផលបន្លែនិងផ្លែឈើស្រស់នៅលើទីផ្សារ។ ព្រមជាមួយគ្នានេះបានរៀបចំស្លាកសញ្ញាជាតិស្តីពីស្តង់ដារនៃការអនុវត្តកសិកម្មល្អកម្ពុជា (CamGAP Logo Sticker) សម្រាប់បិទនៅលើផលិតផលផ្លែឈើនិងបន្លែស្រស់ដែលបញ្ជាក់ផលិតផលកសិកម្មនៃការអនុវត្តកសិកម្មល្អកម្ពុជា (CamGAP) និងមានបំពាក់ប្រព័ន្ធ QR Code ចំនួន ១៩ ៨៩០ សម្រាប់ក្រុមហ៊ុន (១) Eco-Agri Co,.ltd (EAC) (២) ក្រុមហ៊ុនមាសបៃតង (៣) ក្រុមហ៊ុនប្រសិទ្ធហ្វាម (៤) DPK PRASAT FARM និង(៥) មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបន្ទាយមានជ័យ។ ជារួម គិតពីឆ្នាំ ២០១៨ ដល់ឆ្នាំ២០២៤ ការចុះបញ្ជីចម្ការនៃស្តង់ដានៃការអនុវត្តកសិកម្មល្អកម្ពុជាបានសរុបចំនួន ១ ៣៥៧ចម្ការ ក្នុង ២៤ រាជធានី-ខេត្ត លើមុខដំណាំចំនួន ១៣ប្រភេទ។

ក្នុងឆ្នាំ២០២៤នេះ ក្រសួងបានអនុវត្តសកម្មភាពចុះបញ្ជីជាចម្ការ ឬកសិដ្ឋានដំណាំបន្លែ និងឈើហូបផ្លែ ស្តីពីកសិកម្មសរីរាង្គកម្ពុជា (CamORG) ជូនកសិករ សហគមន៍អភិវឌ្ឍន៍កសិកម្ម និងក្រុមហ៊ុន ដោយក្នុងនោះ បានទទួលពាក្យស្នើសុំចុះវាយតម្លៃជាចម្ការកសិកម្មសរីរាង្គកម្ពុជា (CamORG) ចំនួន ១៥លិខិត បានចុះបញ្ជីជាចម្ការកសិកម្មសរីរាង្គកម្ពុជាចំនួន ៦ចម្ការ និងបាននិងកំពុងអនុវត្តតាមនិតិវិធីចុះបញ្ជីជាចម្ការកសិកម្មសរីរាង្គកម្ពុជាចំនួន ៩ចម្ការបន្ថែមទៀត។

ការនាំចេញកសិផលផ្លូវការផ្អែកលើប្រព័ន្ធទិន្នន័យគ្រឹះភូតគាមអនាម័យជាតិ មានចំនួន ១២២ មុខ ទៅកាន់ ៨៧ទិសដៅ ដែលមានបរិមាណកសិផលសរុបចំនួន ១២ ០០២ ៣០០តោន ក្នុងនោះ អង្ករចំនួន៦៤៥ ៨៧២តោន ស្រូវចំនួន៤ ៦០៨ ៥៧៤តោន និងកសិផលក្រៅពីស្រូវ-អង្ករចំនួន ៦ ៧៤៧ ៨៥៥តោន។ ជារួម ការនាំចេញកសិផលកើនឡើងចំនួន ៤២% បើធៀបនឹងឆ្នាំ២០២៣។

### ក្រាហ្វិកទី៩៖ ការនាំចេញផលិតផលកសិកម្មឆ្នាំ២០២០-២០២៤




ឆ. ការគ្រប់គ្រងធាតុចូលកសិកម្ម

**១. ការគ្រប់គ្រងថ្នាំកសិកម្ម**

ឆ្នាំ២០២៤ ក្រសួងបាន (១) បានទទួលសំណើសុំចុះបញ្ជិកាថ្នាំកសិកម្មពីក្រុមហ៊ុនលក់ថ្នាំកសិកម្ម និងចែកចាយសម្ភារៈកសិកម្ម បានចំនួន ១២៧ ក្រុមហ៊ុន ដែលសរុបចំនួន ២ ១៣៥ មុខ (២) បានទទួលសំណើសុំនាំចូលថ្នាំកសិកម្មពីក្រុមហ៊ុនលក់ថ្នាំកសិកម្មចំនួន ១៤៥ក្រុមហ៊ុន ដែលមានចំនួន ០៥ប្រភេទ ស្មើនឹង ៤ ២៣៧យថាប្រភេទ ដែលមានបរិមាណសរុបចំនួន ១៣៦ ០៩៤,៩៧តោន និង(៣) បានទទួលសំណើសុំពិសោធន៍ជីវប្រសិទ្ធភាពថ្នាំកសិកម្មនៅទីវាលពីក្រុមហ៊ុនលក់ចែកចាយសម្ភារ និងថ្នាំកសិកម្ម និងបាននិងកំពុងធ្វើពិសោធន៍លើថ្នាំកសិកម្មសរុបចំនួន ១ ៣៩៨មុខ។

**២. ការគ្រប់គ្រងជីកសិកម្ម**

បរិមាណជីកសិកម្មដែលបាននាំចូលក្នុងព្រះរាជាណាចក្រកម្ពុជាមានបរិមាណសរុបចំនួន ១ ៧៦៥ ៤៧៦តោន ចែកចេញជា ៥ប្រភេទ រួមមាន៖ ជីគីមី ចំនួន ១ ២៩២ ៦៦១តោន ជីសរីរាង្គ ចំនួន ៤៥៤ ៥៨៥តោន ជីកែលម្អដី ចំនួន ៧ ១០០តោន វត្ថុធាតុដើមជី ចំនួន ៤ ៦៧០តោន និងជីជីវសាស្ត្រ ចំនួន ៦ ៤៦០តោន។

ក្នុងឆ្នាំ២០២៤ តម្លៃជីកសិកម្មមានការថយចុះ ធៀបជាមួយឆ្នាំ២០២៣។ តាមរយៈការសង្កេតបានឱ្យឃើញថា តម្លៃជី DAP (18-46-0) បានធ្លាក់ចុះពី ៣៩,៥៤ដុល្លារអាមេរិក/បាវ (១បាវស្មើនឹង ៥០គ.ក្រ) មកត្រឹម ៣៦,៣៨ដុល្លារអាមេរិក/បាវ តម្លៃជីអ៊ុយរ៉េ (46-0-0) បានធ្លាក់ចុះពី ៣៨,៧៣ដុល្លារអាមេរិក/បាវ មកត្រឹម ២៩,៧ដុល្លារអាមេរិក/បាវ តម្លៃជី NPK (15-15-15) បានធ្លាក់ចុះពី ៣៨,៧១ដុល្លារអាមេរិក/បាវ មកត្រឹម ៣៥,២៩ដុល្លារអាមេរិក/បាវ ចំណែកតម្លៃជី Kali/KCl (0-0-60) បានធ្លាក់ចុះពី ៣៦,៧៥ដុល្លារអាមេរិក/បាវ មកត្រឹម ៣២,៣១ដុល្លារអាមេរិក/បាវ។

ក្រៅពីនេះ ក្រសួងបាន (១) ចុះពិនិត្យ និងពង្រឹងការធ្វើអាជីវកម្មជីកសិកម្មចំនួន ៤ខេត្តគោលដៅ (២) ចុះវាយតម្លៃទីតាំងឃ្លាំងសន្និធិជីកសិកម្មចំនួន ៧៨ក្រុមហ៊ុន (៣) ចុះវាយតម្លៃទីតាំងលាយផ្សំនិងវេចខ្ចប់ជាថ្មីជីកសិកម្មចំនួន ២១ក្រុមហ៊ុន (៤) ចុះធ្វើអធិការកិច្ចត្រួតពិនិត្យការធ្វើអាជីវកម្មជីកសិកម្មតាមបណ្ដាខេត្តចំនួន ២០ ស្មើនឹង ៣៧លើក និងបានចុះធ្វើអធិការកិច្ចជាក់ស្ដែងតាមដេប៉ូលក់ជីកសិកម្មចំនួន ៧០ដេប៉ូ (៥) ចុះបណ្ដុះបណ្ដាលអប់រំសមត្ថភាពវិជ្ជាជីវៈស្ដីពីបទដ្ឋានគតិយុត្តនីតិវិធី និងវិធានបច្ចេកទេសសម្រាប់ការធ្វើអាជីវកម្មថ្នាំកសិកម្មនិងជីកសិកម្ម នៅខេត្តចំនួន ៧ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ៨៦៤នាក់ (៨) ចុះយកសំណាកជីកសិកម្មដែលដាក់លក់នៅតាមបណ្ដាដេប៉ូនានាក្នុងខេត្តចំនួន ១៧ខេត្ត បានចំនួន ៣២០សំណាក ក្នុងគោលបំណងពង្រឹងគុណភាព ប្រសិទ្ធភាព បមាណីយជីកសិកម្មដែលធ្វើអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា។

ជាមួយគ្នានេះ ក្រសួងបានចុះផ្សព្វផ្សាយ និងពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ និងអធិការកិច្ចពូជដំណាំក្រុមហ៊ុន ដេប៉ូនិងតូបលក់ពូជដំណាំសរុបបានចំនួន ២៦៧ទីតាំង ក្នុងខេត្តចំនួន ១០។ លើសពីនេះ ក្រសួងបានសហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ចុះសិក្សាករណីដុតបំផ្លាញពូជពោតចំនួន ៧៧១ការ៉ុង ដែលដេប៉ូអាជីវកម្មពូជដំណាំបានក្លែងបន្លំពាណិជ្ជសញ្ញា។

## ឈ. ការងារអភិវឌ្ឍន៍កសិ-ឧស្សាហកម្ម

### ១. ការរៀបចំវគ្គបណ្តុះបណ្តាលការអភិវឌ្ឍន៍កសិ-ឧស្សាហកម្ម

ក្រសួងបានបណ្តុះបណ្តាលដល់អ្នកស្រាវជ្រាវ សិស្ស-និស្សិត សហគ្រាស អ្នកកែច្នៃ អ្នកផលិត និងពាណិជ្ជករ ដែលមានអ្នកចូលរួមសរុប ២ ៤១០នាក់ លើប្រធានបទ បច្ចេកវិទ្យានិងនវានុវត្តកសិផលិតផល បច្ចេកទេសក្រោយពេលប្រមូលផលនិងស្តុកទុក បច្ចេកទេសកែច្នៃកសិផលិតផល បច្ចេកទេសវេចខ្ចប់ ស្លាកសញ្ញាសំបកវេចខ្ចប់និងអាយុកាលផលិតផលកសិកម្មនិងចំណីអាហារ ការធ្វើផែនការអាជីវកម្មកសិផលិតផល វិធីសាស្ត្រអភិវឌ្ឍន៍ផលិតផលអាហារ ការប្រើប្រាស់សារធាតុការពារនិងវិធីសាស្ត្រថែរក្សាគុណភាពចំណីអាហារ ការធានាគុណភាពអាហារ ការគ្រប់គ្រងប្រព័ន្ធសុវត្ថិភាពអាហារ ការអនុវត្តសុវត្ថិភាពក្នុងមន្ទីរពិសោធន៍ ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពកសិផលិតផល និងចំណីអាហារ។ លើសពីនេះទៀត នាយកដ្ឋានកសិ-ឧស្សាហកម្ម បានបណ្តុះបណ្តាល បានចំនួន ៨១១នាក់ ក្រោមការគាំទ្រពីគម្រោង និងដៃគូអភិវឌ្ឍន៍។

### ២. ការពិសោធន៍ ស្រាវជ្រាវ និងចងក្រងឯកសារបច្ចេកទេស

ក្រសួងបានពិសោធន៍ ស្រាវជ្រាវ និងចងក្រងឯកសារបច្ចេកទេសកសិ-ឧស្សាហកម្ម រួមមាន (១) សៀវភៅស្តីពីបច្ចេកទេសកែច្នៃផលិតផលពីផ្លែនិងគ្រាប់ស្វាយចន្ទី (២) សៀវភៅស្តីពី បច្ចេកទេសក្រោយពេលប្រមូលផល និងស្តង់ដារគ្រាប់ស្វាយចន្ទី (៣) សៀវភៅណែនាំស្តីពី ផែនការកសិពាណិជ្ជកម្ម (៤) សៀវភៅស្តីពី ការអនុវត្តន៍ផលិតកម្មកសិកម្មតាមកិច្ចសន្យា (៥) នីតិវិធី និងបែបបទនៃការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាព សុវត្ថិភាព ផលិតផលកសិកម្ម និងចំណីអាហារ និង(៦) បានធ្វើម៉ាស៊ីនសម្រាប់បកគ្រាប់ស្វាយចន្ទី។

### ៣. ផលិតកម្មកសិកម្មតាមកិច្ចសន្យា

ការអនុវត្តផលិតកម្មកសិកម្មកិច្ចសន្យាក្នុងឆ្នាំ ២០២៤ សរុបចំនួន ៣០១កិច្ចសន្យា ដែលមាន ១៥៨ សហគមន៍ ៨២ ក្រុមកសិករនិងបណ្តុំអាជីវកម្ម បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនចំនួន ៧១ក្រុមហ៊ុន សរុបកសិករចូលរួមចំនួន ១៥ ០៦៥គ្រួសារ លើផ្ទៃដីសរុប ២៦ ៧៧៥,៤៦ហិកតា ក្នុងបរិមាណសរុបចំនួន ១ ៤៣៧ ៩០៣,០២តោន ១ ១០១ ៦០០គ្រាប់ និង ៥៩៥ ២០០លីត្រ។ ការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាលើប្រភេទផលិតផលកសិកម្មនិងចំនួនកិច្ចសន្យាមានបង្ហាលម្អិតដូចតារាងទី១។

**ក្រាហ្វិកទី១០៖ ការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាតាមបណ្តារាជធានី/ខេត្ត**



**៤. ការគ្រប់គ្រងគុណភាព និងសុវត្ថិភាពផលនិងផលិតផលកសិ-ឧស្សាហកម្ម**

ក្រសួងបានចូលរួមជួយផ្តល់ និងសម្របសម្រួលបច្ចេកទេសដល់សិប្បកម្មកែច្នៃផលិត ផលកសិកម្ម ដើម្បីទទួលបានវិញ្ញាបនបត្រគុណភាព សុវត្ថិភាពបានចំនួន ៣វិញ្ញាបនបត្រ រួមមាន (១)វិញ្ញាបនបត្រការអនុវត្តអនាម័យល្អ (GHP) (២)វិញ្ញាបនបត្រការគ្រប់គ្រងប្រព័ន្ធសុវត្ថិភាពចំណីអាហារ(HACCP) និង(៣)វិញ្ញាបនបត្រស្តង់ដារការកែច្នៃសរីរាង្គ(JAS Organic, NOP, EOS)។ លើសពីនេះ ក្រសួងបានវិភាគគុណភាព សុវត្ថិភាព និងអាហារូបត្ថម្ភ នៅក្នុងផលនិងផលិតផលកសិ-ឧស្សាហកម្ម បានចំនួន ១៥២សំណាក លើផ្នែករូបនិងគីមីសាស្ត្រ ផ្នែកមីក្រូជីវសាស្ត្រ និងអាហារូបត្ថម្ភ។

**៥. ការប្រឡងប្រជែងអ្នកកែច្នៃគ្រាប់ស្វាយចន្ទីឆ្អើម**

ក្នុងឆ្នាំ២០២៤ ក្រសួងបានបានរៀបចំព្រឹត្តិការណ៍ប្រឡងប្រជែងអ្នកកែច្នៃគ្រាប់ស្វាយចន្ទីឆ្អើមដែលមានអ្នកចូលរួមចំនួន ១៧៧នាក់ ក្នុងនោះមានចូលរួមអ្នកប្រឡងប្រជែងជាសិប្បករកែច្នៃចំនួន ៣០នាក់ ដែលធ្វើឡើងជាបីដំណាក់កាល។ ជ័យលាភីបានទៅលើសិប្បកម្មកែច្នៃគ្រាប់ស្វាយចន្ទីចំនួន ២ និងសហគ្រាសកែច្នៃគ្រាប់ស្វាយចន្ទីចំនួន ១ ដោយឡែកក្រុមហ៊ុនចំនួន ៥ ទទួលបានពានរង្វាន់កិត្តិយស។

## ៥.២ ការបង្កើនផលិតភាពដំណាំកៅស៊ូ

**១. ផ្ទៃដីដាំដុះកៅស៊ូ**

ផ្ទៃដីកៅស៊ូកម្ពុជាសរុបមានចំនួន ៤២៥ ៤៤៣ហិកតា កើនឡើង ១៨ ២៧១ហិកតា ស្មើនឹង ៤,៥% ធៀបឆ្នាំ២០២៣ ក្នុងនោះផ្ទៃដីកៅស៊ូកសិ-ឧស្សាហកម្មចំនួន ២២៣ ១២២ហិកតា (៥២%) និងផ្ទៃដីកៅស៊ូគ្រួសារចំនួន ២០២ ៣២១ហិកតា (៤៨%)។

**ក្រាហ្វិកទី១១៖ ប្រភេទផ្ទៃដីចម្ការកៅស៊ូឆ្នាំ២០២០-២០២៤**




**២. ការងារផលិតកម្មកៅស៊ូ**

ផ្ទៃដីកៅស៊ូយកផលមានចំនួន ៣៣០ ៣៥៩ហិកតា កើនឡើងចំនួន ១០ ១៧៥ហិកតា ស្មើនឹង៣,២% ធៀបឆ្នាំ២០២៣ ដោយសារកៅស៊ូដល់អាយុផ្តល់ផល(បើកមុខចៀរថ្មី)។ ផលិតផលកៅស៊ូសម្រេចបានចំនួន ៤០៧ ២០៩តោន កើនឡើងចំនួន ១៥ ៤០៩តោន ស្មើនឹង ៣,៩% ធៀបឆ្នាំ២០២៣។ ទិន្នផលមធ្យមចំនួន ១ ២៣៣គ.ក្រ/ហ.ត/ឆ្នាំ កើនឡើងចំនួន ៥គ.ក្រ ស្មើនឹង០,៤% ធៀបឆ្នាំ២០២៣។

**ក្រាហ្វិកទី១២៖ ផ្ទៃដីចៀរជ័រ ថែទាំ និងផ្ទៃដីសរុបនៃដំណាំកៅស៊ូ ឆ្នាំ២០២០-២០២៤**




**៣. ការងារធុរកិច្ចកៅស៊ូ**

ក្នុងឆ្នាំ២០២៤ ចំណូលសរុបទទួលបានពីការលក់ផលិតផលកៅស៊ូមានប្រមាណចំនួន ៦៧១,៦៨លានដុល្លារអាមេរិក កើនឡើងប្រមាណចំនួន ១៥០,៣លានដុល្លាអាមេរិក ស្មើនឹង ៣៦,៤៨% ធៀបឆ្នាំ២០២៣ ក្នុងនោះរួមមាន៖ (១)ការនាំចេញកៅស៊ូ សម្រេចបានចំនួន ៣៣៨ ០០០តោន គិតជាទឹកប្រាក់ប្រមាណចំនួន ៦៦៦,៣លានដុល្លារអាមេរិក ថយចុះចំនួន ៣០ ០៤៨តោន ស្មើនឹង -៨,២% និងប្រាក់ចំណូលពីការនាំចេញកៅស៊ូកើនឡើងប្រមាណចំនួន ១៧៤,៣លានដុល្លារអាមេរិក ស្មើនឹង ៣៥,៤% ធៀបឆ្នាំ២០២៣ (២)ការនាំចេញឈើកៅស៊ូមានចំនួន ២៥ ១៥៧ម៉ែត្រគូប គិតជាទឹកប្រាក់ប្រមាណចំនួន ៥,៤លានដុល្លារអាមេរិក បានកើនឡើង ១៥ ៧៤៦ម៉ែត្រគូប និងទឹកប្រាក់កើនឡើងចំនួន ៣,៨លានដុល្លារអាម៉េរិក ស្មើនឹង២៤០,៦% ធៀបនឹងឆ្នាំ២០២៣ និង(៣)ការប្រើប្រាស់ផលិតផលកៅស៊ូក្នុងស្រុកចំនួន ៥៨ ០០០តោន គិតជាទឹកប្រាក់ប្រមាណចំនួន ១១៤,៣លានដុល្លារអាមេរិក បានកើនឡើងចំនួន ២៧ ៥៤៨ម៉ែត្រគូប និងទឹកប្រាក់កើនឡើងចំនួន ៥០,៧លានដុល្លាអាមេរិក ស្មើនឹង១១១% ធៀបនឹងឆ្នាំ២០២៣។

ថ្លៃលក់កៅស៊ូជាមធ្យម ១ ៩៧១ដុល្លារអាមេរិក/តោន កើនឡើង ៦៣៤ដុល្លារអាមេរិក/តោន ស្មើនឹង ៤៧% ធៀបឆ្នាំ២០២៣។ ថ្លៃលក់ឈើកៅស៊ូជាមធ្យម ២១៦ដុល្លារអាមេរិក/ម៉ែត្រគូប កើនឡើង ៤៦ដុល្លារអាមេរិកក្នុងមួយម៉ែត្រគូប ស្មើនឹង២៧,៤% ធៀបឆ្នាំ២០២៣។

**ក្រាហ្វិកទី១៣៖ ផលិតកម្ម និងការនាំចេញកៅស៊ូ ឆ្នាំ២០២០-២០២៤**



គិតត្រឹមឆ្នាំ២០២៤ កម្ពុជាមានរោងចក្រសិប្បកម្មកែច្នៃកៅស៊ូ និងឈើកៅស៊ូចំនួនសរុប ១៧៩កន្លែង កើនឡើងចំនួន ៦កន្លែង ធៀបឆ្នាំ២០២៣ ក្នុងនោះរោងចក្រកែច្នៃកៅស៊ូធម្មជាតិបញ្ជាក់តាមលក្ខណៈបច្ចេកទេស (TSR: TECHNICALLY SPECIFIED RUBBER) ចំនួន ៥៦កន្លែង រោងចក្រកែច្នៃទឹកជ័រខាប់ (CL: CONCENTRATED LATEX) ចំនួន១កន្លែង សិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយមានផ្សែង (RSS: RIBBED SMOKED SHEET) និងសិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយខ្យល់ក្តៅ (ADS: AIR-DRIED SHEET) មានចំនួន ១០១កន្លែង និងរោងចក្រកែច្នៃឈើកៅស៊ូ (RWF: RUBBER WOOD FACTORY) ចំនួន ២១កន្លែង។ បច្ចុប្បន្ននេះ រោងចក្រសិប្បកម្មកែច្នៃកៅស៊ូ និងឈើកៅស៊ូកំពុងដំណើរការសរុបចំនួន ៦២កន្លែង។ រោងចក្រ និងសិប្បកម្មសរុបចំនួន ១១៧កន្លែង បានផ្អាកដំណើរការ ស្មើនឹង៦៥% ក្នុងនោះរោងចក្រកែច្នៃកៅស៊ូធម្មជាតិបញ្ជាក់តាមលក្ខណៈបច្ចេកទេស (TSR: TECHNICALLY SPECIFIED RUBBER) ចំនួន១៩កន្លែង រោងចក្រកែច្នៃទឹកជ័រខាប់ (CL: CONCENTRATED LATEX) ចំនួន១កន្លែង សិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយមានផ្សែង (RSS: RIBBED SMOKED SHEET) និងសិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយខ្យល់ក្តៅ (ADS: AIR-DRIED SHEET) មានចំនួន ៨៦កន្លែង និងរោងចក្រកែច្នៃឈើកៅស៊ូ (RWF: RUBBER WOOD FACTORY) ចំនួន១១កន្លែង។ ការផ្អាកដំណើរការនេះ ដោយសារខ្វះវត្ថុធាតុដើម ខ្វះទុនបម្រុង ថ្លៃដើមផលិតខ្ពស់ ផលិតផលមិនបំពេញតម្រូវការទីផ្សារ និងប្រព័ន្ធផលិតកម្មកែច្នៃមិនទាន់ល្អប្រសើរ។

**ក្រាហ្វិកទី១៤៖ រោងចក្រ សិប្បកម្មកែច្នៃកៅស៊ូ និងឈើកៅស៊ូឆ្នាំ២០២០-២០២៤**




**៤. ការងារផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកៅស៊ូ**

ក្រសួងបានបើកវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងផ្សព្វផ្សាយបច្ចេកទេសកៅស៊ូចំនួន ៧វគ្គ ដោយមានអ្នកចូលរួមចំនួន ១៩៨នាក់ បណ្តុះបណ្តាលបច្ចេកទេសការចិញ្ចឹមឃ្មុំក្នុងសហគមន៍កសិកម្មកៅស៊ូគ្រួសារចំនួន ១សហគមន៍ និងពង្រឹងសហគមន៍កសិកម្មកៅស៊ូគ្រួសារបានចំនួន ៤សហគមន៍។

**៥. ការងារពិសោធន៍ និងស្រាវជ្រាវកៅស៊ូ**

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- បានអនុវត្តនិងបន្តការងារស្រាវជ្រាវ តាមដានទិន្នន័យចម្ការពិសោធន៍ទាំងនៅក្នុងស្ថានីយ ទាំងនៅតាមបណ្តាក្រុមហ៊ុនចម្ការកៅស៊ូ សរុបមាន៦៣ចម្ការពិសោធន៍
- បានចូលរួមបណ្តុះបណ្តាលធនធានមនុស្សនៅតាមគ្រឹះស្ថានសិក្សា និងការសម្របសម្រួលឱ្យនិស្សិតធ្វើទស្សនកិច្ចសិក្សាចម្ការពិសោធន៍

- ចេញវិញ្ញាបនបត្រច្បារពូជកៅស៊ូចំនួនពីរដល់កសិករកៅស៊ូគ្រួសារ នៅក្នុងស្រុកចម្ការលើ ខេត្តកំពង់ចាម និងស្រុកតំបែរ ខេត្តត្បូងឃ្មុំ
- ផ្តល់មែកពូជដល់ក្រុមហ៊ុនចម្ការកៅស៊ូមេមត់នូវក្លូនកៅស៊ូកម្ពុជាចំនួន២៖ CRRI-19 ចំនួន ៣៥ម៉ែត្រ និង CRRI-12 ចំនួន ៣៥ម៉ែត្រ
- បានយកសំណាក និងវិភាគសរីរៈទឹកជ័រពីចម្ការពិសោធន៍នានាក្នុង និងក្រៅស្ថានីយបានចំនួន១ ៦២៨សំណាក
- បានធ្វើតេស្តកៅស៊ូសន្លឹក (RSS) សរុបចំនួន ៩៦សំណាក ដើម្បីពិនិត្យគុណភាព នៃការកែច្នៃតាមស្តង់ដា CSR
- បានចូលរួមធ្វើតេស្តប្រៀបធៀបអន្តរមន្ទីរពិសោធន៍អន្តរជាតិក្នុងក្របខ័ណ្ឌសមាគមកៅស៊ូអន្តរជាតិ (IRA) ចំនួន ២លើក (ទី១៣០និងទី១៣១) លើយថាប្រភេទកៅស៊ូ TSR (Technical Specified Rubber)
- បានធ្វើតេស្តប្រៀបធៀបក្នុងស្រុកជាមួយមន្ទីរសោធន៍មូលដ្ឋាន លើកទី៦៦និង៦៧
- ធ្វើតេស្តនិងបានចុះបញ្ជិកាទទួលស្គាល់ និងសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ចំនួន៤ រោងចក្រកែច្នៃកៅស៊ូ CSR និងមន្ទីរពិសោធន៍ចំនួន៤។

**៦. កម្លាំងពលកម្មក្នុងអនុវិស័យកៅស៊ូ**

ឆ្នាំ២០២៤ អនុវិស័យកៅស៊ូបានប្រើប្រាស់កម្លាំងពលកម្មផ្នែកសំខាន់ៗសរុបចំនួនប្រមាណ ១៤២ ៧១៧នាក់ ដែលក្នុងនោះមាន៖ កម្លាំងពលកម្មក្នុងផ្នែកយកផលមានចំនួនប្រមាណ ១១០ ១១៩នាក់ កម្លាំងពលកម្មក្នុងផ្នែកថែទាំមានចំនួនប្រមាណ ១៩ ០១៦នាក់ កម្លាំងពលកម្មក្នុងផ្នែកកែច្នៃមានចំនួនប្រមាណ ៦ ៧៨៦នាក់ និងកម្លាំងពលកម្មក្នុងផ្នែកការងាររដ្ឋបាលមានចំនួនប្រមាណ ៦ ៧៩៦នាក់។ ចំពោះកៅស៊ូគ្រួសារ មានចំនួនសរុប ៣៤ ៧៥៣គ្រួសារក្នុងខេត្តចំនួន២១ មានទំហំផ្ទៃដីសរុប ២០២ ៣២១ហិកតា គិតជាមធ្យម ១គ្រួសារមានផ្ទៃដីកៅស៊ូចំនួន ៥,៨ហិកតា។

**៧. ការងារប្រលងចៀរជ័រនិងប្រារព្ធខួប១០០ឆ្នាំចម្ការកៅស៊ូចាស់ជាងគេនៅកម្ពុជា**

ឆ្នាំ២០២៤នេះ ក្រសួងបានរៀបចំកម្មវិធីប្រលងចៀរជ័រកៅស៊ូ ដែលជាព្រឹត្តិការណ៍ប្រលងចៀរជ័រកៅស៊ូថ្នាក់ជាតិលើកដំបូងនៅកម្ពុជា ដែលជាគំនិតផ្តួចផ្តើមដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីទាក់ទាញចំណាប់អារម្មណ៍ពីប្រជាពលរដ្ឋក្នុងការងារជាកម្មករចៀរជ័រកៅស៊ូ ដែលរក្សាបាននិរន្តរភាពកម្លាំងពលកម្មតាមចម្ការកៅស៊ូ រក្សាសុខភាពដើមកៅស៊ូ រយៈពេលចៀរយកផលបានយូរ ត្រឹមត្រូវ ទទួលបានទិន្នផលខ្ពស់ និងផ្តល់ក្តីសង្ឃឹមដល់កម្មករចៀរជ័រឱ្យខិតខំប្រឹងប្រែងបំពេញការងារកាន់តែល្អ និងមានប្រសិទ្ធភាពសេដ្ឋកិច្ចកាន់តែប្រសើរឡើង។ កម្មវិធីនេះមានការចូលរួមពីកម្មករចៀរជ័រឆ្នើមពីបណ្តាក្រុមហ៊ុនកសិ-ឧស្សាហកម្ម និងសហគមន៍ កៅស៊ូគ្រួសារ សរុបចំនួន ៦៩នាក់។ លើសពីនេះ ក្រសួងក៏បានប្រារព្ធខួប១០០ឆ្នាំ ចម្ការកៅស៊ូចាស់ជាងគេនៅកម្ពុជា ដែលទទួលបានការប្រសិទ្ធនាមដ៏ខ្ពង់ខ្ពស់បំផុតពី **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ថា "**ឧទ្យានបេតិកភណ្ឌកៅស៊ូ តេជោ-ធិបតី**" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ឧទ្យាននេះ បានផ្តល់ជាប្រភពធនធានសេនេទិចសម្រាប់បម្រើឱ្យការសិក្សាស្រាវជ្រាវបង្កើតក្លូនកៅស៊ូថ្មី បង្កើតទៅជាតំបន់កសិទេសចរណ៍ និងជាកេរ្តិ៍ដំណែលចម្ការកៅស៊ូដាំដោយគ្រាប់នៅសល់ដើមរស់ ដែលមានអាយុចាស់ជាងគេនៅកម្ពុជា ហើយមានចំនួនដើមនៅរស់ច្រើនជាងគេក្នុងពិភពលោក។

## ៥.៣ ការងារផលិតកម្មសត្វ និងសុខភាពសត្វ

### ក. ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ

ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារក្នុងឆ្នាំ២០២៤ មានសត្វសរុបចំនួន ៣៩,៨លានក្បាល ក្នុងនោះ គោចំនួនប្រមាណ ៣លានក្បាល ក្របីចំនួន ៤៥០,៧៨ពាន់ក្បាល ជ្រូកចំនួន ១,២៦លានក្បាល បក្សីចំនួន ៣៥,០២លានក្បាល សេះចំនួន ៣,១១ពាន់ក្បាល ចៀមចំនួន ៧,៥ពាន់ក្បាល ពពែចំនួន ៥៦,៨៦ពាន់ក្បាល និងដំរីចំនួន ៣៦ក្បាល។

ប្រៀបធៀបឆ្នាំ២០២៣ ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារសរុបមានអត្រាកំណើន ១,៧% ក្នុងនោះ គោថយចុះ -០,៦% ក្របីកើន ៤,៥% សេះកើន ១១,៩% ជ្រូកកើន ១,៦% បក្សីកើន ១,៨% ចៀមកើន ៧៤,៣% និងពពែកើន ១០,១% ។

**ក្រាហ្វិកទី១៥៖ ផលិតកម្មសត្វលក្ខណៈគ្រួសារឆ្នាំ២០២០-២០២៤**




**ក្រាហ្វិកទី១៦៖ ផលិតកម្មសត្វបក្សីលក្ខណៈគ្រួសារឆ្នាំ២០២០-២០២៤**




## ខ. ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម

ក្នុងឆ្នាំ២០២៤ ការសត្វចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្ម មានចំនួនសរុប ២៩,៥១លានក្បាល ក្នុងនោះ គោ-ក្របីចំនួន ៥៤,៥៤ពាន់ក្បាល ជ្រូកចំនួន ២,៨០លានក្បាល បក្សីចំនួន ២៦,៥៤លានក្បាល សេះចំនួន ២០ក្បាល ចៀមចំនួន ១,០៧ពាន់ក្បាល ពពែចំនួន ៣,៤៦ពាន់ក្បាល និងស្វាចំនួន ១០២,៨១ពាន់។

ប្រៀបធៀបឆ្នាំ២០២៣ ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មសរុបមានអត្រាកំណើន ៧,៥% ក្នុងនោះ គោ-ក្របីកើន ៥៦,៦% ជ្រូកកើន ១៩,៦% បក្សីកើន ៦,៣% សេះថយ -៥០% ចៀមថយ -៥២,៤% ពពែកើន ១៥២% និងស្វាកើន ៥,៣%។

ក្រាហ្វិកទី១៧៖ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មឆ្នាំ២០២០-២០២៤




ក្រាហ្វិកទី១៨៖ ផលិតកម្មសត្វបក្សីលក្ខណៈពាណិជ្ជកម្មឆ្នាំ២០២០-២០២៤




គ. ផលិតកម្មសត្វសរុបទូទាំងប្រទេស (លក្ខណៈគ្រួសារ និងពាណិជ្ជកម្ម)

ជារួម ផលិតកម្មសត្វគ្រប់ប្រភេទក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ មានការកើនឡើងគួរឱ្យកត់សម្គាល់ គឺចាប់ពីចំនួន ៥៣,៩០លានក្បាល ក្នុងឆ្នាំ២០២០ កើនដល់ចំនួន ៦៩,៣០លានក្បាលនៅឆ្នាំ២០២៤។ ដោយឡែកក្នុងឆ្នាំ២០២៤ នេះ ស្ថិតិសត្វគោមានចំនួន ៣,០៥លានក្បាល ក្របីចំនួន ៤៥១,០៣ពាន់ក្បាល ជ្រូកចំនួន៤,០៦លានក្បាល បក្សីចំនួន ៦១,៥៥លានក្បាល សេះចំនួន ៣,១៣ពាន់ក្បាល ចៀមចំនួន ៨,៥៦ពាន់ក្បាល ពពែចំនួន ៦០,៣២ពាន់ក្បាល ដំរីចំនួន ៣៦ក្បាល ស្វាចំនួន ១០៣,២៥ពាន់ក្បាល និងទន្សាយចំនួន ២,៩០ពាន់ក្បាល។

បើប្រៀបធៀបទៅនឹងឆ្នាំ២០២៣ ផលិតកម្មសត្វសរុបមានអត្រាកំណើនចំនួន ៤,១% ក្នុងនោះគោក្របីកើន ០,៥៨% ជ្រូកកើន ១៣,៤% បក្សីកើន ៣,៧% សេះកើន ១១,១% ចៀមកើន ៣០,៧% ពពែកើន ១៣,៨% ស្វាកើន ៥,៣% និងទន្សាយថយចុះ ១០,៦% និងដំរីថយចុះ ៧,៧%។

ក្រាហ្វិកទី១៩៖ ផលិតកម្មសត្វសរុប (លក្ខណៈគ្រួសារនិងពាណិជ្ជកម្ម) ឆ្នាំ២០២០-២០២៤




ក្រាហ្វិកទី២០៖ ផលិតកម្មសត្វបក្សីសរុប (លក្ខណៈគ្រួសារនិងពាណិជ្ជកម្ម) ឆ្នាំ២០២០-២០២៤




### ឃ. ការប្រៀបធៀបបែបផែនផលិតកម្មសត្វ

ការជំរុញផលិតកម្មសត្វ និងបង្កើនផលិតភាពសត្វ គឺជាគោលដៅអាទិភាពសម្រាប់ការធ្វើពាណិជ្ជកម្មសត្វ។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្ម មានអត្រាកើនឡើងគួរឱ្យកត់សម្គាល់ គឺចាប់ពីចំនួន ១៨,៩២លានក្បាល ក្នុងឆ្នាំ២០២០ កើនដល់ចំនួន ២៩,៥០លានក្បាល នៅឆ្នាំ២០២៤។ ដោយឡែកនៅក្នុងឆ្នាំ២០២៤ នេះ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មមានអត្រាកំណើន ៧,៥% ក្នុងនោះផលិតកម្មគោ ក្របីកើន ៥៦, ៦% ផលិតកម្មជ្រូកកើន ១៩,៦% និងផលិតកម្មបក្សីកើនចំនួន ៦,៣%។ អត្រានៃកំណើននេះបានឆ្លុះបញ្ចាំងឱ្យឃើញពីការផ្លាស់ប្តូរបែបផែនផលិតកម្មសត្វជាវិជ្ជមានមួយ ដើម្បីឈានទៅកែលម្អផលិតភាពសត្វ និងប្រសិទ្ធភាពសេដ្ឋកិច្ចកាន់តែល្អប្រសើរឡើង។

- **ការប្រៀបធៀបបែបផែនផលិតកម្មសត្វ៖** អត្រានៃការចិញ្ចឹមសត្វលក្ខណៈពាណិជ្ជកម្មបានកើនពី ៣៥% ក្នុងឆ្នាំ២០២០ ដល់៤២,៦% នៅឆ្នាំ២០២៤។ ដោយឡែកអត្រានៃការចិញ្ចឹមសត្វលក្ខណៈគ្រួសារបានថយចុះពី ៦៥% ក្នុងឆ្នាំ២០២០ មកត្រឹម ៥៧,៤ នៅឆ្នាំ២០២៤។

## ក្រាហ្វិកទី២១៖ ប្រៀបធៀបបែបផែនផលិតកម្មសត្វសរុបឆ្នាំ២០២០-២០២៤




## ក្រាហ្វិកទី២២៖ ប្រៀបធៀបអត្រាបែបផែនផលិតកម្មសត្វសរុបឆ្នាំ២០២០-២០២៤




- **ការប្រៀបធៀបបែបផែនផលិតកម្មជ្រូក៖** អត្រានៃការចិញ្ចឹមជ្រូកជាលក្ខណៈពាណិជ្ជកម្មបានកើនពីចំនួន ៥៥% ក្នុងឆ្នាំ២០២០ ដល់ចំនួន៦៩% នៅក្នុងឆ្នាំ២០២៤។ ដោយឡែកអត្រានៃការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារបានថយចុះពីចំនួន៤៥% ក្នុងឆ្នាំ២០២០ មកត្រឹមចំនួន៣១% នៅឆ្នាំ២០២៤។

## ក្រាហ្វិកទី២៣៖ ប្រៀបធៀបបែបផែនផលិតកម្មជ្រូក ឆ្នាំ២០២០-២០២៤



- **ការប្រៀបធៀបបែបផែនផលិតកម្មបក្សី៖** អត្រានៃការចិញ្ចឹមបក្សីជាលក្ខណៈពាណិជ្ជកម្មបានកើនពីចំនួន ៣៦% ក្នុងឆ្នាំ២០២០ ដល់ចំនួន ៤១,៥% នៅឆ្នាំ២០២៤។ ដោយឡែក អត្រានៃការចិញ្ចឹមបក្សីជាលក្ខណៈគ្រួសារបានថយចុះពីចំនួន ៦៤% ក្នុងឆ្នាំ២០២០ មកត្រឹមចំនួន ៥៨,៥% នៅឆ្នាំ២០២៤។

**ក្រាហ្វិកទី២៤៖ ប្រៀបធៀបបែបផែនផលិតកម្មបក្សី ឆ្នាំ២០២០-២០២៤**




**ក្រាហ្វិកទី២៥៖ ប្រៀបធៀបអត្រាបែបផែនផលិតកម្មបក្សី ឆ្នាំ២០២០-២០២៤**




### ង. តម្រូវការសត្វ និងសាច់

ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ តម្រូវការសាច់សត្វសម្រាប់បរិភោគ មានការកើនឡើងគួរឱ្យកត់សម្គាល់ គឺកើនពីចំនួន ៣០១ពាន់តោន ក្នុងឆ្នាំ២០២០ ឡើងដល់ចំនួន ៣៣១ពាន់តោន នៅឆ្នាំ២០២៤។ ដោយឡែកក្នុងឆ្នាំ ២០២៤ នេះ តម្រូវការសាច់សរុបចំនួន ៣៣១ពាន់តោន ក្នុងនោះសាច់គោ-ក្របីចំនួន ៩២ពាន់តោន សាច់ជ្រូកចំនួន ១៦៧ពាន់តោន សាច់បក្សីចំនួន ៧០,៧ពាន់តោន និងសាច់ចៀម-ពពែឬសាច់ផ្សេងៗទៀតចំនួន ៨៩៥តោន។

ផលិតកម្មសត្វក្នុងស្រុកអាចផ្គត់ផ្គង់សាច់បានប្រមាណ ៣២៥ពាន់តោន ស្មើនឹង ៩៨,១% នៃតម្រូវការសរុប ក្នុងនោះសាច់គោ-ក្របីចំនួន ៩០,៧ពាន់តោន (៨២៥ពាន់ក្បាល) សាច់ជ្រូកចំនួន ១៦៧ពាន់តោន (៣,៣៥លានក្បាល) សាច់បក្សីចំនួន ៦៦ពាន់តោន (៥៥,១៥៧ពាន់ក្បាល)។

បរិមាណសាច់ដែលខ្វះខាតត្រូវបាននាំចូលពីបរទេសមកបំពេញតម្រូវការបន្ថែមសម្រាប់ម្ហូបអាហារ និងធ្វើជាវត្ថុធាតុដើមផលិតចំណីសត្វលម្អ (ឆ្កែ ឆ្មា)។ ជាក់ស្តែងនៅក្នុងឆ្នាំ២០២៤ កម្ពុជាបាននាំចូលសាច់ និងផលិតសត្វសរុបចំនួន ២៩ពាន់តោន។

ការវាយតម្លៃស្ថានភាពប្រចាំឆ្នាំ២០២៤ ការបរិភោគសាច់សត្វនៅកម្ពុជាសម្រាប់មនុស្ស ម្នាក់ក្នុងមួយឆ្នាំហូបសាច់ជាមធ្យមប្រមាណ ១៨,៥គ.ក ក្នុងនោះមានសាច់គោ-ក្របីចំនួន ៥,១៥គ.ក សាច់ជ្រូកចំនួន ៩,៣៥គ.ក សាច់បក្សីចំនួន ៣,៩៥គ.ក និងសាច់ចៀម ពពែចំនួន ០.០៥គ.ក។

**ក្រាហ្វិកទី២៦៖ តម្រូវការសាច់ ការផ្គត់ផ្គង់ និងកង្វះខាត**




## ច. ការនាំចេញសត្វ និងផលិតផលសត្វ

កម្ពុជាមានលទ្ធភាពធ្វើការនាំចេញគោ-ក្របី ជ្រូក មាន់ ស្វាក្តាម សាច់ ផលិតផលសត្វ ចំណីសត្វ និងទឹកដោះគោមួយចំនួនទៅបរទេសផងដែរ។ ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ កម្ពុជាបាននាំចេញគោ-ក្របីចំនួន ៨៩,៩៨ពាន់ក្បាល ជ្រូកសាច់ចំនួន ១៥,២៥ពាន់ក្បាល ជ្រូកពូជ (មេ បា) ចំនួន ២,៣១ពាន់ក្បាល ស្វាក្តាមចំនួន ៩៨,២៧ពាន់ក្បាល ទឹកដោះគោចំនួន ២,៨៦ពាន់តោន ចំណីឆ្កែចំនួន ៤០,០៣ពាន់តោន រោមសត្វចំនួន ១៧២តោន ស្បែកគោ-ក្របី ជ្រូកចំនួន ២៧,៦៨ពាន់តោន  Gelatine ចំនួន ៨៤៨តោន និងកាកសំណល់ប្រេងឆាចំនួន ១២៦តោន។ ដោយឡែកនៅឆ្នាំ២០២៤ កម្ពុជាបាននាំចេញគោ-ក្របីចំនួន ៣០,៨២ពាន់ក្បាល ជ្រូកពូជ (មេ បា) ចំនួន ៧៥០ក្បាល ស្វាក្តាមចំនួន ១១,៨៩ពាន់ក្បាល ចំណីឆ្កែចំនួន ១៤,២៦ពាន់តោន រោមសត្វចំនួន ៣២,៧៧តោន ស្បែកគោ-ក្របី ជ្រូកចំនួន ១,៩៥ពាន់តោន Gelatine ចំនួន ៩៦តោន និងកាកសំណល់ប្រេងឆាចំនួន ១២៦តោន។

## ឆ. កម្មវិធីកែលម្អពូជ

ក្រសួងបានផ្សព្វផ្សាយបច្ចេកទេស និងផលប្រយោជន៍នៃការបង្កាត់គោ និងជ្រូកដោយសិប្បនិម្មិតដល់មន្ត្រីជំនាញផលិតកម្ម និងបសុព្យាបាលទាំង២៥រាជធានី ខេត្ត។

នៅឆ្នាំ២០២៤ នេះ ការបង្កាត់គោដោយសិប្បនិម្មិតសម្រេចបានចំនួន១៣ ៣៩៩ក្បាល និងមេកើតកូនបានចំនួន ៦ ៨៦៩ក្បាល (ញី ៣ ៧២៨ក្បាល) ស្មើនឹង ៣០% នៃមេដែលបានបង្កាត់សិប្បនិម្មិត។

## ជ. ចំណីសត្វ និងបសុឱសថ

កម្មវិធីកែលម្អចំណីសត្វ និងផ្សព្វផ្សាយពូជស្មៅដែលសំបូរទៅដោយសារធាតុចិញ្ចឹម និងផ្តល់ទិន្នផលខ្ពស់គឺជាសកម្មភាពដ៏អាទិភាពមួយដើម្បីជំរុញផលិតកម្មសត្វ។ បច្ចុប្បន្នការដាំដុះដំណាំចំណីសត្វ បានរីកសាយភាយ

យ៉ាងទូលំទូលាយនៅទូទាំង២៥រាជធានី ខេត្ត។ ជាក់ស្តែងក្នុងឆ្នាំ២០២៤ នេះ កន្លែងដាំដុះ និងធ្វើបង្ហាញដំណាំចំណីសត្វ សរុបចំនួន ៣ ២០៤កន្លែង លើផ្ទៃដីចំនួន ៣ ៥៥៣,១ហិកតា។

ក្នុងឆ្នាំ២០២៤ នេះ ក្រុមហ៊ុនដែលបានវិនិយោគសាងសង់រោងចក្រផលិតចំណីសត្វ នៅក្នុងប្រទេសកម្ពុជា សរុបចំនួន ២៥ក្រុមហ៊ុន មានរោងចក្រផលិតចំណីចំនួន ៣០កន្លែង រួមមានក្រុមហ៊ុនស៊ីភី ខេមបូឌា, អេហ្វ្រីម៉ាស្ទ័រ, ហ្វ្រីនហ្វីត ខេមបូឌៀ, បេតាហ្គ្រោ ខេមបូឌា, ស៊ីឈួន ញ៉ូវហូភ, អ៊ីស្តហូប, ស៊ីជេ ដេលជីដាង ហ្វីដ, សាណាហ្វ្រូ, អិមភិក អេស៊ីអិមស៊ី, ស៊ីខេ-វ៉ាយអ៊ី, ប្រាយអេហ្វ្រីស្តារ, វើលដ៍វេត, រោងចក្រចំណីសត្វកណ្តោលដុំ, អេអែនធី ហ្វីដ, ដេហ៊ីស ធីអិមអេច, វឌ្ឍនៈអេនីម៉លហ៊ែល, ភីដិបបែលយូអ, នូបលចេស្តហ្វូដ, អាយតាវេផេតសិបផ្លាយ, ឡូឌីផេតប្រូដាក, ហាយភើហូប, លូហេង ផេត ហ្វូដ, ខ្មែរ ហ្វ្រេស មីល និងសហគ្រាសផលិតចំណីដង្កៅប៉ាង។ ក្នុងឆ្នាំ២០២៤ ក្រុមហ៊ុនផលិតចំណីសត្វទាំងអស់បាននឹងកំពុងដំណើរការផលិតចំណីសត្វយ៉ាងសកម្ម ដោយផលិតចំណីសត្វបានប្រមាណជាង ១,៩០លានតោន ស្មើនឹង៥៤% នៃសមត្ថភាពផលិតរបស់រោងចក្រជាង ៣,៥លានតោន។

### ឈ. ការគ្រប់គ្រងកាកសំណល់សត្វ

ចាប់ពីឆ្នាំ២០០៦ ឡជីវឧស្ម័នគ្រួសារសម្រេចបានចំនួន ៣០ ៩៩០ឡ (ឆ្នាំ២០២៤ ចំនួន ៣៩៤ឡ) ក្នុងខេត្តចំនួន ១៤ គឺខេត្តបាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពត កណ្តាល ព្រៃវែង ពោធិ៍សាត់ សៀមរាប ស្វាយរៀង តាកែវ ត្បូងឃ្មុំ និងខេត្តបន្ទាយមានជ័យ ដែលបានចូលរួមកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់។

ក្រោមហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាលចិន គម្រោងសាងសង់ឡជីវឧស្ម័នកម្ពុជា-ចិន សម្រេចបានចំនួន ១៧៨ឡ ចាប់ពីចុងឆ្នាំ២០១៩ មកដល់បច្ចុប្បន្ន នៅក្នុងខេត្តចំនួន ៧ គឺ ខេត្តកំពង់ចាម កំពង់ឆ្នាំង ព្រះវិហារ ព្រៃវែង ពោធិ៍សាត់ ស្វាយរៀង និងខេត្តត្បូងឃ្មុំ។

ក្រោមហិរញ្ញប្បទានសម្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី គម្រោងខ្សែច្រវាក់ផលិតកម្មដោយភាគរបរិស្ថានបានសាងសង់ឡជីវឧស្ម័នគ្រួសារចំនួន ១៧៩ឡ៖ ខេត្តតាកែចំនួន ៥០ឡ កំពតចំនួន ៤៨ឡ កំពង់ចាមចំនួន ៤៥ឡ និងខេត្តត្បូងឃ្មុំចំនួន ៣៦ឡ។

**ក្រាហ្វិកទី២៧៖ ការសាងសង់ឡជីវឧស្ម័នតាមបណ្តាខេត្ត**



### ញ. ការលើកកម្ពស់សុខនាពសត្វ

ក្រសួងបានធ្វើការត្រួតពិនិត្យចរាចរណ៍សត្វ និងផលិតផលសត្វសរុបចំនួន ២០៥ករណី ក្នុងនោះ ចរាចរណ៍សត្វ និងផលិតផលសត្វមានលិខិតអនុញ្ញាតត្រឹមត្រូវចំនួន ១៧០ករណី និងបង្ក្រាបបទល្មើសបានចំនួន ៣៥ករណី (ដឹកជញ្ជូនស៊ុតចំនួន ៨ករណី ជ្រូករស់ចំនួន ២ករណី មាន់រស់ និងទារស់ចំនួន ៥ករណី និងសាច់បង្កកមានចំនួន ២០ករណី)។ ការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត បង្ក្រាបបទល្មើសសាច់បង្កកបានចំនួន ៤ករណី។

ចាក់វ៉ាក់សាំងការពារជំងឺឆ្លងសំខាន់ៗដែលកើតមានលើគោ ក្របី ពពែ ចៀម ដូចជាជំងឺអុតក្តាម បូសខ្យល់ សារទឹក និងជំងឺដុំពកស្បែកគោ ក្របីសរុបចំនួន៩៤៦ ៩០៥ក្បាល ចាក់វ៉ាក់សាំងការពារជំងឺលើសត្វជ្រូកចំនួន ២ ៦៦៧ ៩៦៤ក្បាល ចាក់វ៉ាក់សាំងការពារជំងឺលើបក្សីបានចំនួន ២៨ ៦២០ ៤២៤ក្បាល ចាក់វ៉ាក់សាំងការពារជំងឺឆ្កែឆ្កួតលើសត្វឆ្កែ និងឆ្មាចំនួន ២៦៥ ០០០ក្បាល។ លើសពីនេះ ក្រសួងបានចាត់វិធានការជីវសុវត្ថិភាព ផ្សព្វផ្សាយ និងអនុវត្តផ្ទាល់នៅសត្តឃាតដ្ឋាន ទីផ្សារលក់សត្វ កសិដ្ឋានចិញ្ចឹមសត្វ កន្លែងចិញ្ចឹមសត្វ មធ្យោបាយដឹកជញ្ជូនសត្វ និងផលិតផលសត្វ និងកន្លែងផ្ទុះជំងឺសត្វសរុបចំនួន ២៥០ ២៥៧លើក។ បច្ចុប្បន្ននេះ ក្រសួងមានភ្នាក់ងារសុខភាពសត្វភូមិ ចំនួន ៨ ១៩៣នាក់ (ស្ត្រី ៥៦៥នាក់) នៅទូទាំងប្រទេស។

### ដ. ការលើកកម្ពស់សុខនាពសាធារណៈបសុព្យាបាល

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- បានបណ្តុះបណ្តាល និងចុះណែនាំបច្ចេកទេសធ្វើអាជីវកម្មសត្វ និងការពិឃាតសត្វចំនួន ៣៦លើក ដោយមានការចូលរួមពីម្ចាស់សត្តឃាតដ្ឋាន អាជីវករពិឃាតសត្វ និងអ្នកពាក់ព័ន្ធចំនួន ៣៦០នាក់ (ស្ត្រី ៧៦នាក់)
- ចុះត្រួតពិនិត្យបច្ចេកទេសបង្កើតសត្តឃាតដ្ឋានចំនួន ១៥កន្លែង បន្តសុពលភាពសត្តឃាតដ្ឋានចំនួន ១១កន្លែង
- សត្តឃាតដ្ឋាននៅទូទាំងប្រទេសមានចំនួន ២៣៧កន្លែង ក្នុងនោះមានសត្តឃាតដ្ឋានអនុលោមតាមអនុក្រឹត្យ ១០៨ ចំនួន ១២៤កន្លែង សត្តឃាតដ្ឋានអនុលោមតាមអនុក្រឹត្យ១០៨និងវិនិយោគចំនួន៦២កន្លែង និងសត្តឃាតដ្ឋានវិនិយោគចំនួន៥១កន្លែង។ សត្តឃាតដ្ឋានទំនើបចំនួន ៥កន្លែង ក្នុងនោះ សត្តឃាតដ្ឋានបក្សីទំនើបចំនួន ៣កន្លែង (កណ្តាល២ កំពត១) និងសត្តឃាតដ្ឋានជ្រូកទំនើបចំនួន ២កន្លែង (ត្បូងឃ្មុំ១ កំពត១)
- មន្ទីរព្យាបាលសត្វ និងគ្លីនិកព្យាបាលសត្វនៅតាមបណ្តារាជធានី-ខេត្តសរុបចំនួន ៤៥កន្លែង ក្នុងនោះរាជធានីភ្នំពេញ ២៨កន្លែង ខេត្តបាត់ដំបង ៦កន្លែង បន្ទាយមានជ័យ ៣កន្លែង សៀមរាប ៣កន្លែង កំពត ២កន្លែង ព្រះសីហនុ ២កន្លែង និងខេត្តកំពង់ស្ពឺ ១កន្លែង។
- បានកែលម្អការដឹកជញ្ជូនសាច់ និងផលិតផលសត្វចេញពីសត្តឃាតដ្ឋានទៅកាន់ទីផ្សារបានចំនួន ៣១សត្តឃាតដ្ឋាន

### ឋ. ការងារផ្សព្វផ្សាយបច្ចេកទេស

ក្រសួងបានផ្សព្វផ្សាយ តាមរយៈការសម្ភាសន៍ វេទិកាសាធារណៈ ប្រជុំ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលអំពីច្បាប់ លិខិតបទដ្ឋានគតិយុត្ត បច្ចេកទេសចិញ្ចឹមសត្វ ដាំដំណាំចំណីសត្វ និងជំងឺឆ្លងសត្វ ជាពិសេសជំងឺប៉េស្តជ្រូកអាហ្វ្រិក ជំងឺផ្តាសាយបក្សី និងជំងឺដុំពកលើស្បែកគោក្របី ដល់កសិករចិញ្ចឹមសត្វ និងអ្នកពាក់ព័ន្ធសរុបចំនួន ១ ២៥៨នាក់ (ស្ត្រី ៦៥០នាក់)។ ទន្ទឹមនេះ ក្រសួងក៏បានធ្វើការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ គេហទំព័រ និងហ្វេសប៊ុកជូនសាធារណៈជនផងដែរ។ ថ្នាក់ដឹកនាំសហគមន៍សុខភាពសត្វ និងផលិតកម្មសត្វដែលក្រសួងជ្រើសរើស បានចុះផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមសត្វ ខ្សែច្រវាក់ផលិតកម្ម និងផែនការអាជីវកម្មដល់សមាជិកចំនួនសរុប ៦៦០នាក់ (ស្ត្រី ៣០៧នាក់)។

### ឌ. ការងារចេញលិខិតអនុញ្ញាត និងចុះបញ្ជិកា

ក្រុមហ៊ុនចំណីសត្វចំនួន ២ ទទួលបានការអនុញ្ញាតឱ្យផលិត លាយផ្សំ ឬវេចខ្ចប់ជាថ្មី។ ក្រុមហ៊ុនចំណីសត្វចំនួន ១៣ បានចុះបញ្ជិកាចំណីសត្វ សារធាតុបន្ថែម និងវត្ថុធាតុដើមសរុបចំនួន ៥៣៣មុខ ក្នុងនោះមានចំណីសត្វចំនួន ៤២៦មុខ សារធាតុបន្ថែមចំនួន ៤១មុខ វត្ថុធាតុដើមចំនួន ៦៦មុខ។ ក្រុមហ៊ុនចំណីសត្វចំនួន ១៧ ទទួលបានការអនុញ្ញាតឱ្យចុះបញ្ជីឃ្លាំងសន្និធិ ហើយក្រុមហ៊ុនចំនួន ២០ បានទទួលលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយចំណីសត្វដែលមានយថាប្រភេទចំនួន ១ ៨១៦មុខ។

ក្រុមហ៊ុនបសុឱសថចំនួន ៥ ទទួលបានចុះបញ្ជិកាបសុឱសថ វត្ថុធាតុជីវបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុសរុបចំនួន ១៨៣មុខ ក្នុងនោះបសុឱសថចំនួន ១៦៤មុខ និងវ៉ាក់សាំងចំនួន ១៩មុខ បានចុះបញ្ជីឃ្លាំងសន្និធិបសុឱសថចំនួន ៥ក្រុមហ៊ុន។

### ឍ. ការងារអធិការកិច្ច

ក្រសួងបានផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ និងបានបើកវគ្គបណ្តុះបណ្តាលស្តីពីការអប់រំសមត្ថភាពវិជ្ជាជីវៈ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតពាក់ព័ន្ធនឹងចំណីសត្វ និងបសុឱសថ ដល់អ្នកលក់ដុំនិងរាយចំណីសត្វ និងបសុឱសថចំនួនសរុប ២១៤នាក់ (ស្ត្រីចំនួន ៦៩នាក់) ព្រមទាំងបានចាត់មន្ត្រីចុះធ្វើអធិការកិច្ចដេប៉ូលក់ដុំនិងរាយចំនួន ១៤៥ដេប៉ូ។

### ណ. ការងារស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- ធ្វើរោគវិនិច្ឆ័យលើសំណាកចំនួន ១១ ៦៣៩ និងរកឃើញចំនួន ១៧ករណី បង្កដោយវីរុស H5N1 សរុបចំនួន ៥ រាជធានីខេត្តមានដូចជា ខេត្តបន្ទាយមានជ័យមាន ១ករណី ព្រៃវែង ៧ករណី សៀមរាប ៥ករណី ស្វាយរៀង ៣ករណី និងខេត្តតាកែវ ១ករណី
- អង្កេតឃ្លាំមើលវត្តមានជំងឺផ្តាសាយបក្សីនៅទីផ្សារបក្សីរស់ក្នុងខេត្តចំនួន ៨ រួមមាន៖ ខេត្តបាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ កំពត មណ្ឌលគីរី សៀមរាប និងខេត្តស្វាយរៀង និងជំងឺផ្តាសាយជ្រូក ប៉េស្តជ្រូកអាហ្វ្រិក អុតក្តាម រលូតកូនជ្រូក រលូតកូនគោ គ្រុន Q និងមេលីអូអ៊ីដូស៊ីសនៅតាមសត្តឃាតដ្ឋានក្នុងខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ធំ កំពត ក្រចេះ ភ្នំពេញ ព្រៃវែង សៀមរាប ស្វាយរៀង និង ខេត្តតាកែវ។
- ចាត់មន្ត្រីជំនាញចុះអន្តរាគមន៍ពិនិត្យ ព្យាបាល ចាក់វ៉ាក់សាំង យកវត្ថុវិភាគ អនុវត្តវិធានជីវសុវត្ថិភាព អប់រំណែនាំ និងផ្សព្វផ្សាយបច្ចេកទេសដល់កសិករចិញ្ចឹមសត្វ ព្រមទាំងបន្តអង្កេតឃ្លាំមើលវត្តមានជំងឺឆ្លងនានានៅទូទាំងប្រទេស
- ចុះយកវត្ថុវិភាគបានចំនួន ៤៩៤វត្ថុវិភាគ ក្នុងនោះ មានសាច់បង្កកគ្រប់មុខចំនួន ៩២វត្ថុវិភាគដែលនាំចូលពីបណ្តាប្រទេសនានា ដើម្បីរកវត្តមានសារធាតុរក្សាទុក បសុឱសថ សារធាតុជំរុញការលូតលាស់ បូរ៉ាក់ និងហ្វរម៉ាលីន ជាលទ្ធផលអវិជ្ជមាន ប្រេងឆាចំនួន ៤២វត្ថុវិភាគ សាច់ជ្រូកចំនួន ១២០វត្ថុវិភាគ សាច់គោចំនួន ១២០វត្ថុវិភាគ និងសាច់មាន់ចំនួន ១២០វត្ថុវិភាគដែលលក់នៅក្នុងតូបតាមដងផ្លូវជាតិ និងតាមទីផ្សារនៅខេត្តកំពង់ចាម ស្វាយរៀង បាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ សៀមរាប ព្រះវិហារ កែប កំពត កោះកុង កំពង់ធំ និងខេត្តត្បូងឃ្មុំ ដើម្បីធ្វើតេស្តរកវត្តមានកាកសំណល់អង់ទីប៊ីយ៉ូទិក សារធាតុគីមីហ្វរម៉ាលីន និងបូរ៉ាកនៅក្នុងផលិតផលសត្វដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ

- ផលិត និងចែកចាយទឹកមេជីវិតគោបង្កកចំនួន១ ៥២០ដើម ក្នុងនោះបែងចែកជូនខេត្តបាត់ដំបងចំនួន២៣០ដើម បន្ទាយមានជ័យចំនួន ៥៨០ដើម រតនគិរីចំនួន ២៣០ដើម សៀមរាបចំនួន ២២០ដើម និងខេត្តពោធិ៍សាត់ចំនួន ២៦០ដើម
- បង្កាត់គោដោយសិប្បនិម្មិតពិសោធន៍បង្ហាញបានចំនួន ១ ៤៨៧ក្បាល និងកើតកូនបានចំនួន ៦៦៩ក្បាល
- ប្រមូលវត្ថុវិភាគចំណីសត្វតាមក្រុមហ៊ុន និងដេប៉ូលក់ចំណីសត្វបានចំនួន៣៨៦ (ចំណីសម្រេច ៣៧១ និងវត្ថុធាតុដើម១៥)។

## ៥.៤ ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម

ក. ការងារអភិរក្ស និងគ្រប់គ្រងដែនជលផល

- បានរៀបចំឯកសារស្នើចុះបញ្ជីកន្លែងគ្រប់គ្រង ការពារ និងអភិរក្សជលផល ៥៨ទីតាំង លើផ្ទៃទឹកទំហំ ១៥២ ៥៨២ហិកតា បានទទួលបណ្ណកម្មសិទ្ធិ ១២ទីតាំង លើផ្ទៃទឹកទំហំ ៧៧៧,១៥ហិកតា
- បានបញ្ចប់ការសាងសង់បង្គោលបេតុងកំណត់ព្រំប្រទល់ បំពាក់ស្លាក់ការអភិរក្ស និងដាំស្តារព្រៃលិចទឹកសម្រាប់កន្លែងការពារនិងអភិរក្សជលផល ៣៩ទីតាំង លើផ្ទៃដីទំហំ ១៥៣ ៣៦៨ហិកតា
- បានដាំកូនឈើព្រៃលិចទឹកនិងព្រៃកោងកាង ១២៧ ០០០ដើម លើផ្ទៃដីទំហំ១៧០ហិកតា នៅតំបន់ បឹងទន្លេសាប និងតំបន់ឆ្នេរ
- បានទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក ៩៣ទីតាំង លើផ្ទៃដីទំហំ ៤០ហិកតា នៅខេត្តជុំវិញបឹងទន្លេសាប
- បានសាងសង់ស្លាក់ការអភិរក្ស ២ខ្នង បោះបង្គោលឈើ ៤៥៧ដើម និងបង្គោលបេតុង ១៥ដើម សម្រាប់កន្លែងអភិរក្សជលផលក្នុងខេត្តបាត់ដំបង ពោធិ៍សាត់ កណ្តាល និងខេត្តក្រចេះ និងបោះពោងបណ្តែតទឹកចំនួន ២០សម្រាប់កំណត់ព្រំប្រទល់តំបន់គ្រប់គ្រង និងការពារសត្វផ្សោតទន្លេមេគង្គ
- បានពង្រឹងការងារល្បាត ២៤/២៤ម៉ោងការពារសត្វផ្សោតទន្លេមេគង្គ ជាលទ្ធផលកូនផ្សោតកើតថ្មី ៩ក្បាល និងស្លាប់ ៤ក្បាល ដែលធ្វើឱ្យចំនួនសត្វផ្សោតកើនពី ៨៩ក្បាលក្នុងឆ្នាំ២០២៣ ដល់ ១០៤ក្បាល ក្នុងឆ្នាំ២០២៤
- បានរកឃើញវត្តមានសត្វផ្សោតសមុទ្រប្រមាណជាង ១០០ក្បាល (ផ្សោតអ៊ីរ៉ាវ៉ាឌី ផ្សោតឥតព្រុយខ្នង និងផ្សោតឃ្លៀច) និងជ្រូកទឹកនៅខេត្តកែបនិងខេត្តកំពត
- បានរកឃើញសំបុកអណ្តើកសមុទ្រ ៣ទីតាំង ញាស់បាន ៩០កូន និងបានលែងអណ្តើកសមុទ្រ ៤៤ក្បាល ចូលក្នុងដែនទឹកធម្មជាតិ
- បានបង្កាត់ភ្ញាស់ពងអណ្តើកហ្លួង ២៥០គ្រាប់ ញាស់បាន ៥៣កូន និងលែងអណ្តើកហ្លួងជំទង់ ៤០ក្បាល ចូលក្នុងប្រព័ន្ធព្រៃកស្រែអំបិលខេត្តកោះកុង
- បានលែងត្រីរាជ ១២ក្បាល ត្រីគល់រាំង ៣៣ក្បាល ត្រីស្លក់ ១ក្បាល ត្រីបបែលទឹកសាប ១ក្បាល និងកន្ធាយក្បាលកង្កែប ២៣ក្បាល
- បានចុះស្រាវជ្រាវនិងទប់ស្កាត់បទល្មើសជួញដូរប្រភេទវារីសត្វកម្រ និងជិតផុតពូជ ៤០ករណី ដោយរឹបអូសអណ្តើករស់ចំនួន ៤៩៨ក្បាល
- បង្កើនផលស្តុកក្តាមសេះ ដោយគាំទ្របច្ចេកទេសបង្កាត់ភ្ញាស់ពាក់កណ្តាលសិប្បនិម្មិតដល់សហគមន៍នេសាទភូមិអង្កោល ខេត្តកែប និងរៀបចំធនាគារក្តាមថ្មី១កន្លែង នៅសហគមន៍ភូមិថ្មី ខេត្តកែប និង បានលែងកូនក្តាមប្រមាណ ២០០លាន ចូលក្នុងដែនទឹកធម្មជាតិ
- ចុះបញ្ជីកសិដ្ឋានចិញ្ចឹមក្រពើ ៧០ទីតាំង ដែលមានក្រពើមេពូជ ៣១ ១៨៧ក្បាល។

### ខ. ការអភិវឌ្ឍសហគមន៍នេសាទ

- សហគមន៍នេសាទ ៥១៦សហគមន៍ ទឹកសាប) ៤៧៥និងសមុទ្រ ៤១មានសមាជិក ( ៣៣២ ១៦៨នាក់ ស្ត្រី) ៣៥%) ត្រូវជា ១៤៧ ៥១៨គ្រួសារ
- សហគមន៍នេសាទ ៤៥៨ត្រូវបានចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង សហគមន៍នេសាទ ៩កំពុងរៀបចំស្នើសុំចុះបញ្ជីបន្ថែមទៀត
- សហគមន៍នេសាទចំនួន ៥២ត្រូវបានស្នើសុំទៅក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីចុះបញ្ជីជាដីកម្មសិទ្ធិសាធារណៈរបស់រដ្ឋនិងជាទ្រព្យសម្បត្តិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងនោះ សហគមន៍នេសាទ៦បានទទួលប្លង់រឹង
- សហគមន៍នេសាទបានទទួលការបណ្តុះបណ្តាលនិងផ្សព្វផ្សាយដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រង សហគមន៍នេសាទនិងបង្កើនមុខរបរចិញ្ចឹមជីវិត ២៦១វគ្គ អ្នកចូលរួម ៦ ៦១៤នាក់
- រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍បានផ្តល់ថវិកាគាំទ្រការអនុវត្តផែនការសកម្មភាពរបស់សហគមន៍នេសាទចំនួន ២៥០ មានថវិកាចំនួន ១ ២៣៦ ០០០ ០០០រៀល
- បានសាងសង់ស្នាក់ការសហគមន៍នេសាទចំនួន៤ នៅខេត្តកោះកុងនិងខេត្តព្រះសីហនុ
- បានផ្តល់សម្ភារៈរួមមាន កាណូតល្បាត ៨គ្រឿង ទូរស័ព្ទ ២២គ្រឿង អាយកូម ៤៥គ្រឿង GPS ១២គ្រឿង កែវយឹត ១០គ្រឿង អាវពោង ១៤៣ អាវភ្លៀង ១៤៦ ពិល ១៦ មេក្រូ ៥គ្រឿង ឯកសណ្ឋានល្បាត ២១១កំផ្លេ ដល់សហគមន៍នេសាទសម្រាប់ពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ
- បានបង្កើតកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទចំនួន ៥៧៧កន្លែង ដាក់ស្លាកសញ្ញា ២៤៦ស្លាក បោះបង្គោលក្នុងកន្លែងអភិរក្សជលផលសហគមន៍នេសាទ ៦៩៣បង្គោល និងបោះបង្គោល ព្រំប្រទល់កន្លែងនេសាទសហគមន៍ ១៥៩បង្គោល
- សហគមន៍នេសាទចំនួន ២០០ត្រូវបានវាយតម្លៃថាមានដំណើរការល្អ។

### គ. ការងារបង្ក្រាបបទល្មើសជលផល

ក្រសួងបានចងក្រងសំណុំរឿងបទល្មើសជលផលចំនួន ៣ ១៩៤ករណី (សមុទ្រ ១៤៨ករណី) ដោយបានបំផ្លាញវត្ថុតាងចំនួន ២ ៨៨៦ករណី ពិន័យអន្តរការណ៍ចំនួន ១៤៦ករណី (ប្រមូលបានថវិកាចំនួន ៥៤៨ ៨២១ ០០០រៀល ពីប្រាក់ពិន័យនិងការលក់វត្ថុតាង) និងបានបញ្ជូនសំណុំរឿងចំនួន ១៦២ករណី និងជនសង្ស័យចំនួន ១១៥នាក់ ទៅតុលាការ។

ទន្ទឹមនេះ ក្រសួងក៏បាន រឹបអូស និងបំផ្លាញចោល ដូចជា របាំងស្បៃមុង សាច់អួន លប លូស្បៃមុង លូសាច់អួន អួនអូសទឹកសាបរួមផ្សំឆក់ត្រជាក់ ឈិបយន្ត អួនហ៊ុម ឧបករណ៍ឆក់ត្រី សម្រាស់ លបកែច្នៃឬលបកន្ទុយកណ្តុរ ជាដើម និងបានលែងត្រីចម្រុះចូលក្នុងធម្មជាតិវិញ ៦៧ ៦៣៦គីឡូក្រាម។

### ឃ. ការអភិវឌ្ឍវារីវប្បកម្ម

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- ការចិញ្ចឹមត្រីអនុវត្តបាន ៣២០ ២៨០តោន កើនឡើង ៦ ២៨០តោន ស្មើនឹង ២% ធៀបនឹងឆ្នាំ២០២៣
- ការផលិតកូនត្រីពូជអនុវត្តបាន ២៧៥ ៥០០ ០០០ក្បាល កើនឡើង ៦ ២០០ ០០០ក្បាល ស្មើនឹង ២.៣% ធៀបនឹងឆ្នាំ២០២៣
- ការចិញ្ចឹមក្រពើអនុវត្តបាន ២៨២ ៨២៥ក្បាល ថយចុះ ៤៩ ៨៧៥ក្បាល ស្មើនឹង១៥% ធៀប នឹងឆ្នាំ២០២៣
- បានស្រាវជ្រាវផលិតកូនពូជវារីសត្វប្រភេទថ្មីបាន ២ប្រភេទ មានត្រីអាំងកីយ និងក្តាមថ្មបាន ១៥ ០០០កូន

- បានផ្គត់ផ្គង់ និងចែកចាយកូនត្រីពូជសម្រាប់ទិវាមច្ឆជាតិ និងកសិករចិញ្ចឹម ១០ ០០០ ០០០កូន
- បានស្រាវជ្រាវផលិតកូនពូជវារីសត្វប្រភេទថ្មីបាន៧ប្រភេទ មានត្រីពោ សណ្តាយ ខ្យា គ្រំ ត្រចៀកដំរី ខ្ទឹង និងត្រីអណ្តែងទន់ ៧២០ ០០០កូន
- បានស្រាវជ្រាវផលិតពូជត្រីប្រានិងត្រីឆ្តិនតាមវិធីសាស្ត្រធ្វើជម្រើសពូជ ដោយផលិតកូនត្រីពូជជំនាន់ ទី១បាន ៣២០ ០០០កូន
- បានកំណត់អត្តសញ្ញាណត្រីមេពូជ ដាក់លេខកូដបាន៧ប្រភេទ មានត្រីប្រា ពោ ខ្យា គ្រំ ឆ្តិន ព្រលូង និងត្រីសណ្តាយ
- បានបង្កើតបណ្តុំវារីវប្បករបាន ៣៤កន្លែង មានសមាជិក ៤៩៤នាក់
- បានផ្តល់វិញ្ញាបនបត្របញ្ជាក់ការអនុវត្តវារីវប្បកម្មល្អជូនកសិដ្ឋាន ៤កន្លែង
- បានចេញលិខិតអនុញ្ញាតឱ្យធ្វើវារីវប្បកម្មកសិដ្ឋានធំៗ ៣៨ច្បាប់។

### ង. ការងារបច្ចេកវិទ្យាកែច្នៃ និងគុណភាព

- បានពង្រឹងប្រព័ន្ធគ្រប់គ្រងនិងត្រួតពិនិត្យគុណភាព សុវត្ថិភាពម្ហូបអាហារផល ផលិតផលជលផល ដើម្បីអនុលោមតាមស្តង់ដារសុវត្ថិភាពម្ហូបអាហារអន្តរជាតិ
- បានអនុវត្ត និងរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃកម្មវិធីជាតិតាមដាននិងត្រួតពិនិត្យសំណល់ឱសថវារីសត្វ និងសារធាតុគីមីហាមឃាត់ក្នុងផលិតផលវារីវប្បកម្ម ដោយបានប្រមូលសំណាកសម្រាប់ វិភាគ ៣២០សំណាកក្នុងខេត្តគោលដៅចំនួន១០
- បានចុះត្រួតពិនិត្យនិងអធិការកិច្ចលើគុណភាព សុវត្ថិភាពផល ផលិតផលជលផល ៦០ទីតាំង
- បានសហការជាមួយអង្គការ UNIDO បណ្តុះបណ្តាលមន្ត្រីជំនាញ ២៧នាក់ អ្នកកែច្នៃចំនួន ៤៧៩នាក់ សហគ្រាសចំនួន ២៦ និងគម្រោងចំនួន ២៣ ពាក់ព័ន្ធសមត្ថភាពធ្វើជាសវនករគុណភាព សុវត្ថិភាពអនុវត្តប្រព័ន្ធនិមិត្តសញ្ញាគុណភាព បង្កើនការកសាងសមត្ថភាពដល់សហគ្រាសកែច្នៃ (SMEs) ដោយប្រើប្រព័ន្ធឌីជីថល "CamTrace" សម្រាប់គាំទ្រដល់សហគ្រាសកែច្នៃជលផល
- បានរៀបចំសិក្ខាសាលានិងវគ្គបណ្តុះបណ្តាល ស្តីពីប្រព័ន្ធត្រួតពិនិត្យនិងអធិការកិច្ចគុណភាព សុវត្ថិភាពនិងលក្ខខណ្ឌតម្រូវបច្ចេកទេសនាំចេញ នាំចូល និងនាំឆ្លងកាត់ផល ផលិតផលជលផលដល់មន្ត្រីថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធ ៤វគ្គ អ្នកចូលរួម ៣៦៣នាក់ (ស្រី ៧៨នាក់)
- បានចេញវិញ្ញាបនបត្រសុខភាព ៣៤ដល់ក្រុមហ៊ុនចំនួន៧ ដើម្បីនាំចេញផល ផលិតផលជលផល ១៧០តោន ទៅកាន់ទីផ្សារប្រទេសចិន នូវែលហ្សេឡង់ អូស្ត្រាលី និងប្រទេសកូរ៉េខាងត្បូង។

### ច. ការងារសិក្សាស្រាវជ្រាវធនធានជលផល

- សិក្សាស្រាវជ្រាវជីវសាស្ត្រវារីសត្វនិងតាមដានផលនេសាទដាយត្រី
- សិក្សា eDNA ប្រភេទត្រីទឹកសាបនិងតាមដានលំហូរនៃប្រភេទកូនត្រីនៅខេត្តកំពង់ឆ្នាំងនិង ខេត្តកំពង់ចាម
- សិក្សាតាមដានសុខភាពអេកូឡូស៊ីទន្លេនៅខេត្តក្រចេះនិងខេត្តស្ទឹងត្រែង
- សិក្សាវាយតម្លៃសេដ្ឋកិច្ចត្រីទឹកសាបនៅខេត្តពោធិ៍សាត់និងខេត្តបាត់ដំបង និងផលនេដាទចាប់ប្រចាំថ្ងៃ និងវាយតម្លៃប្រាក់ចំណូលអ្នកនេសាទនៅខេត្តពោធិ៍សាត់ ក្រចេះ ស្ទឹងត្រែង និងខេត្តសៀមរាប
- សិក្សាប្រសិទ្ធភាពឧបករណ៍នេសាទទឹកសាបនៅខេត្តបាត់ដំបងនិងខេត្តពោធិ៍សាត់
- បានសិក្សាលក្ខណៈជីវសាស្ត្រនិងប្រព័ន្ធអេកូឡូស៊ីគ្រែងឈាមនិងគ្រុំចំពុះទានៅតំបន់ឆ្នេរ
- កំណត់អត្តសញ្ញាណប្រភេទត្រី និងកូនត្រីសមុទ្រ
- សិក្សាឧបករណ៍នេសាទអួនអូសនៅខេត្តតំបន់ឆ្នេរ
- បានបោះពុម្ពលទ្ធផលនៃការសិក្សាស្រាវជ្រាវចំនួន១២ច្បាប់។

### ឆ. ផល ផលិតផលជលផល

ក្នុងឆ្នាំ២០២៤នេះ ផល ផលិតផលជលផលអនុវត្តបាន ៩២៦ ៩៣៤តោន កើនលើសឆ្នាំមុន៦០ ៦៨៤តោន ស្មើនឹង៧% ធៀបនឹងឆ្នាំ២០២៣ រួមមាន៖

- ផលនេសាទទឹកសាប ៤៦៧ ៣៤៤តោន កើនឡើង ៤០ ៥៩៤តោន ស្មើនឹង ៩,៥១% ធៀបនឹងឆ្នាំ២០២៣
- ផលនេសាទសមុទ្រ ១៣៩ ៣១០តោន កើនឡើង ១៣ ៨១០តោន ស្មើនឹង ១១% ធៀបនឹងឆ្នាំ២០២៣
- ផលវារីវប្បកម្ម ៣២០ ២៨០តោន កើនឡើង ៦ ២៨០តោន ស្មើនឹង ២% ធៀបនឹងឆ្នាំ២០២៣។

**ក្រាហ្វិកទី២៨៖ ផលនេសាទទឹកសាប ផលនេសាទសមុទ្រ និងវារីវប្បកម្ម ឆ្នាំ ២០២០-២០២៤**




## ៥.៥ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានព្រៃឈើ និងសត្វព្រៃ

### ក. សហគមន៍ព្រៃឈើ

គិតត្រឹមឆ្នាំ២០២៤ សហគមន៍ព្រៃឈើមានចំនួន ៦៥៥ គ្របដណ្តប់លើផ្ទៃដីសរុប ៥៣០ ៤៩៨ហិកតា និងមានសមាជិកចំនួន ១៧២ ៣៩៨គ្រួសារ ក្នុងនោះ ក្រសួងបានប្រកាសទទួលស្គាល់ចំនួន ៥៤២សហគមន៍ (ផ្ទៃដី ៤៥៥ ៦៤៩ហិកតា) បានចុះកិច្ចព្រមព្រៀងបង្កើតព្រៃសហគមន៍ចំនួន ៤៧១ (ផ្ទៃដី ៣៨៦ ៤៨៥ហិកតា) និងបានរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន ១២០ (ផ្ទៃដី ៨៥ ៧៤៩ហិកតា)។

**ក្រាហ្វិកទី២៩៖ ចំនួនសហគមន៍ព្រៃឈើពីឆ្នាំ២០២០-២០២៤**



ខ. ការងារបកស្រាយគម្របព្រៃឈើ

ក្រសួងបានបាននិងកំពុងសិក្សាវាយតម្លៃគម្របព្រៃឈើសម្រាប់ឆ្នាំ២០២៣ អនុវត្តបាន ៦៤,០៨ភាគរយ នៃផ្ទៃដីសរុបទូទាំងប្រទេស និងចាត់ថ្នាក់តាមរូបភាពផ្កាយរណបសម្រាប់ឆ្នាំ២០២៤ អនុវត្តបាន ៣៥ភាគរយ នៃផ្ទៃដីសរុបទូទាំងប្រទេស ព្រមទាំងបានចុះប្រមូលទិន្នន័យដើម្បីផ្ទៀងផ្ទាត់គម្របព្រៃឈើឆ្នាំ២០២៤ ជាក់ស្តែងបានចំនួន ១ ១៨៩ចំណុច។

គ. ការគ្រប់គ្រងផល អនុផលព្រៃឈើ

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- ផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តសរុបចំនួន ២០៨គ្រឿង និងយានយន្តសរុបចំនួន ១៩៤គ្រឿង
- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ ជូនក្រុមហ៊ុន ក្នុងនោះមានឈើហ៊ុបមូលចំនួន ៣ ៧៣៥ ម៉ែត្រគូប កូនឈើចំនួន ៦០ ៤៨០ដើម អុសចម្រុះចំនួន ៤១ ៥៧៤ស្ទេរ ជ័រទឹកចំនួន ១២៦តោន ឬស្សីព្រៃចំនួន ២៥០តោន និងផ្លែសំរ៉ែងចំនួន ៦០តោន

ឃ. ការគ្រប់គ្រងដីស្ថានីយដាំឈើ និងដីព្រៃសហគមន៍

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- បានរៀបចំបង្កើតស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើចំនួន ៧ទីតាំង លើផ្ទៃដីសរុបទំហំ ៤ ៥០៤ហិកតា និងបានទទួលប័ណ្ណកម្មសិទ្ធិចំនួន២៦ បណ្ណ លើផ្ទៃដីទំហំ ១៧ ៥៧៦ហិកតា។ គិតត្រឹមឆ្នាំ២០២៤ ស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើ និងតំបន់ប្រភពគ្រាប់ពូជឈើមានចំនួនសរុប ៩៩ទីតាំងដែលគ្របដណ្តប់លើផ្ទៃដីសរុបទំហំ ៥២១ ៣៤២ហិកតា ស្ថិតក្នុងខេត្តចំនួន២១ ដោយក្នុងនោះស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើចំនួន១៦ទីតាំង មានប័ណ្ណកម្មសិទ្ធិលើផ្ទៃដីទំហំ ៩១ ២៤៤ហិកតា។ បច្ចុប្បន្ននេះ មានការដាំឈើជាលក្ខណៈក្រុមហ៊ុនដៃគូសហការ និងលក្ខណៈគ្រួសារចំនួន ២០ទីតាំង លើផ្ទៃដីសរុប ចំនួន ៩០ ០៤៦ហិកតា។ ព្រមទាំងបានចូលរួមដាំឈើជាចម្ការថ្មី និងទីសាធារណៈលើផ្ទៃដីទំហំ ២២ ៩០០ហិកតា (ដោយរដ្ឋ ១៥៣ហិកតា និងដាំដោយក្រុមហ៊ុនដៃគូសហការ និងទីសាធារណៈ ២២ ៧៤៧ហិកតា) បានបណ្តុះកូនឈើសម្រាប់ដាំ និងចែកចាយជូនប្រជាពលរដ្ឋ និងឯកជនសរុបចំនួន ៥ ៥០០ ០០០ដើម ជាពិសេសបានរៀបចំព្រះរាជពិធីរុក្ខទិវា ៩ កក្កដា ឆ្នាំ២០២៤ នៅស្រុកត្រាំកក់ ខេត្តតាកែវ ក្រោមព្រះរាជធិបតីភាព **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តមសីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**។ លើសពីនេះបានបន្តជំរុញការផ្សព្វផ្សាយ និងលើកទឹកចិត្តឱ្យមានការចូលរួមដាំឈើតាមទីតាំងផ្សេងៗដូចជា ទីសាធារណៈ សាលារៀន វត្តអារាម លំនៅដ្ឋាន។ល។
- បានទទួលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុចំនួន ២៦សន្លឹកបណ្ណ ក្នុងចំនួន ៣ខេត្ត ដែលមានផ្ទៃដីសរុបទំហំ ១៧ ៥៧៦ហិកតា ក្នុងនោះខេត្តមណ្ឌលគិរី ៣សន្លឹកបណ្ណ លើផ្ទៃដីទំហំ ៩៩ ៥២ហិកតា ខេត្តស្ទឹងត្រែង ៦សន្លឹកបណ្ណ លើផ្ទៃដីទំហំ ៤ ៣១៨ហិកតា និងខេត្តកំពង់ឆ្នាំង ១៧សន្លឹកបណ្ណ លើផ្ទៃដី សរុបទំហំ ៣ ៣០៦ហិកតា
- បានអនុវត្តបញ្ចប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធថ្នាលបណ្តុះកូនឈើ ស្ថិតនៅខេត្តកំពត
- កំពុងថែទាំចម្ការឈើសរុបទំហំ ៧៧៦ហិកតា ក្នុងនោះចម្ការពូជឈើទំហំ ១២០ហិកតា ឡូត៍បង្ហាញ កសិ-រុក្ខកម្មទំហំ ៣៧ហិកតា ចម្ការឈើដាំទំហំ ៥៩៧ហិកតា និងចម្ការរុក្ខទិវា៩កក្កដាសរុបទំហំ ៤០ហិកតា ស្ថិតក្នុងខេត្តចំនួន ៨ មានដូចជា៖ ខេត្តតាកែវ កំពត កណ្តាល ព្រះសីហនុ កំពង់ធំ កំពង់ឆ្នាំង បាត់ដំបង និងខេត្តក្រចេះ។

ង. ការងារឧស្សាហកម្ម ពាណិជ្ជកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- ការនាំចេញគិតត្រឹមខែតុលា ឆ្នាំ២០២៤ មានចំនួនសរុប ៣៥៨លានដុល្លារអាមេរិកមានដូចជា៖ (១) ផលិតផលព្រៃឈើ វត្ថុធ្វើពីឈើ រួមទាំងឈើដាំ និងធ្យូងឈើដាំចំនួន ៣០០លានដុល្លារអាមេរិក និង (២) សត្វស្វាក្តាម (ពានរ) ចំនួន ៥៨លានដុល្លារអាមេរិក
- ចុះពិនិត្យសំណើសុំបង្កើតរោងម៉ាស៊ីនឡធ្យូងកែច្នៃឈើដាំចំនួន ៦កន្លែង និងពន្យា ១១កន្លែង សរុប ១៧កន្លែង បានចុះពិនិត្យសំណើសុំបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំ (ច្រកចេញចូលតែមួយ) ចំនួន ០៦កន្លែង (បង្កើត ២ និងពន្យា ៤កន្លែង)
- បានបង្កើតរោងម៉ាស៊ីនកែច្នៃឈើចំនួន ៣០កន្លែង រោងសន្និធិឈើប្រភេទធំ ៤កន្លែង និងរោងសន្និធិដែលចេញដោយខណ្ឌរដ្ឋបាលព្រៃឈើមូលដ្ឋានចំនួន ៤៩៥កន្លែង
- បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន ១ មានបរិមាណឈើកែច្នៃចំនួន ១ ០៨០ម៉ែត្រត្រីគុណ
- រដ្ឋបាលព្រៃមានគម្រោងសហប្រតិបត្តិការអន្តរជាតិ និងសហការជាមួយដៃគូមានចំនួន ១៥គម្រោង។

### ច. ការងារសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ និងសត្វព្រៃ

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- នៅឆ្នាំ២០២៤នេះ បានធ្វើការចុះបញ្ជិកាថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសាររួមមានផ្ទះត្រចៀកកាំបានចំនួន ១០៤ច្បាប់ និងសត្វព្រៃប្រភេទផ្សេងចំនួន ៥ច្បាប់។ កសិដ្ឋានស្រាវជ្រាវចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាមត្រូវបានបង្កើតថ្មីចំនួន ២ទីតាំង។ មកដល់បច្ចុប្បន្ន មានកសិដ្ឋានស្រាវជ្រាវចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាមយកកូននាំចេញចំនួន ១០ទីតាំង ស្វាក្តាមចំនួន ១៣៩ ០០០ក្បាល ក្នុងនោះកូនកើតក្នុងឆ្នាំចំនួន ២៤ ៩០០ក្បាល
- បានចុះប្រមូលសំណាកសត្វល្អិតបានចំនួន ៥២៤សំណាក ស្មើនឹង ៦៩ប្រភេទ រុក្ខជាតិឱសថបុរាណ ចំនួន ៣១ប្រភេទ រុក្ខជាតិកេសរកូល បានចំនួន (អ័រគីដេព្រៃ) ១១២សំណាក ស្មើនឹង ១៣អំបូរ និងធ្វើជំរឿន សត្វដំរីស្រុកមានចំនួន ៦៣ក្បាល ដែលមានវត្តមានស្ថិតនៅក្នុងខេត្តសៀមរាប ឧត្តរមានជ័យ រតនៈគិរី មណ្ឌលគិរី ភ្នំពេញ និងខេត្តតាកែវ
- បានដាំស្តារដើមចន្ទន៍ក្រស្នា សរុបចំនួន ២ ៥០០០ ដើម លើផ្ទៃដីទំហំ ១៧,៦៦ ហិកតា នៅខេត្តកោះកុង ពោធិ៍សាត់ និងខេត្តបាត់ដំបង
- នៅឆ្នាំ២០២៤នេះ រដ្ឋបាលព្រៃឈើបានអនុវត្តការងារស្រាវជ្រាវព្រៃឈើ ដោយបានផ្តោតសំខាន់ៗលើការជំរុញ និងបង្កើតចំការបង្កាត់ពូជឈើប្រភេទឈើប្រណិតនិងឈើសំណង់បានចំនួន ៣ប្រភេទ លើផ្ទៃដី ២៤ហិចតា បង្កើតសួនអភិរក្សធនធានសេនេទិចពូជឈើសំខាន់ៗរបស់ប្រទេសកម្ពុជាចំនួន ២៥ប្រភេទ លើទំហំដី ២៦ហិកតា និងការបង្កើនសមត្ថភាពបច្ចេកវិទ្យាក្នុងការផលិតកូនឈើតាមបច្ចេកទេសជាលិកាវប្បកម្មទំនើប សម្រាប់ការដាំស្តារព្រៃឈើឡើងវិញ។

### ឆ. ការគ្រប់គ្រងឧទ្យានសួនសត្វ ព្រៃការពារ និងសួនឆ្លូតគាម "ន្ទិតាម៉ៅ"

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- បានសង្គ្រោះ និងថែរក្សាសត្វព្រៃសរុបចំនួន ៣ ២២០ក្បាល ដែលទទួលបានពីតំបន់នានាជាវត្ថុតាងនៃបទល្មើសសត្វព្រៃ ឬជាសត្វព្រៃដែលម្ចាស់អស់និស្ស័យ ឬសត្វព្រៃដែលរងគ្រោះថ្នាក់ដោយប្រការផ្សេងៗ ព្រមទាំងធ្វើការស្តារលទ្ធភាពជីវសាស្ត្ររួចលែងទៅព្រៃធម្មជាតិវិញបានចំនួន ៨៩៩ក្បាល
- បានធ្វើអនាម័យព្រៃ ៦៦ហិកតា សាងសង់ និងជួសជុលទ្រុងសត្វ ៣ ៩០៦ម៉ែត្រការ៉េ ជួសជុលផ្លូវ ១៨គីឡូម៉ែត្រ រៀបចំធ្វើផ្លូវភ្លើង ១៣គីឡូម៉ែត្រ រៀបចំផ្លូវជិះកង់ ៥គីឡូម៉ែត្រ ដាំជួសកូនឈើ ៦ ៣០០ដើម ផលិតស្លាកចរាចរ និងព័ត៌មាន ១៥០ផ្ទាំង ព្រមទាំងបានធ្វើការអប់រំផ្សព្វផ្សាយ សិស្សសាលាសរុបចំនួន ១១ ១២៧នាក់

- បានទទួលថែរក្សាសត្វដំរីញី ឈ្មោលមួយគូនេះ ដែលជាអំណោយដ៏ថ្លៃថ្លារបស់ **ឯកឧត្តម ថនលុន ស៊ីសុលីត** ប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្នុងឱកាសអញ្ជើញបំពេញទស្សនកិច្ចផ្លូវរដ្ឋនៅព្រះរាជាណាចក្រកម្ពុជាពីថ្ងៃទី២៣-២៤ ខែមេសា ឆ្នាំ២០២៤ នឹងថ្វាយសត្វដំរីញី ឈ្មោលមួយគូ ជាដង្វាយថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលនេះជានិមិត្តរូបនៃទំនាក់ទំនងភាតរភាព និងមិត្តភាពខ្លាំងក្លារវាងប្រទេសទាំងពីរ ព្រមទាំងបង្ហាញនូវចំណងមិត្តភាព កិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធយូរអង្វែងរវាងប្រជាជនទាំងពីរ ជាពិសេសទំនាក់ទំនងកាន់តែរឹងមាំបន្ថែមទៀតរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

ជ. ការងារអនុវត្តច្បាប់ស្តីពីព្រៃឈើ

ក្នុងឆ្នាំ២០២៤ សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងការកាប់រានដីព្រៃទទួលបានពីរដ្ឋបាលព្រៃឈើគ្រប់លំដាប់ថ្នាក់សរុបចំនួន ៤៨៨ករណី ដែលក្នុងនោះ មានសំណុំរឿងបទល្មើសព្រៃឈើត្រូវពិន័យអន្តរការណ៍ចំនួន ១១៩ករណី (ព្រៃឈើចំនួន ៩៣ករណី និងសត្វព្រៃចំនួន ២៦ករណី) និងសំណុំរឿងបទល្មើសព្រៃឈើត្រូវបញ្ជូនទៅតុលាការចំនួន ៣៦៩ករណី (ព្រៃឈើចំនួន១១៨ករណី សត្វព្រៃចំនួន ១៩ករណី និងដីព្រៃឈើចំនួន ២៣២ករណី)។ ចំពោះវត្ថុតាងនៃបទល្មើសព្រៃឈើដែលបានចាប់ឃាត់ និងដកហូតរួមមាន៖ ឈើចម្រុះខ្នាតមានចំនួន ៤២៧ម៉ែត្រគូប សត្វព្រៃចំនួន ៦១៦ក្បាលនិង៣៣០គីឡូក្រាម ផ្ទៃដីព្រៃឈើដែលបានកាប់រានទំហំ ៤ ១៥៣ហិកតា ឃាត់ខ្លួនជនល្មើសចំនួន ៧៨នាក់ និងអនុផលព្រៃឈើព្រមទាំងឧបករណ៍សម្ភារផ្សេងៗមួយចំនួនទៀត។

**ក្រាហ្វិកទី៣០៖ បទល្មើសព្រៃឈើពិន័យអន្តរការណ៍ និងទៅតុលាការពីឆ្នាំ២០២០-២០២៤**




## ៥.៦ ការងារសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស

### ៥.៦.១ អភិវឌ្ឍន៍ធនធានមនុស្ស

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានមន្ត្រីរាជការសរុបចំនួន ៥ ៨៤០នាក់ ស្រី ១ ៥០៩នាក់ ស្មើនឹង ២៥,៥៨% ក្នុងនោះអង្គភាពថ្នាក់កណ្តាលមានចំនួន៣ ០៨៧នាក់ ស្រី ៩២០នាក់ ស្មើនឹង២៩,៧១% និងថ្នាក់រាជធានីខេត្តមានចំនួន ២ ៧៥៣នាក់ ស្រី ៥៨៩នាក់ ស្មើនឹង២១,០៣%។

ក្រសួងបានផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីរាជការចំនួន ២ ៨៥៥នាក់ (ស្ត្រី ៨៤៤នាក់) ក្នុងនោះ ការបណ្តុះបណ្តាលក្នុងប្រទេស រយៈពេលខ្លី និងមធ្យម បានចំនួន២ ៥០៤នាក់ (ស្ត្រី ៧៤៣នាក់) និងរយៈពេលវែងចំនួន ១៥នាក់ ស្ត្រី ៥នាក់ និងការបណ្តុះបណ្តាលក្រៅប្រទេសសរុបបានចំនួន ៣៣៦នាក់ (ស្ត្រី ៩៦នាក់)។

ដោយឡែក នៅតាមគ្រឹះស្ថានអប់រំកសិកម្មទាំងបី មាននិស្សិតកំពុងសិក្សាសរុបចំនួន ៤ ៧៦០នាក់ (ស្ត្រី ២ ១១១នាក់)  និងនិស្សិតបញ្ចប់ថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បណ្ឌិតសរុបចំនួន ១ ២៣៦នាក់ (ស្ត្រី ៤៦៥នាក់)។

ក្រាហ្វិកទី៣១៖ ស្ថានភាពមន្ត្រីរាជការក្របខ័ណ្ឌ ឆ្នាំ២០២០-២០២៤




## ៥.៦.២ ការងាររៀបចំផែនការយុទ្ធសាស្ត្រ

ក្រសួងបានចូលរួមចំណែកយ៉ាងសកម្មក្នុងការរៀបចំធាតុចូលសម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០២៤-២០២៨ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២៤-២០២៨។ ទន្ទឹមនេះ ក្រសួងបានរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៥-២០២៧ គម្រោងថវិកាកម្មវិធីឆ្នាំ២០២៥ កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២០២៥-២០២៧ និងបានបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសដល់មន្ត្រីនៅថ្នាក់កណ្តាល និងរាជធានី ខេត្ត សរុបចំនួន ៦០០នាក់ ពាក់ព័ន្ធនឹងការអនុវត្តថវិកាសមិទ្ធកម្ម ប្រព័ន្ធតាមដាននិងវាយតម្លៃថវិកាកម្មវិធី ប្រព័ន្ធព័ត៌មានស្ថិតិ និងតម្លៃទីផ្សារកសិកម្ម ព្រមទាំងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម។ លើសពីនេះ ក្រសួងបានរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រ គោលនយោបាយ និងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រនានាពាក់ព័ន្ធនឹងវិស័យកសិកម្ម។

## ៥.៦.៣ ការងារគ្រប់គ្រងហិរញ្ញវត្ថុ

ការងារគ្រប់គ្រងហិរញ្ញវត្ថុ ក្រសួងបានទទួលកញ្ចប់ថវិកាសម្រាប់ចំណាយក្នុងឆ្នាំ២០២៤ សរុបចំនួន ៣១៦ ៣៥៣ លានរៀល ក្នុងនោះ ថវិកាសម្រាប់អង្គភាពថ្នាក់កណ្តាលចំនួន ២១០ ៩២៨លានរៀល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តចំនួន ១០៥ ៤២៥លានរៀល និងប៉ាន់ស្មានអនុវត្តសម្រេចបានចំនួន ២៨៦ ២២០ លានរៀល ស្មើនឹង ៩៤,៨% ធៀបនឹងឥណទានក្រោយវិចារណកម្ម។ ការអនុវត្តចំណាយថវិកាឆ្នាំ២០២៤ សម្រេចបានទាបជាងច្បាប់ហិរញ្ញវត្ថុ ៥,២% ដោយសារថវិកាចំណាយបៀវត្សនិងប្រាក់បំប៉ន ពិសេសសម្រាប់មន្ត្រីកសិកម្មឃុំចំនួន ៨០០ ដែលបានគ្រោងក្នុងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤ មិនបានអនុវត្ត ដោយសារមន្ត្រីកសិកម្មឃុំចំនួន ១ ០០០នាក់ ទើបជ្រើសរើសបាននៅក្នុងខែធ្នូ។ ទន្ទឹមនេះ ក្រសួងប៉ាន់ស្មានការប្រមូលចំណូលមិនមែនសារពើពន្ធចំនួន ៤០ ៧១២ លានរៀល ស្មើនឹង ១៤៣,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ។

## ៥.៦.៤ ការងារសវនកម្មផ្ទៃក្នុង

ក្រសួងបានចុះធ្វើសវនកម្មសម្រេចបាន ៤៩សវនដ្ឋាន ដោយរកឃើញលទ្ធផលសវនកម្ម និងផ្តល់អនុសាសន៍សម្រាប់សវនដ្ឋានកែលម្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងចំនួន ២០៨អនុសាសន៍។ បានចុះធ្វើសវនកម្មតាមអង្គភាពអនុវត្តគម្រោងដៃគូអភិវឌ្ឍន៍នានាក្រោមឱវាទក្រសួង និងចុះពិនិត្យការអនុវត្តថវិកានៅតាមអង្គភាពជំនាញមួយចំនួន។ ទន្ទឹមនេះ

ក្រសួងបានណែនាំឱ្យខិតខំពង្រឹងសមត្ថភាពចំណេះដឹងបច្ចេកទេសសវនកម្ម និងការសិក្សាស្រាវជ្រាវបន្ថែមជាបន្តបន្ទាប់ ដើម្បីរកលទ្ធផលសវនកម្ម និងការសរសេររបាយការណ៍សវនកម្មឱ្យកាន់តែល្អថែមទៀត។

### ៥.៦.៥ ការងារសហប្រតិបត្តិការអន្តរជាតិ

ក្រសួងបាននិងកំពុងពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិទាំងក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី ក្នុងក្របខណ្ឌអាស៊ាន ព្រមទាំងសហការល្អប្រសើរ និងស្អិតរមួតជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ស្ថានទូត អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជននានា ដើម្បីគៀងគរទាំងជំនួយបច្ចេកទេស ជំនួយហិរញ្ញវត្ថុ និងបង្កើនការចចារជាមួយបណ្ដាលប្រទេសដែលមានសក្ដានុពលដើម្បីដោះស្រាយលក្ខខ័ណ្ឌតម្រូវនានាដែលពាក់ព័ន្ធនឹងការនាំចេញផលិតផលនិងកសិផលរបស់កម្ពុជាទៅលើទីផ្សារអន្តរជាតិ។ ក្នុងឆ្នាំ២០២៤ ក្រសួងបន្តពង្រឹងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីអភិវឌ្ឍវិស័យកសិកម្មឲ្យមានលក្ខណៈទំនើប និងសមស្របនឹងស្ថានភាពជាក់ស្ដែង និងការវិវត្តនាពេលអនាគត។ ទន្ទឹមនេះ ក្រសួងបានចុះកិច្ចព្រមព្រៀង/អនុស្សារណៈយោគយល់គ្នាសរុបចំនួន ១៤ ដែលមានទឹកប្រាក់សរុប ១១ ៣១៥ ៦០៥ ដុល្លារអាមេរិក រួមមានគម្រោងក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី និងអង្គការអន្តរជាតិ។ ក្រសួងក៏បាននឹងកំពុងសម្របសម្រួលចុះកិច្ចព្រមព្រៀងអនុវត្តគម្រោង (PA ) ជាមួយ FAO និងដៃគូអភិវឌ្ឍន៍ចំនួន ៣ ដែលមានទឹកប្រាក់សរុបចំនួន ១ ១៣៦ ៤៦៤ ដុល្លារអាមេរិក។ ក្រសួងក៏បានចុះពិធីសារជាមួយអគ្គរដ្ឋបាលគយនៃសាធារណរដ្ឋប្រជាមានិតចិនទាក់ទងនឹងការធ្វើចត្តាឡីស័កនិងលក្ខខណ្ឌតម្រូវអនាម័យសម្រាប់ផលិតផលចំណីផ្លែពាក់កណ្តាលសម្រេចធ្វើពីស្បែកគសម្រាប់នាំចេញពីកម្ពុជាទៅចិន។

### ៥.៦.៦ ការងារនីតិកម្មកសិកម្ម

ក្នុងឆ្នាំ២០២៤នេះ សេចក្តីព្រាងច្បាប់ចំនួន ២ ពាក់ព័ន្ធនឹងអនុវិស័យព្រៃឈើ និងជលផលបានបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីធ្វើការពិនិត្យ សម្រេច និងច្បាប់ និងសេចក្តីព្រាងច្បាប់ស្តីពី ផលិតកម្មតាមកិច្ចសន្យា បាននឹងកំពុងរៀបចំដើម្បីស្នើសុំការពិនិត្យ សម្រេច។ ទន្ទឹមនេះ ក្រសួងក៏បាននឹងកំពុងរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យចំនួន ២ សេចក្តីព្រាងអនុក្រឹត្យចំនួន ៤ សេចក្តីព្រាងប្រកាសចំនួន ១១ និងសារាចរណែនាំចំនួន ១ ដែលទាក់ទងនឹងការងារគ្រប់គ្រងជីថ្នាំនិងជីកសិកម្ម និងមូលនិធិអភិវឌ្ឍន៍សហគមន៍កសិកម្ម។ លើសពីនេះ ក្រសួងបានពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ សេចក្តីព្រាងព្រះរាជក្រឹត្យ សេចក្តីព្រាងអនុក្រឹត្យ ប្រកាស និងឯកសារគតិយុត្តិផ្សេងៗដែលពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ៩៣ករណី។

### ៥.៦.៧ ការងារអធិការកិច្ច

ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពការងារ ក្រសួងបានចុះធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រងតាមបណ្ដាអង្គភាពក្រោមឱវាទក្រសួងមានបេសកកម្មសរុបចំនួន ១៥លើក បានអនុញ្ញាតឱ្យសមត្ថកិច្ចគ្រប់គ្រងសាតេសកម្ពុជាចេញលិខិតអនុញ្ញាតសាយតេសឱ្យក្រុមហ៊ុនចំនួន ១៤ច្បាប់ ទទួលពាក្យបណ្តឹងនិងចុះស្រាវជ្រាវជាក់ស្ដែងបានចំនួន ៧ករណី។ ទន្ទឹមនេះ ក្រសួងបានស្រាវជ្រាវព័ត៌មានតាមបណ្តាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ៤១ករណី និងបានចូលរួមកម្មវិធីប្រជុំ សិក្ខាសាលា និងការងារសង្គមសរុបចំនួន ១៥០លើក។ លើសពីនេះក្រសួងបានចុះផ្ទៀងផ្ទាត់ និងពិនិត្យលទ្ធភាពចិញ្ចឹមសត្វក្រពើចំនួន ២លើក ព្រមទាំងចុះពិនិត្យប្រមូលទិន្នន័យកំណត់ប្រភព និងពង្រឹងលើលទ្ធភាពចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាម។

### ៥.៦.៨ ការងារគ្រប់គ្រងឯកសារ និងប្រព័ន្ធព័ត៌មាន

ក្រសួងបានរៀបចំយុទ្ធសាស្ត្រឌីជីថលូបនីយកម្ម ឆ្នាំ២០២៤-២០២៨ សម្រាប់អនុវត្តក្នុងរយៈពេល៥ឆ្នាំ ក្នុងគោលបំណងពង្រឹងសមត្ថភាពស្ថាប័ន រៀបចំហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងពង្រឹងសមត្ថភាពធនធានមនុស្សក្នុងការគ្រប់គ្រង និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលយ៉ាងពេញលេញក្នុងវិស័យកសិកម្ម។ ទន្ទឹមនេះ ក្រសួងបានបង្កើត

មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យរួមមួយក្នុងការគ្រប់គ្រងប្រតិបត្តិការ និងរក្សាសុវត្ថិភាពព័ត៌មាន ទិន្នន័យ សម្រាប់គាំទ្រដល់អភិបាលកិច្ចល្អ បង្កើនប្រសិទ្ធភាព និងផលិតភាពការងារ និងបានសិក្សាបង្កើតកម្មវិធីទូរស័ព្ទ (Mobile App) ដែលជាថ្នាលឌីជីថលនៃទិន្នន័យកសិកម្ម សម្រាប់ប្រើប្រាស់រួមគ្នា ដើម្បីផ្តល់ភាពងាយស្រួលដល់កសិករ និងអ្នកពាក់ព័ន្ធក្នុងវិស័យកសិកម្មទំនាក់ទំនងគ្នា និងបង្កើនទីផ្សារសម្រាប់កសិករ ព្រមទាំងជួយគាំទ្រ និងដោះស្រាយបញ្ហានានារបស់កសិករបានឆាប់រហ័ស។ លើសពីនេះ ក្រសួងបានចូលរួមអនុវត្តគោលនយោបាយរដ្ឋាភិបាលឌីជីថល និងក្របខណ្ឌសេដ្ឋកិច្ច និងសង្គមឌីជីថល ដោយបាននឹងកំពុងប្រើប្រាស់ថ្នាល Verify.gov.kh នៅលើសញ្ញាបត្រនិស្សិតរបស់គ្រឹះស្ថានឧត្តមសិក្សាទាំង៣ និងការដាក់ qr.gov.kh លើឯកសារផ្លូវការព្រមទាំងការភ្ជាប់ QR Verify ក្នុងថ្នាល CamDX លើប្រព័ន្ធផ្តល់សេវាសាធារណៈតាមអនឡាញ។

ចំពោះការងារគ្រប់គ្រងប្រព័ន្ធព័ត៌មាន ក្រសួងបានផ្សព្វផ្សាយព័ត៌មានចំនួន ២ ៩៨៤ព័ត៌មាន ដូចខាងក្រោម៖

- ផ្សព្វផ្សាយតាមទំព័រហ្វេសបុក (Facebook) សរុបចំនួន ១ ០៦៤ព័ត៌មាន ក្នុងនោះមានវីដេអូចំនួន ៧៣វីដេអូ
- គេហទំព័រ (Website) សរុបចំនួន ៧៨៩ព័ត៌មាន ក្នុងនោះមានវីដេអូចំនួន ៦៧វីដេអូ
- តេឡេក្រាម (Channel Telegram) សរុបចំនួន ៩១៨ព័ត៌មាន ក្នុងនោះមានវីដេអូចំនួន ៦៥វីដេអូ
- យូធូបឆែណែល (Channel You tube) ចំនួន ៦៥វីដេអូ
- ផ្សាយតាមស្ថានីយ៍ទូរទស្សន៍ (ទទក BTV អប្សារា) សរុបចំនួន ១៤៨វីដេអូ។

### ៥.៦.៩ ការងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ក្រសួងផ្តល់ព័ត៌មានបច្ចេកទេសកសិកម្មដល់កសិករ និងអតិថិជន (CallCenter) បានជួយដោះស្រាយបញ្ហា និងផ្តល់ព័ត៌មានបច្ចេកទេសកសិកម្មដល់កសិករ និងអតិថិជនមកពី១៥រាជធានី ខេត្ត ដែលទទួលបានចំនួន១ ១៨៦ សំណួរ-ចម្លើយ រួមមាន ការផ្តល់បច្ចេកទេសកសិកម្ម (ដំណាំស្រូវ បន្លែ ការចិញ្ចឹមសត្វ ការប្រើប្រាស់ជី ថ្នាំសម្លាប់សត្វល្អិត ស្មៅ...) ព័ត៌មានតម្លៃស្រូវ ការណែនាំវិធីសាស្ត្រសម្រាប់ទប់ស្កាត់ និងកម្ចាត់កត្តាចង្រៃ ការធ្លាក់ចុះតម្លៃកសិផល (ស្វាយកែវរមៀត ដំឡូងមី បន្លែ...) នីតិវិធីក្នុងការបើកអាជីវកម្មជីនិងថ្នាំកសិកម្ម នីតិវិធីស្នើសុំបើកគ្លីនិកព្យាបាលសត្វ នីតិវិធីនៃការចុះបញ្ជិការជីនិងថ្នាំកសិកម្ម នីតិវិធីនៃការនាំចេញ នាំចូលផលិតផលកសិកម្ម និងព័ត៌មានផ្សេងៗជាច្រើនទៀត។ ជាមួយគ្នានេះដែរក្រសួងបានរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីបច្ចេកទេសកសិកម្មឃុំចំនួន ៧វគ្គ។ តាមរយៈមន្ត្រីបច្ចេកទេសកសិកម្មឃុំ កសិករចំនួន ៩២ ៧៣២គ្រួសារទទួលបានបច្ចេកទេសទាក់ទងនឹងការដាំដុះដំណាំស្រូវ ការផលិតស្រូវសរីរាង្គ ការប្រើប្រាស់ជីនិងថ្នាំកសិកម្ម ការដាំដំណាំគម្របដី ការដាំបន្លែ ការចិញ្ចឹមសត្វ និងបច្ចេកទេសផ្សេងៗទៀតពាក់ព័ន្ធនឹងវិស័យកសិកម្ម។ លើសពីនេះ មន្ត្រីបច្ចេកទេសកសិកម្មឃុំបានរៀបចំវគ្គបណ្តុះបណ្តាលដល់កសិករចំនួន ២៣៤វគ្គ មានអ្នកចូលរួមចំនួន ៤ ៦៨០នាក់ បង្កើតក្រុមសមកាលកម្មដើម្បីសម្របសម្រួលទីផ្សារបានចំនួន ១៨៥ក្រុម ចូលរួមដោះស្រាយបញ្ហារបស់កសិករពាក់ព័ន្ធនឹងបច្ចេកទេសដាំដុះ ការគ្រប់គ្រងកត្តាចង្រៃនិងជំងឺលើដំណាំស្រូ និងបន្លែ ព្រមទាំងផលិតវីដេអូខ្លីស្តីពីចំណាប់អារម្មណ៍របស់កសិករលើវគ្គមានមន្ត្រីបច្ចេកទេសកសិកម្មឃុំបានចំនួន ១៤៣វីដេអូ។

### ៥.៦.១០ ការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ក្រសួងបានចុះគាំទ្របច្ចេកទេស តាមដាន ត្រួតពិនិត្យលើមុខងារដែលបានផ្ទេរទៅឱ្យថ្នាក់ក្រោមជាតិ ស្របតាមផែនការប្រចាំឆ្នាំនៅរដ្ឋបាលខេត្តមួយចំនួនមាន៖ ខេត្តស្វាយរៀង កំពត កំពង់ឆ្នាំង កំពង់ស្ពឺ កោះកុង បន្ទាយមានជ័យ ព្រះសីហនុ សៀមរាប ប៉ៃលិន ឧត្តរមានជ័យ តនគិរី ត្បូងឃ្មុំ កំពង់ចាម កំពង់ធំ ស្ទឹងត្រែង និងខេត្តតាកែវ។ ក្រសួងក៏បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាព និងដោះស្រាយបញ្ហាប្រឈមនានានៃការអនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រចាំខែ

ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជាបន្តបន្ទាប់ផងដែរ។ ទន្ទឹមនេះ ក្រុមការងារបានប្រជុំពិភាក្សាលើការរៀបចំសេចក្តីព្រាងសេចក្តីណែនាំបច្ចេកទេសសម្រាប់គ្រប់គ្រងអនុវត្តបែបបទ និងនីតិវិធីលើមុខងារសេវាសុខភាពសត្វ និងផលិតកម្មសត្វ ដែលប្រតិភូកម្មទៅឱ្យរដ្ឋបាលរាជធានី ខេត្តចំនួន ១០លើក និងបានចេញប្រកាសស្តីពីការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ក្នុងការពិនិត្យ ផ្តល់យោបល់ និងសម្រេចលើការចុះបញ្ជីគម្រោងវិនិយោគដែលមានទុនវិនិយោគសមមូល ៥ (ប្រាំ) លានដុល្លារអាមេរិកចុះក្រោម។ ទន្ទឹមនេះ ដើម្បីជំរុញប្រសិទ្ធភាពការងារ ក្រសួងក៏បានរៀបចំកែសម្រួលសមាសភាពនៃគណកម្មាធិការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងលេខាធិការដ្ឋានសម្រាប់សម្របសម្រួលគាំទ្រកិច្ចដំណើរការប្រចាំថ្ងៃជាសេនាធិការផងដែរ។

### ៥.៦.១១ ការខារសម្បទានដីសេដ្ឋកិច្ច

គម្រោងសម្បទានដីសេដ្ឋកិច្ចមានចំនួន ២២៩គម្រោង ស្ថិតក្នុងខេត្តចំនួន ១៩ នៅទូទាំងប្រទេស រួមមាន៖ ខេត្តមណ្ឌលគិរី រតនគិរី ក្រចេះ ស្ទឹងត្រែង កំពង់ធំ កំពង់ចាម ត្បូងឃ្មុំ ព្រះវិហារ ឧត្តរមានជ័យ សៀមរាប បន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ កំពង់ស្ពឺ កោះកុង ព្រះសីហនុ កំពត ស្វាយរៀង និងខេត្តតាកែវ ដោយមានផ្ទៃដីទំហំ ១ ៣៩៣ ៨៩២ហ.ត។ គិតត្រឹមឆ្នាំ២០២៤នេះ ក្រសួងបាន៖

- ចុះកិច្ចសន្យាវិនិយោគសរុបចំនួន ២០៧គម្រោង ស្មើនឹងផ្ទៃដីទំហំ ១ ១៤៦ ៧០៧,៥៨ហ.ត មិនទាន់បានចុះកិច្ចសន្យាមានចំនួន ២២គម្រោង ស្មើនឹងផ្ទៃដីទំហំ ១១៨ ៧៧៨ហ.ត
- ចុះបញ្ជីដីរដ្ឋក្នុងគោលដៅសម្បទានដីសេដ្ឋកិច្ចរួចរាល់ស្ពាពរចំនួន ១៧៩គម្រោង ស្មើនឹងផ្ទៃដីទំហំ ៧៦២ ៨៩៦,០៦ហ.ត និងមិនទាន់បានចុះបញ្ជីដីរដ្ឋរួចរាល់ចំនួន ៥០គម្រោង ស្មើនឹងផ្ទៃដីទំហំ ២០៥ ០០៣,៨០ហ.ត
- ឈូសឆាយលើផ្ទៃដីទំហំ ៥៣៦ ២៣២,១៩ហ.ត និងដាំដុះ ៣៦៧ ៤៦៧,៥២ហ.ត
- អនុវត្តដាំដំណាំកៅស៊ូ អំពៅ ឈើដាំ (ប្រេងខ្យល់ អាកាស្យា ម៉ៃសាក់) ដំឡូងមី ចន្ទី ស្រល់ ចេក ដូងប្រេង ស្វាយ និងចិញ្ចឹមសត្វ
- ធ្វើអនុប្បយោគចំនួន ១៥៨គម្រោង មានការកើនឡើងចំនួន ៨គម្រោង ធៀបនឹងឆ្នាំ២០២២ មានត្រឹមតែ ១៥១គម្រោង និងមិនទាន់បានធ្វើអនុប្បយោគចំនួន ៧៤គម្រោង
- ប្រើប្រាស់កម្លាំងពលកម្មសរុបចំនួន ៥៦ ៧៤៣នាក់ (បុគ្គលិកជនជាតិខ្មែរចំនួន ៦ ១១៤នាក់ បុគ្គលិកបរទេសចំនួន ៣ ៧៩៨នាក់ កម្មករជនជាតិខ្មែរចំនួន ៣៨ ៨៨២នាក់ និងកម្មករអណ្តែតចំនួន ៧ ៩៤៩នាក់) មានការកើនឡើងចំនួន ៩ ១៧៥នាក់ ស្មើនឹង ១៩,២៨% ធៀបនឹងឆ្នាំ២០២៣ ដែលមានកម្លាំងពលកម្មសរុបចំនួន ៤៧ ៥៦៨នាក់
- ការប្រមូលចំណូលថ្លៃសម្បទានដីសេដ្ឋកិច្ច និងបង់បំណុលឆ្នាំចាស់ចូលថវិការដ្ឋ មានទឹកប្រាក់សរុបចំនួន ៥ ៨៩៥ ០៤២,៨៥ដុល្លារអាមេរិក។

## ៦. បញ្ហាប្រឈម

ទោះបីជាវិស័យកសិកម្មសម្រេចបានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្តី ក៏វិស័យនេះនៅតែជួបប្រទះបញ្ហាប្រឈមមួយចំនួន ជាអាទិ៍ ការយល់ដឹងអំពីទស្សនទាននៃការអភិវឌ្ឍសហគមន៍កសិកម្មទំនើបនៅមានកម្រិត មិនទាន់ឆ្លើយតបតាមតម្រូវការរបស់កសិករ ហេដ្ឋារចនាសម្ព័ន្ធគាំទ្រផលិតកម្ម (ប្រព័ន្ធស្រោចស្រពក្នុងកសិដ្ឋានដោយសន្សំសំចៃទឹក ផ្ទះសំណាញ់ ប្រព័ន្ធស្តុកទុក ឃ្លាំងសម្ងួត ឃ្លាំងត្រជាក់) ប្រព័ន្ធផលិតកម្មគ្រាប់ពូជសុទ្ធ និងការប្រើប្រាស់ពូជដំណាំដែលមានគុណភាពល្អនៅមិនទាន់បានទូលំទូលាយ តម្លៃផលិតផលដំណាំមិនទាន់មានស្ថេរភាព កកស្ទះនៅពេលរដូវប្រមូលផលដោយសារការប្រមូលទិញស្តុកទុកមានកម្រិតមិនទាន់ឆ្លើយតបនឹងទំហំផលិតផល

សមត្ថភាពក្នុងកែច្នៃនៅមានកម្រិត និងការប្រកួតប្រជែងទីផ្សារក៏ដូចជាស្វែងរកទីផ្សារក្នុងស្រុក និងបរទេស នៅតែជាប្រធានបទដែលត្រូវយកចិត្តទុកដាក់ និងបន្តដោះស្រាយ។

ផលិតភាពនៃផលិតកម្មសត្វសម្រាប់កសិករខ្នាតតូចនៅមានកម្រិត ជាមួយនឹងថ្លៃដើមផលិតកម្មខ្ពស់ (ថ្លៃចំណីសត្វ ពូជសត្វ និងថ្នាំការពារ ព្យាបាលសត្វ) តម្លៃសត្វរស់ សាច់ និងផលិតផលសត្វធ្លាក់ថ្លៃ ដែលធ្វើឱ្យការប្រកួតប្រជែងទីផ្សារសាច់សត្វជួបការលំបាក។ ការធ្វើផែនការផលិតកម្មសត្វដើម្បីផ្គត់ផ្គង់ក្នុងស្រុក និងនាំចេញនៅតែជាបញ្ហាដែលត្រូវយកចិត្តទុកដាក់ខ្ពស់។ ប្រព័ន្ធគ្រប់គ្រងអនាម័យ និងភូតគាមអនាម័យនៅមានកម្រិត ការនាំចូលសត្វ និងផលិតផលសត្វខុសច្បាប់នៅតែបន្តកើតមាន។

ការគ្រប់គ្រងធនធានជលផលនៅមានបញ្ហាប្រឈមមួយចំនួន ដូចជា ការធ្វើនេសាទខុសច្បាប់នៅតែមាន ការរំលោភទន្ទ្រានកាន់កាប់ដីព្រៃលិចទឹក និងព្រៃកោងកាង ការការពារកន្លែងអភិរក្សជលផល និងការចូលរួមរបស់សហគមន៍នេសាទនៅមានកម្រិត។ ការធ្វើវារីវប្បកម្មចំណាយថ្លៃដើមខ្ពស់ ជាហេតុនាំឱ្យពិបាកក្នុងការប្រកួតប្រជែងទីផ្សារ រួមទាំងការកង្វះហេដ្ឋារចនាសម្ព័ន្ធក្រោយពេលប្រមូលផល សម្រាប់គាំទ្រដល់ការរក្សាគុណភាព និងការអនុវត្តអនាម័យល្អ។

ការរីកលូតលាស់ផ្នែកសេដ្ឋកិច្ចកសិកម្ម និងកំណើននៃតម្រូវការដីសម្រាប់ធ្វើកសិកម្ម គឺជាហេតុផលចម្បងដែលនាំឱ្យមានការថយចុះនូវផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ។ ទន្ទឹមនេះ ការអនុវត្តច្បាប់ និងផលប្រយោជន៍ប្រជាជនដែលពឹងអាស្រ័យលើព្រៃឈើ នៅតែមានភាពស្មុគស្មាញ ហើយទាមទារឱ្យមានការគាំទ្រ និងផ្តល់ជម្រើសដល់ប្រជាពលរដ្ឋឱ្យចាប់យកមុខរបរកសិ-រុក្ខកម្ម ឬមុខរបរផ្សេង ដើម្បីកាត់បន្ថយសម្ពាធមកលើធនធានព្រៃឈើ។

## ៧. ទិសដៅអនុវត្ត

ក្នុងឆ្នាំ២០២៥នេះ ក្រសួងបានកំណត់ទិសដៅការងារសម្រាប់អនុវត្តតាមអនុវិស័យនីមួយៗដូចខាងក្រោម៖

### ៧.១ ផែនការជំរុញផលិតកម្មដំណាំស្រូវ ដំណាំស្បៀងរួមផ្សំ និងដំណាំទ្រទ្រង់សេដ្ឋកិច្ច

ក្រសួងមានគោលដៅសម្រេចឱ្យបាននូវតម្លៃសេដ្ឋកិច្ចផលិតផលដំណាំនៅកសិដ្ឋានចំនួន ៨ ៥៥៣លានដុល្លារអាមេរិក ផលិតផលដំណាំកសិកម្មនាំចេញចំនួន ៤ ៨៦៩លានដុល្លារអាមេរិក និងអភិវឌ្ឍសហគមន៍កសិកម្មទំនើបចំនួន ២សហគមន៍។ ដើម្បីសម្រេចគោលដៅនេះ ក្រសួងបានកំណត់ផែនការសកម្មភាពដូចខាងក្រោម៖

- ជំរុញការកសាងសហគមន៍កសិកម្មទំនើប ដោយបន្តការផ្សព្វផ្សាយនូវទស្សនទានស្តីពីការអភិឌ្ឍសហគមន៍កសិកម្មទំនើប ពង្រឹងសមត្ថភាពគ្រប់គ្រង អភិបាលកិច្ចនិងការរៀបចំផែនការអាជីវកម្ម និងកៀរគរធនធាន គាំទ្រទាំងបច្ចេកទេស និងហិរញ្ញប្បទាន
- ជំរុញការអភិវឌ្ឍខ្សែច្រវាក់ផលិតកម្មដំណាំដែលមានសក្តានុពលសម្រាប់ការនាំចេញ តាមរយៈការសិក្សាវាយតម្លៃប្រភេទពូជដំណាំ ការចុះបញ្ជីប្រភេទពូជដំណាំ ការអភិវឌ្ឍបច្ចេកទេសដាំដុះ ការពង្រឹងប្រព័ន្ធផលិតកម្មគ្រាប់ពូជដំណាំ និងការគាំទ្របច្ចេកទេសដល់មន្ត្រីជំនាញ មន្ត្រីកសិកម្មឃុំសង្កាត់/ សហគមន៍កសិកម្មទំនើ កសិករ និងអ្នកពាក់ព័ន្ធ នៅតាមតំបន់មេគង្គលើ មេគង្គក្រោម ទន្លេសាប និងតំបន់ឆ្នេរ
- លើកកម្ពស់គុណភាព សុវត្ថិភាពនិងការសម្រួលពាណិជ្ជកម្មកសិផល ដោយជំរុញការគាំទ្របច្ចេកទេសផលិតកម្មតាមស្តង់ដានិងការផ្តល់វិញ្ញាបនបត្រការអនុវត្តកសិកម្មល្អ និងកសិកម្មសរីរាង្គ ការអន្តរាគមន៍កម្ចាត់សមាសភាពចង្រៃនិងពង្រឹងការគ្រប់គ្រងនិងអនុវត្តវិធានភូតគាមអនាម័យ ព្រមទាំងពន្លឿនការអនុវត្តការផ្តល់វិញ្ញាបនបត្រភូតគាមអនាម័យតាមប្រព័ន្ធអេឡិត្រូនិក (ePhyto) និងប្រព័ន្ធឌីជីថល

- ជំរុញការគ្រប់គ្រងនិងការប្រើប្រាស់ធាតុចូលកសិកម្ម មានជីកសិកម្ម ថ្នាំកសិកម្ម និងពូជដំណាំឱ្យមានប្រសិទ្ធភាពខ្ពស់សំដៅកាត់បន្ថយថ្លៃដើមផលិត លើកកម្ពស់គុណភាព និងសុវត្ថិភាពកសិផល និងភាតរបរិស្ថាន
- ជំរុញការគ្រប់គ្រងធនធានដីកសិកម្មប្រកបដោយចីរភាព ដោយបន្តការសិក្សាវាយតម្លៃដីជាតិដី ការធ្វើផែនទីកំណត់តំបន់ដាំដុះដំណាំសំខាន់ៗ និងការជំរុញអនុវត្តកសិកម្មនិរន្តរភាព ដើម្បីថែរក្សាសុខភាពដី។

## ៧.២ ផែនការបង្កើនផលិតកម្មដំណាំកៅស៊ូ

ក្រសួងមានគោលដៅសម្រេចឱ្យបានកំណើនផ្ទៃដីចៀរជ័រក្នុងរង្វង់ ៤% (ក្នុងរង្វង់ ៣៣៦ពាន់ហិកតា) ទិន្នផលកៅស៊ូក្នុងរង្វង់ ៣,៣% (ក្នុងរង្វង់ ១ ២៧៩គីឡូក្រាម/ហិកតា) ផលិតផលកៅស៊ូក្នុងរង្វង់ ៧,៥% (ក្នុងរង្វង់ ៤៣០ពាន់តោន) និងតម្លៃសេដ្ឋកិច្ចនៃផលិតផលកៅស៊ូចំនួន ៦៤៥លានដុល្លារអាមេរិក។

ដើម្បីសម្រេចគោលដៅនេះ ក្រសួងបានកំណត់ផែនការសកម្មភាពដូចខាងក្រោម៖

- បន្តសិក្សា ស្រាវជ្រាវ និងកសាងលិខិតគតិយុត្តពាក់ព័ន្ធ
- បន្តជំរុញការប្រើប្រាស់កូនកៅស៊ូដែលមានសក្ដានុពល
- បន្តជំរុញការអភិវឌ្ឍសហគមន៍កសិកម្មកៅស៊ូគ្រួសារ
- បន្តជំរុញនិងកែលម្អគុណភាពផលិតផលកៅស៊ូ តម្រូវតាមទីផ្សារ
- បន្តជំរុញនិងសម្របសម្រួលបង្កើនការប្រើប្រាស់ផលិតផលកៅស៊ូក្នុងស្រុក
- បន្តសម្របសម្រួលនិងពង្រឹងសកម្មភាពរបស់សមាគមអភិវឌ្ឍន៍កៅស៊ូកម្ពុជា (ARDC)
- បន្តជំរុញការសិក្សាលទ្ធភាពបង្កើតមជ្ឈមណ្ឌលកែច្នៃ និងទីផ្សារកៅស៊ូ
- បន្តចុះពិនិត្យនិងផ្តល់ប្រឹក្សាផ្ទាល់នៅចម្ការជាមួយកសិករកៅស៊ូគ្រួសារ
- បន្តសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រស្តីពីពូជ បច្ចេកទេស ថែទាំកូនកៅស៊ូ ការគ្រប់គ្រងសមាសភាពចង្រៃ ការយកផល និងការកែច្នៃ
- ជំរុញអនុវត្តបែបបទវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ (CSR) សម្រាប់ការនាំចេញកៅស៊ូនិងវិញ្ញាបនបត្របញ្ជាក់គុណភាពច្បារពូជ
- បន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយ ដៃគូអភិវឌ្ឍន៍ ទីភ្នាក់ងារ និងអង្គការជាតិនិងអន្តរជាតិនានា។

## ៧.៣ ផែនការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ

ក្រសួងមានគោលដៅសម្រេចឱ្យបាននូវតម្លៃសេដ្ឋកិច្ចនៃសត្វ និងផលិតផលសត្វក្នុងឆ្នាំ២០២៥ ចំនួន ១ ៧៥៦ លានដុល្លារអាមេរិក និងកាត់បន្ថយអត្រាជំងឺឆ្លងសត្វឱ្យនៅក្រោម ៥%។

ដើម្បីសម្រេចគោលដៅនេះ ក្រសួងបានកំណត់ផែនការសកម្មភាពដូចខាងក្រោម៖

- បន្តផ្តល់សេវាបសុព្យាបាល និងបង្កើនសមត្ថភាពបច្ចេកទេសដល់កសិករចិញ្ចឹមសត្វ
- បន្តពង្រឹងការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ ពង្រឹងអនុវត្តច្បាប់ ពង្រឹងសមត្ថភាពមន្ត្រី និងបណ្តុះបណ្តាលពីបច្ចេកទេសពិឃាតសត្វប្រកបដោយមនុស្សធម៌ដល់ម្ចាស់សត្តឃាតដ្ឋាន និងអាជីវករពិឃាតសត្វ
- ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំនានា ពង្រឹងសមត្ថភាពមន្ត្រីនិងផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ បង្កើនការត្រួតពិនិត្យនិងធ្វើអធិការកិច្ចលើអាជីវកម្មនាំចូល នាំចេញ និងនាំឆ្លងកាត់សត្វនិងផលិតផលសត្វ សត្តឃាតដ្ឋាន កសិដ្ឋានចិញ្ចឹមសត្វនិងបង្កាត់ពូជសត្វ កន្លែងផលិតលាយផ្សំ ឬវេចខ្ចប់ជាថ្មី កន្លែងផ្គត់ផ្គង់

ចែកចាយ ឃ្លាំងសន្និធិចំណីសត្វ វត្ថុធាតុដើម សារធាតុបន្ថែម បសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម សមាសធាតុគ្រប់ប្រភេទ
- បង្កើនសមត្ថភាពមន្ត្រីគ្រប់កម្រិត ដើម្បីផ្ទេរចំណេះដឹងលើជំនាញសុខភាពសត្វ និងផលិតកម្មសត្វដូចជា ការចិញ្ចឹម ការបង្កាត់ពូជសត្វ សុវត្ថិភាពចំណីអាហារ បសុឱសថ ជីវសុវត្ថិភាព ការបង្ការជំងឺឆ្លងរាលដាលសត្វ ខ្សែច្រវាក់ផលិតកម្មសត្វ ការធ្វើពាណិជ្ជកម្មសត្វដល់វិស័យឯកជន អង្គការដៃគូអភិវឌ្ឍន៍ សហគមន៍ សមាគមកសិករចិញ្ចឹមសត្វ ដើម្បីបង្កើនផលិតភាពសត្វ
- ជំរុញលើកទឹកចិត្តសហគមន៍ចិញ្ចឹមសត្វ កសិករចិញ្ចឹមសត្វតាមកិច្ចសន្យា ដើម្បីលើកកម្ពស់ផលិតកម្មសត្វធានាបាននូវបរិមាណផ្គត់ផ្គង់
- ពង្រឹងការសិក្សាស្រាវជ្រាវ ការអង្កេតតាមដានជំងឺឆ្លងសត្វ សំដៅរកឱ្យឃើញប្រភពជំងឺ និងឆ្លើយតបទាន់ពេលវេលា ព្រមទាំងពង្រឹងការស្រាវជ្រាវចំណីសត្វ បសុឱសថ ពូជសត្វដែលមានលក្ខណៈបន្សាំនឹងការប្រែប្រួលអាកាសធាតុ ធន់នឹងជំងឺ លូតលាស់លឿន និងស្របនឹងតម្រូវការទីផ្សារ និងការបង្កាត់ពូជសិប្បនិម្មិត
- លើកកម្ពស់ភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន
- លើកទឹកចិត្ត គាំទ្រ និងជួយសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធ ប្រទេសបញ្ចាទិញ ដើម្បីអន្តរាគមន៍បានចូលទីផ្សារក្នុងការប្រកួតប្រជែងផលិតផលដែលផលិតបាន
- ពង្រឹងកិច្ចសហប្រតិបត្តិការទាំងកម្រិតថ្នាក់ជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន អង្គការជាតិ អង្គការអន្តរជាតិនានាពាក់ព័ន្ធអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ

## ៧.៤ ផែនការពង្រឹងការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម

ក្រសួងមានគោលដៅសម្រេចឱ្យបានការនាំចេញផល ផលិតផលជលផលចំនួន ៨លានដុល្លារអាមេរិក សមុទ្រចំនួន ៣៣០ពាន់តោន និងផលវារីវប្បកម្មទឹកសាប និងផ្ទៃដីដែនគ្រប់គ្រងជលផលត្រូវបានការពារនិងគ្រប់គ្រងចំនួន ៩,៦ លានហ.ត។ ដើម្បីសម្រេចគោលដៅនេះ ក្រសួងបានកំណត់ផែនការសកម្មភាពដូចខាងក្រោម៖
- បន្តការអនុវត្តច្បាប់ដោយម៉ឺងម៉ាត់ ដោយសហការទប់ស្កាត់និងបង្ក្រាបបទល្មើសជលផលគ្រប់ប្រភេទ
- បន្តការការពារកន្លែងអភិរក្សជលផលនិងប្រភេទត្រីកំពុងរងគ្រោះថ្នាក់ក្នុងដែនទឹកធម្មជាតិ
- ជំរុញការអភិវឌ្ឍវារីវប្បកម្មតាមគ្រប់រូបភាព ដោយសិក្សាពីតម្រូវការទីផ្សារនិងធ្វើផែនការផលិតកម្មច្បាស់លាស់ព្រមទាំងលើកទឹកចិត្តផ្តល់បច្ចេកទេសក្នុងការអនុវត្តវារីវប្បកម្មល្អ
- ជំរុញការអភិវឌ្ឍខ្សែច្រវាក់តម្លៃ ពង្រឹងការត្រួតពិនិត្យ និងវិភាគគុណភាព សុវត្ថិភាពផលផលិតផលជលផល
- ពង្រឹងសមត្ថភាពសហគមន៍នេសាទឱ្យមានភាពជាម្ចាស់ក្នុងការគ្រប់គ្រងធនធានជលផលឱ្យមានប្រសិទ្ធភាព និងនិរន្តរភាព
- បន្តសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍វិស័យជលផល
- បង្កើនការសិក្សាស្រាវជ្រាវបច្ចេកទេសនិងវិទ្យាសាស្ត្រជលផលទឹកសាបនិងសមុទ្រ
- ពង្រឹងការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព។

## ៧.៥ ផែនការពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃ

សម្រាប់អនុវិស័យនេះ ក្រសួងមានគោលដៅសម្រេចឱ្យបានផ្ទៃដីដាំឈើឡើងវិញចំនួន ៣ ០០០ហ.ត និងកំណត់ព្រំប្រទល់ដីព្រៃឈើ ដើម្បីចុះបញ្ជីដីរដ្ឋ (ដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ សម្បទានដី សេដ្ឋកិច្ច សហគមន៍ព្រៃឈើ ព្រៃបម្រុងទុកអចិន្ត្រៃយ៍។ល។) ចំនួន ២០ ០០០ហ.ត។

ដើម្បីសម្រេចគោលដៅនេះ ក្រសួងបានកំណត់ផែនការសកម្មភាពដូចខាងក្រោម៖

- ជំរុញ និងពង្រឹងការរៀបចំថវិកាសមិទ្ធកម្ម ឱ្យឆ្លើយតបទៅនឹងសូចនាករគោលដៅ ដោយយកបទពិសោធន៍ ការអនុវត្តក្នុងឆ្នាំ២០២៤ ដើម្បីតម្រង់ទិសការអនុវត្តឆ្នាំ២០២៥
- ជំរុញការអនុវត្តទស្សនៈវិស័យរបស់ក្រសួងគឺ៖ **មានហូប មានបាន មានប្រើ និងមានរហូត** ដោយបានកំណត់ពីតម្រូវការរបស់សហគមន៍មូលដ្ឋានក្នុងការទាញយកផល អនុផលព្រៃឈើ និងការប្រមាញ់ ឱ្យប្រែក្លាយទៅជាការជំរុញការចិញ្ចឹមសត្វ ត្រី ការធ្វើស្រែចម្ការ ដែលកិច្ចការទាំងនេះពាក់ព័ន្ធនឹងការធ្វើសហគមន៍កសិកម្មទំនើប
- ចូលរួមក្នុងការអនុវត្តកម្មវិធី **ផ្តល់ដី ការពារព្រៃឈើ** ដោយធ្វើការកំណត់ទីតាំងដីដែលត្រូវដាក់បញ្ចូលក្នុងកម្មវិធីផ្តល់ដី ការពារព្រៃ រៀបចំផែនការអភិវឌ្ឍនៅទីតាំងនិងនៅជិតទីតាំងកម្មវិធី "ផ្តល់ដី ការពារព្រៃឈើ" ព្រមទាំងគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ
- ជំរុញការដាំឈើតាមគ្រប់រូបភាពជាលក្ខណៈពាណិជ្ជកម្ម គ្រួសារ ឬដោយប្រជាពលរដ្ឋតាមទម្រង់ជារដ្ឋ សហការដៃគូរដ្ឋ-ឯកជន-សហគមន៍មូលដ្ឋានជាដើម ព្រមទាំងជំរុញការបណ្តុះកូនឈើឱ្យបានច្រើនជា អតិបរមាសម្រាប់ចែកចាយប្រជាពលរដ្ឋ
- សិក្សាតម្រូវការប្រើប្រាស់ផល អនុផលព្រៃឈើ ឱ្យបានចប់សព្វគ្រប់នៅចុងឆ្នាំ២០២៥
- ជំរុញការគ្រប់គ្រងព្រៃលំហែកម្សាន្ត និងឧទ្យានសួនសត្វ សួនរុក្ខជាតិ និងព្រៃការពារ ឱ្យក្លាយជាតំបន់ទាក់ទាញទេសចរណ៍ធម្មជាតិ និងលើកកម្ពស់ការសង្គ្រោះ ថែរក្សា ព្យាបាល និងស្តារលទ្ធភាពសត្វព្រៃ
- ជំរុញការត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រសិប្បកម្ម កែច្នៃផល អនុផលព្រៃឈើ ឱ្យកាន់តែមានប្រសិទ្ធភាព ជាពិសេសពង្រឹងការគ្រប់គ្រងលើការប្រមូលផល អនុផលព្រៃឈើ ក្នុងតំបន់សម្បទានសេដ្ឋកិច្ច និងក្នុងតំបន់ព្រៃដាំឈើដៃគូសហការ
- បន្តបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃ ជាពិសេសប្រើប្រាស់កម្លាំងសរុបបង្ក្រាបបទល្មើសនៃការកាប់រាន ដុតឈូសឆាយ និងហ៊ុមព័ទ្ធយកដីព្រៃឈើធ្វើកម្មសិទ្ធិតាមគ្រប់រូបភាព ដោយចុះស្រាវជ្រាវ រុករក ទីតាំងប្រព្រឹត្តបទល្មើស រកអ្នកសមគំនិត ដកហូតវត្ថុតាង និងឃាត់ខ្លួនជនប្រព្រឹត្តបទល្មើស បំពេញនីតិវិធីបញ្ជូនទៅតុលាការ
- ជំរុញការទប់ស្កាត់ និងមានវិធានការការពារភ្លើងឆេះព្រៃ ដោយមានយន្តការគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្តដឹកនាំបញ្ជាផ្ទាល់ប្រើប្រាស់កម្លាំងសរុប ប្រជាពលរដ្ឋ សហគមន៍ សិស្សានុសិស្ស ព្រះសង្ឃ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ព្រមទាំងចាត់វិធានការផ្លូវច្បាប់ចំពោះជនណាដែលបានកាប់រុករាន ដុតព្រៃដើម្បីយកដីផ្ទុយនឹងច្បាប់ និងបទបញ្ជានានារបស់រាជរដ្ឋាភិបាល
- ជំរុញការចុះបញ្ជីដីរដ្ឋ (ដីស្ថានីយស្រាវជ្រាវព្រៃឈើ ដីចម្ការឈើដាំ ស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើ សហគមន៍ព្រៃឈើ និងដីក្នុងបញ្ជីទ្រព្យរដ្ឋ) ដោយប្រែក្លាយពីទ្រព្យអសកម្ម ឱ្យទៅជាទ្រព្យសកម្ម
- ការធ្វើបច្ចុប្បន្នភាពកំណែទម្រង់រដ្ឋបាលសាធារណៈ វិភាគមុខងារ និងរៀបចំរចនាសម្ព័ន្ធអង្គភាពឱ្យបានសមស្រប និងបញ្ចប់ការធ្វើបច្ចុប្បន្នភាពសេចក្តីព្រាងច្បាប់ស្តីពីព្រៃឈើ ព្រមទាំងពិនិត្យ និងរៀបចំកែសម្រួលលិខិតបទដ្ឋានគតិយុត្តក្នុងអនុវិស័យព្រៃឈើ
- បន្តសហការជាមួយដៃគូពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍នានា និងស្វែងរកដៃគូថ្មីៗទៀត ដើម្បីជំរុញកិច្ចសហប្រតិបត្តិការឱ្យកាន់តែប្រសើរ និងអនុវត្តគម្រោងការបណ្តុះបណ្តាលសមត្ថភាពដល់មន្ត្រីរដ្ឋបាលព្រៃឈើ ដោយបង្កើនការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ
- ពិនិត្យផ្ទៀងផ្ទាត់ និងតាមដានព័ត៌មានពាក់ព័ន្ធនឹងព្រៃឈើ-សត្វព្រៃ ដើម្បីបំភ្លឺជូនសាធារណជនឱ្យទាន់ពេលវេលា យកចិត្តទុកដាក់គោរពវិន័យ សាមគ្គីភាពផ្ទៃក្នុង ព្រមទាំងបន្តកិច្ចសហការឱ្យបានជិតស្និទ្ធជាមួយអាជ្ញាធរ ដែនដី

កងកម្លាំងប្រដាប់អាវុធ ព្រះរាជអាជ្ញា តុលាការគ្រប់លំដាប់ថ្នាក់ និងអង្គភាពពាក់ព័ន្ធដើម្បីឱ្យដំណើរការអនុវត្តការងារអនុវិស័យព្រៃឈើទទួលបានលទ្ធផលល្អ និងមានប្រសិទ្ធភាព។

## ៧.៦ ផែនការពង្រឹងការគ្រប់គ្រងស្ថាប័ន និងអភិវឌ្ឍន៍ធនធានមនុស្ស

ក្រសួងមានគោលដៅសម្រេចឱ្យបានអនុបាតនៃការអនុវត្តថវិកាកម្មវិធី ៩៥% និងចំនួននិស្សិតដែលបានបញ្ចប់ការសិក្សាចំនួន ១ ០៤០នាក់ ព្រមទាំងអនុវត្តសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- កសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២៤-២០២៨ ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៦-២០២៨ ផែនការថវិកាកម្មវិធីឆ្នាំ២០២៦ ផែនការវិនិយោគសាធារណៈបីឆ្នាំរំកិលឆ្នាំ២០២៦-២០២៨ និងកិច្ចព្រមព្រៀងសមិទ្ធកម្មឆ្នាំ២០២៥
- បន្តតាមដាន និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ និងគោលនយោបាយ ថវិកាកម្មវិធីឆ្នាំ២០២៥ ពង្រឹងប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ច
- បន្តពង្រឹងប្រព័ន្ធស្ថិតិ ព័ត៌មានទីផ្សារកសិកម្ម ប្រព័ន្ធព័ត៌មានវិទ្យា និងផ្សព្វផ្សាយកសិកម្ម
- ពង្រឹងការប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- បន្តអនុវត្តគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្សរបស់ក្រសួង និងពង្រឹងការគ្រប់គ្រងមន្ត្រីរាជការ
- បន្តអនុវត្តផែនការបណ្តុះបណ្តាលនិស្សិតរបស់គ្រឹះស្ថានអប់រំកសិកម្មទាំងបី
- បន្តរៀបចំនីតិវិធីជ្រើសរើស និងដាក់ពង្រាយមន្ត្រីកសិកម្ម ទៅបម្រើការងារនៅតាមឃុំ-សង្កាត់ទូទាំងប្រទេស
- បន្តជំរុញការអភិវឌ្ឍកសិកម្មក្នុងតំបន់ប៉ូលសេដ្ឋកិច្ចថ្មីតំបន់ពាយព្យ (ច្រករបៀងមច្ឆា និងអង្គរ)
- បន្តរៀបចំ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្ត ឱ្យស្របតាមស្ថានភាពនៃការវិវត្តរបស់វិស័យកសិកម្ម។

ដោយឡែក ក្រសួងមានផែនការពង្រឹងការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច តាមរយៈការដាក់ចេញនូវទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០២៥ ដូចខាងក្រោម៖

- បន្តពិនិត្យតាមដាន និងពង្រឹងការប្រមូលចំណូលពីថ្លៃឈ្នួលដីសម្បទានដីសេដ្ឋកិច្ច
- បន្តជំរុញការរៀបចំកសាង និងធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ច
- បន្តសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ជំរុញការចុះបញ្ជីដីឯកជនរបស់រដ្ឋក្នុងគោលដៅសម្បទានដីសេដ្ឋកិច្ចក្នុងតំបន់ឱ្យមានសុវត្ថិភាពជាមុន និងបន្តដោះស្រាយលើទីតាំងដែលមានភាពប្រទាញប្រទង់ពុំទាន់ដាច់ស្រេច
- បន្តប្រើប្រាស់យន្តការនៃគណៈកម្មាធិការជាតិ ដើម្បីទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើ ដើម្បីវាតយកដីធ្វើកម្មសិទ្ធិដើម្បីដោះស្រាយបញ្ហាទន្ទ្រានដី និងវិវាទផ្សេងៗដែលកើតឡើងក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច
- បន្តប្រមូលទិន្នន័យ ព័ត៌មានទាក់ទងនឹងសម្បទានដីសេដ្ឋកិច្ច ដើម្បីរៀបចំមូលដ្ឋានទិន្នន័យធ្វើផែនទី និងបង្កើតមូលដ្ឋានទិន្នន័យផ្នែករឹង និងផ្នែកទន់ (Hard Copy and Soft Copy) នៃផ្ទៃដីគម្រោងសម្បទានដីសេដ្ឋកិច្ច ដើម្បីរៀបចំគោលការណ៍គ្រប់គ្រងគម្រោងសម្បទានដីសេដ្ឋកិច្ចឱ្យមានប្រសិទ្ធភាព
